# មហាគ្រោះជាតិខ្មែរ

# *The Great Danger of Khmer Nation*

## មាតិការរឿង ទំព័រ


អារម្ភកថា ........................................................................................................ ២

១-អង្គការឧក្រិដ្ឋជនសំងាត់បាក់គី (Secret Criminal Organization of Backy)......... ៥

២-អង្គការយុវជនពិសេស អេស-អូ-វ៉ាយ (S.O.Y = Special Organization of Youths).. ១៧

៣- អង្គការឧក្រិដ្ឋជនសំងាត់អាវឈុតខ្មៅ Death Squads....................... ៦២

៤-អង្គការឧក្រិដ្ឋជនស្របច្បាប់របស់រដ្ឋាភិបាលអាយ៉ងតឹកងកំលាំងប្រដាប់អាវុធ............... ៧៨

៥-រចនាសម្ព័ន្ធឃាតកម្មរបស់គណៈបក្សប្រជាជនកម្ពុជា:..................................... ៨៦

៦-មូលហេតុអ្វីបានជា ហ៊ុន-សែន គ្រប់គ្រងក្រុមឃាតករយ៉ាងណែនក្នុងដៃយ៉ាងនេះ? ១០៣

៧-ល្បិចកាប់ដើមដុតគល់រំលើងរឹសដើម្បីសំរេចបេសសកម្មរំលាយជាតិសាសន៍ខ្មែរ ១១១

៨-តើអំណាចផ្តាច់ការផ្តាច់មុខរបស់គណៈបក្សប្រជាជនបានមកពីណា? ១១៩

៩-យុទ្ធសាស្ត្រក្ស័យប្រល័យមរណ:ឆ្លងគ្រោះរំដោះមហាគ្រោះរបស់ប្រជាជាតិខ្មែរ: ១២១

១០-សន្និដ្ឋាន ១៣២

# អារម្ភកថា

ជំរៅមហាគ្រោះរបស់ជាតិខ្មែរគ្រាន់តែជាជ្រុងដ៏សែនតូចមួយនៃបេសសកម្មរំលាយជាតិជាតិសាសន៍ខ្មែររបស់ក្រុងហាណូយតាមរយៈគណៈបក្សប្រជាជនកម្ពុជា បន្ទាប់ពីយួនកុំមុយនីស្ត៍ឈ្លានពានខ្មែរ និងលេបទឹកដីខ្មែរបានសំរេចជាស្ថាពរហើយនោះ នៅមានបញ្ហាសេសសល់គឺជាតិសាសន៍ដែលរស់នៅលើដីកំណើតខ្លួនអាចធ្វើបដិវត្តន៍រើបំរះនៅថ្ងៃណាមួយ ប្រសិនបើជនជាតិខ្មែរមានចំនួនច្រើនយ៉ាងនេះ ដូច្នេះចាំបាច់ត្រូវតែបន្តគោលនយោបាយរំលាយជាតិសាសន៍ខ្មែរ ធ្វើអោយជនជាតិខ្មែរមានចំនួនតិចទៅៗ រហូតដល់សេសសល់ត្រឹមតែមួយក្តាប់តូចទុកគ្រាន់ល្មមតាំងពិពណ៌ដូចជនជាតិចម្ប៉ា ជនជាតិឡាវ និងជនជាតិខ្មែរកម្ពុជាក្រោម ហើយជំនួសដោយនយោបាយសមានកម្ម និងនយោបាយឆុងសាច់ឈាមយួន-ខ្មែរ ចិន-ខ្មែរ ចិន-យួន លាយចំរុះពូជសាសន៍ ដោយយកជនជាតិជាតិខ្មែរធ្វើជាទាសកររបស់យួន របស់ចិននៅលើទឹកដីកំណើតរបស់ខ្លួន។ ក្រុងហាណូយអនុវត្តយុទ្ធសាស្ត្រថ្មីដែលហៅថា "យុទ្ធសាស្ត្រជំហ៊ានគីង្គក់ "នៅក្នុងការរំលាយពូជសាសន៍ខ្មែរដោយបង្កើតបណ្តាញអង្គការឧក្រិដ្ឋជនសំងាត់បន្តកន្ទុយគ្នាជាបណាញខ្សែរសង្វាក់ ប្រទាក់ក្រឡាចាក់ច្រែះគ្នាយ៉ាងស្មុគស្មាញដូចជា អង្គការឧក្រិដ្ឋជនសំងាត់បាក់គី អេស-អូ-វ៉ាយ និង អង្គការឧក្រិដ្ឋជនសំងាត់អាវឈុតខ្មៅរួមជាមួយក្រុងកងកំលាំងប្រដាប់អាវុធរបស់រដ្ឋាភិបាលអាយ៉ងយួនដែលដឹកនាំដោយ ហ៊ុន-សែន ធ្វើការសំលាប់រង្គាលប្រជារាស្ត្រតាម "យុទ្ធសាស្ត្រជំហ៊ានគីង្គក់ " គឺសំលាប់តិចៗ សំលាប់តក់ៗ សំលាប់រយៈយូរសំលាប់ច្រើនករណីផ្សេងៗគ្នាគឺសំលាប់បានច្រើន ហើយអាចលាក់បាំងភ្នែកសហគមន៍អន្តជាតិបានយ៉ាងងាយស្រួល។ គណៈបក្សប្រជាជនកម្ពុជាមានប្រភពដើមកំណើតចេញមកពីយួនកុំមុយនីស្ត៍ដែលជាអ្នកបង្កើត និងបន្ទុបពួកគេឱ្យស្ថិតនៅលើបល្ល័ងអំណាចដែលសោយអំណាចរហូតដល់បច្ចុប្បន្ននេះ ហើយពួកគេបានយកព្រះមហាក្សត្រធ្វើជាទ្រនាប់ជើងរបស់ពួកគេដើម្បីឈរលើអំណាច ទាត់ធាក់វាយប្រហារសំលាប់ប្រជារាស្ត្រខ្មែរស្រេចតែក្បាលចិត្តដោយគ្រាន់តែយកលេសថាអនុវត្តតាមព្រះហត្ថលេខារបស់ព្រះមហាក្សត្រ ឬធ្វើតាមព្រះរាជតំរិះព្រះមហាក្សត្រតែប៉ុណ្ណោះ។ ទោះបីជាពួកថ្នាក់ដឹកនាំរបស់គណៈបក្សប្រជាជនកម្ពុជាចេញប្រភព

មកពីពួកចោរលួចចោរប្លន់ក្មេងពាលក្មេងអាណាថា មិនបានរៀនសូត្រជ្រៅជ្រះក៏ដោយ ប៉ុន្តែពួកគេទទួលការហ្វឹកហាត់សិល្បៈសង្គ្រាមពីចៅហ្វាយឃួនរបស់ពួកគេ ហើយពួកគេមាន ជំនាញប៉ិនប្រសព្វណាស់ចំពោះខាងរឿងសំលាប់ឃាតកម្ម ការធ្វើភេរវកម្ម ការគំរាមកំហែង ការបំបាក់ស្មារតីប្រជារាស្ត្រខ្មែរអោយភ័យរន្ធត់ខ្លាចបាក់ស្បាត ការប្រើឃាតករក្នុងបណ្តាញខ្សែសង្វាក់ចុចអន្ទាក់ គឺជាជំនាញរបស់ពួកគេនៅក្នុងការក្តោប អំណាច ហើយ **"ចំណុចខ្លាំងរបស់ពួកកុំមុយនីស្តគឺប្រើប្រាស់ឃាតកម្ម ទារុណកម្ម និងភេរវកម្ម ធ្វើជាឧបករណ៍តែមួយគត់សំរាប់គ្រប់គ្រងប្រទេស និងត្រួតត្រាក្តោបក្តាប់ប្រជាជនខ្មែរបានយ៉ាងណែននៅក្នុងដៃ ហើយ ចំណុចខ្សោយរបស់ពួកកុំមុយនីស្តគឺសេដ្ឋកិច្ច តែបើពួកវាមានសេដ្ឋកិច្ចហើយ គឺប្រៀបបីដូចជាសត្វខ្លាដុះស្លាប ធ្វើអ្វីក៏បាន"** ។ ទោះបីជាពួកថ្នាក់ដឹកនាំកុំមុយនីស្តកំពូល១ របស់គណះបក្ស ប្រជាជនកម្ពុជាបានសំលាប់ប្រជារាស្ត្រខ្មែររាប់មិនអស់ក៏ដោយ ក៏ពួកគេប៉ិនប្រសព្វធ្វើអោយពិភពខាងក្រៅដូចជា សហគមន៍អន្តរជាតិ មហាអំណាចពិភពសេរីមានសហរដ្ឋជាមេខ្លោងជាដើមនៅតែយល់ច្រលំ ស្មានមិនដល់ និងភន្តច្រលំថាពួកគេកំពុងតែអនុវត្តលទ្ធិប្រជាធិបតេយ្យដោយគ្រាន់ទុកឱ្យមាន គណះបក្សប្រឆាំងធ្វើអ្វីមិនកើតមានតួនាទីត្រឹមតែក្តាន់ក្តអោយគណៈបក្សប្រជាជននោមតែប៉ុណ្ណោះ ហើយគណៈបក្សប្រជាជនកម្ពុជាដែលជាស្ថានិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតនៅកម្ពុជា បានផ្តល់កៅអីតែបន្តិចបន្តួចដល់ពួកគណៈបក្សប្រឆាំងដើម្បីបិទផ្លូកថាពួកគេអនុវត្តលិទ្ធិប្រជាធិបតេយ្យព្រោះមានគណៈបក្សប្រឆាំងនៅក្នុងរដ្ឋាភិបាល ហើយយកពាក្យលទ្ធិប្រជាធិបតេយ្យនេះធ្វើជាឧបករណ៍ ធ្វើជានុយបញ្ឆោត ទៅស្ទូចលុយធំ ជារន្ទា ជាឈ្នាន់សំរាប់អោយគណៈប្រជាជនកម្ពុជាយកទៅបោកប្រាស់ ពួកសហគមន៍អន្តរជាតិ អង្គការអន្តរជាតិ និងបណ្តាប្រទេសមហាអំណាចនានាមានសហរដ្ឋអាមេរិកជាមេក្លោង ទៅស្ទូចយកលុយជំនួយអន្តរជាតិ និង លុយកំម្ចីបរទេសរាប់រយពាន់លានដុល្លាសហរដ្ឋអាមេរិកទៅចាក់បញ្ចូលក្នុងមាត់បិសាចកុំមុយនីស្ត ជាហេតុធ្វើអោយពួកកុំមុយនីស្តមានកំលាំងខ្លាំងក្លាមហិមារ ដោយយកលុយជំនួយបរទេស លុយកម្ចីបរទេស លុយចំណូលថវិការជាតិ លុយលក់ធនធានធម្មជាតិ និងលុយរបរម៉ាហ្វីយ៉ាអស់ទាំងនោះទៅពង្រឹង និងពង្រីកបណ្តាញ

អង្គការឧក្រិដ្ឋជនសំងាត់ បណ្ដាញឃាតករ ភេរវករ បណ្ដាញចោរលួចឆក់ប្លន់ជីវិត ជួញដូរគ្រឿងញៀន ជួញដូរមនុស្សនិងយកទៅបំពាក់ឧបករណ៍ចារកម្មអសន្យាណូទំនើបរួមទាំងពង្រីកប្រព័ន្ធចារជនទាំង៥ ទៅបំផ្លាញជាតិខ្មែរ កំទេចរាល់សរសរទ្រូងខ្មែរ បោសសំអាតពួកវរៈជនខ្មែរ គាស់រំលើងពួកអ្នកជាតិនិយមខ្មែរដើម្បីសំរេចបេសកកម្មរំលាយជាតិខ្មែររបស់ក្រុងហាណូយ ហើយរដ្ឋាភិបាលអាយ៉ងយួនដែលដឹកនាំដោយគណៈបក្សប្រជាជនកម្ពុជា និង ហ៊ុន-សែន ស្អីគេនោះ បានព្យាយាមបង្កើតកលយុទ្ធនៅក្នុងអង្គការឧក្រិដ្ឋជនសំងាត់ដីសែនស្មុគស្មាញប្រទាក់ក្រឡាចាក់ច្រែះគ្នាជាមួយកងកំលាំងប្រដាប់អាវុធ និងប្រពន្ធ័ចារកម្មចំរុះយួនខ្មែរអនុវត្តយុទ្ធសាស្ត្រ **"ជំហ៊ានតីង្គក់"** ដើម្បីសំរេចបេសសកម្មរំលាយជាតិខ្មែររបស់ក្រុងហាណូយ ដោយធ្វើការលួចឆក់ប្លន់ជីវិត ជួញដូរមនុស្ស ជួញដូរគ្រឿងញៀន បង្កើតបរិយាកាសបំពុលសង្គមខ្មែរ ធ្វើការកាប់សំលាប់បាញ់ប្រហារ ចាប់ចងវាយដំធ្វើទារុណកម្ម ដាក់គុកធ្វើទារុណកម្មដូចសត្វធាតុ ប៉ុន្តែសហគមន៍អន្តរជាតិអង្គការអន្តរជាតិ និងបណ្ដាប្រទេសមហាអំណាចលោកសេរីដែលមានសហរដ្ឋអាមេរិកជាមេក្លោងបែរជាពុតធ្វើមិនដឹងមិនឮ មិនធ្វើអន្តរាគមន៍អ្វីទាំងអស់ដើម្បីជួយស្រោយស្រង់ប្រជាជាតិខ្មែរអោយចេញពីរណ្តៅគ្រោះមរណៈរបស់យួន ថែមទាំងនាំគ្នាផ្តល់លុយជំនួយ និងលុយកំចីបរទេសទៅអោយរដ្ឋាភិបាលអាយ៉ងយួនដែលដឹកនាំដោយ ហ៊ុន-សែន ដើម្បីដូរយកផលប្រយោជន៍វិនិយោគទុន ធនធានធម្មជាតិខ្មែរ និងប្រយោជន៍ដែលមើលលមិនឃើញទៅវិញ ចំណែកឯអង្គការសហប្រជាជាតិមិនត្រឹមតែ មិនចាប់ ហ៊ុន-សែន និងពួកមេដឹកនាំគណៈបក្សប្រជាជនឯទៀត១យកទៅកាត់ទោសប៉ុណ្ណោះនោះទេ តែបែរជាឃុបឃិតសមគំនិតជាមួយពួកមេឧក្រិដ្ឋករ មេឃាតករ មេភេរវករ ហ៊ុន-សែន ហើយបង្កើតតុលាការសាលាក្តីខ្មែរក្រហមលាងសំអាតបទឧក្រិដ្ឋកម្មប្រល័យមនុស្សជាតិរបស់យួន និងអំពើឈ្លានពានលេបទឹកដីខ្មែររបស់យួនឱ្យក្លាយទៅជាអំពើស្របច្បាប់ទៅវិញ។ បច្ចុប្បន្នប្រជាជាតិខ្មែរកំពុងតែរស់នៅដីសែនវេទនាឈឺចាប់នៅក្នុងចង្កូមបិសាចនៃជំរៅមហាគ្រោះត្រូវបានបង្កើតឡើងដោយរដ្ឋាភិបាលអាយ៉ងក្រោមខ្សែញាក់នៃរដ្ឋាភិបាលក្រុងហាណូយនោះ **តើក្នុងនាមជាប្រជាជាតិខ្មែរទាំងអស់គ្នាគួរតែរកច្រកចេញពីក្រញាំបិសាចយួនកំមុយនីស្តដោយរបៀបណា?**

## ១. អង្គការឧក្រិដ្ឋជនសំងាត់បាក់គី (Secret Criminal Organization of Backy):



លោក **ហុក ឡុងឌី** គឺជាអគ្គស្នងការនគរបាលជាតិ ជាឧត្ដមសេនីយឯកផ្កាយមាស៤ ជាប្រធានអង្គការឧក្រិដ្ឋជនសំងាត់បាក់គី (១៩៩១-១៩៩៧) ជាអ្នកចូលរួមធ្វើរដ្ឋប្រហារថ្ងៃ ៥-៦ កក្កដា ១៩៩៧ ដោយបានសំលាប់ឥស្សរះជនជាច្រើនរបស់គណះបក្សហ្វ៊ុនស៊ិនប៉ិច ជាអ្នកចូលរួមស្ថាបនាអង្គការឧក្រិដ្ឋជនសំងាត់ អេស.អូ.វ៉ាយ ជាមួយ ហ៊ុន-សែន និង ជា-ស៊ីម (១៩៩៧-២០០៣) ជាប្រធានអង្គការឧក្រិដ្ឋជនសំងាត់អាវខ្មៅឈុតខ្មៅ ជាមួយ ហ៊ុន-សែន (១៩៩៧-២០០៨) គឺជាវិរៈបុរសរបស់យួនដែលបានសំរេចស្នាដៃដឹមហិមារនៅក្នុងបេសកកម្មរំលាយជាតិសាសន៍ខ្មែររបស់ក្រុងហាណូយបន្ទាប់ពីយួនកំមុយនីស្តិ៍ឈ្លានពានលេបត្របាក់ទឹកដីខ្មែររួចស្រេចហើយ។ អង្គការឧក្រិដ្ឋជនសំងាត់បាក់គីគឺត្រូវបានបង្កើតឡើងដោយរដ្ឋាភិបាលក្រុងហាណូយ នៅក្នុងឆ្នាំ១៩៩១ ដើម្បីធ្វើភេរវកម្ម បង្កើតអសន្តិសុខ ចលាចលសង្គម អស្ថេរភាពនៅក្នុងសង្គមខ្មែរ និងរកចំណូលអោយគណៈបក្សប្រជាជនកម្ពុជា ព្រមទាំងបំរើផលប្រយោជន៏នយោបាយនៃរដ្ឋាភិបាលអាយ៉ងយួន (CPP) ដើម្បីពន្លឺនល្បឿនលេបទឹកដីខ្មែរយ៉ាងឆាប់បំផុត។ អង្គការឧក្រិដ្ឋជនសំងាត់បាក់គីនេះត្រូវបានប្រើប្រាស់ និងបញ្ជាដោយលោក ហុង ឡង់ឌី រហ័សនាមថា កាពីរ (K-2 ជាឧត្ដមសេនីយផ្កាយមាស៤ ជាអគ្គស្នងការនគរបាលជាតិនៅក្នុងប្រទេសកម្ពុជា និងជាឧត្តមសេនីយផ្កាយទោនៅប្រទេសវៀតណាម មានឈ្មោះថា ខៀវវ៉ាន់ឌី នេះបើតាមប្រភពលោកអ៊ុំ នូសារុន CFF នៅខេត្តស្វាយរៀង ដែលបានបញ្ជាក់ប្រាប់ខ្ញុំនៅបរិវេនខាងក្រោយអាគារសេ C នៃគុកព្រៃសនាឆ្នាំ ២០០៧ ហើយបើតាមលោក វេង វុទ្ធី បានបញ្ជាក់ថាឪចិញ្ចឹមរបស់លោក ហុក-ឡង់ឌី ឈ្មោះតាវ៉ា នៅបាវិតនាខេត្តស្វាយរៀង)។ បន្ទាប់ពីកិច្ចព្រមព្រៀងក្រុងប៉ារីសនាថ្ងៃទី ២៣ ខែតុលា ឆ្នាំ១៩៩១ រដ្ឋាភិបាលក្រុងហាយណូយមានការព្រួយបារម្ភខ្លាចបាត់

អំណាចត្រួតត្រាលើកម្ពុជា ក៏បានកែឈ្មោះប្រមូលអតីតយុទ្ធជនវៀតណាម និងពួកចោរជើងចាស់ និងឈ្មួញជួញដូរមនុស្សជួញដូរគ្រឿងញៀនវៀតណាម រួមទាំងក្រុមជនអន្ធពាលវៀតណាមផងដែរ ត្រូវបានគេបញ្ចូលជាសមាជិកអង្គការឧក្រិដ្ឋជនសំងាត់បាក់គី ពួកសមាជិកអង្គការឧក្រិដ្ឋជនសំងាត់បាក់គី មួយចំនួនធំ គឺបានចេញប្រភពមកពីអតីតយុទ្ធជនវៀតណាមដែលជាពួកចារជនផ្នែកខាងទាហ៊ាននៃជួរកងទ័ពវៀតណាមដែលពូកែខាងស៊ើបការណ៏យកពត៏មាន និងឃោសនាបំផុសបំផុលផ្នែកនយោបាយ និងធ្លាប់រៀនសូត្រខាងវិជ្ជាដាកកុងនិនច្វារ ដែលមានប្រសិទ្ធិភាពខ្ពស់ក្នុងក្រុមនេះ។ សមាជិកអង្គការឧក្រិដ្ឋជនសំងាត់បាក់គីត្រូវបានបញ្ជូនទៅប្រទេសកម្ពុជាសំរាប់ជួយជ្រោងជ្រែងលោក ហុកឡង់ឌី នៅក្នុងការសំលាប់ផ្តាច់ពូជជនជាតិខ្មែរបែបរបៀបថ្មីមានន័យថាសំលាប់ខុសពីលោកអ៊ីត្លែ និងលោកប៉ុលពត គឺយកលេសប្លន់ជីវិតបងធំបងតូចសំលាប់រាស្ត្រខ្មែរជាចំហរ សំលាប់បន្តិច១ សំលាប់តក់១ តែរយៈយូរគឺសំលាប់បានច្រើន អន្តរជាតិមិនដឹង មិនសង្ស័យ ហើយចាប់ភស្តុតាងមិនបាន ថ្កោលទោសក៏មិនបាន។ លោក ហុកឡង់ឌី ប្រើប្រាស់អង្គការឧក្រិដ្ឋជនសំងាត់បាក់គីនេះដើម្បីសំលាប់ពួកអ្នកស្នេហាជាតិខ្មែរ ឥស្សរៈជនខ្មែរ វរៈជនខ្មែរ វីរះជនខ្មែរ ពួកគណះបក្សប្រឆាំងនិងរាស្ត្រសាមញ្ញ និងបង្ករអសន្តិសុខ អស្ថេរភាពសង្គមវឹកវរចលាចល ដើម្បីងាយស្រួលប្រើអំណាចផ្តាច់ការសំលាប់ប្រជារាស្ត្រខ្មែរ បង្កើនអំណាចរបស់គណៈបក្សប្រជាជន ជាពិសេសដើម្បីពង្រឹងកំលាំងអំណាចផ្តាច់មុខរបស់លោក ហុកឡង់ឌី នៅក្នុងប្រទេសកម្ពុជា។ ក្នុងការបំភាន់ភ្នែកអន្តរជាតិមិនអោយមើលឃើញ ឬយល់ដឹងនៅអាថ៌កំបាំងឧក្រិដ្ឋកម្មសំងាត់ ឃាតកម្មសំងាត់របស់ខ្លួន ប្រព្រឹត្តិលើប្រជារាស្ត្រខ្មែរស្លូតត្រង់លោក ហុក ឡង់ឌី បានប្រើប្រាស់អង្គការឧក្រិដ្ឋជនសំងាត់បាក់គីដូចស្រដៀងគ្នាទៅនឹង អង្គការអាល់ខៃដារបស់លោកអូសាម៉ា បិនឡាឌិន ប៉ុន្តែពាក់ផ្លាកនយោបាយទៅលើគណៈបក្សដៈទៃ១ ជាពិសេសលើពួកខ្មែរក្រហម ដូចករណី ដាក់បន្ទុះគ្រាប់បែកដៃចងកៅស៊ូទុកក្នុងកំប៉ុងប្រេកកាតដាក់បង្កប់តាមហាងកាហ្វេយួននាឆ្នាំ ១៩៩២ ១៩៩៣,.,.,.,ភេរវកម្ម បាញ់ប្រហារ ឃាតកម្មចំឡែក១ជាដើម។

**គោលបំណង និង គោលដៅនៃអង្គការឧក្រិដ្ឋជនសំងាត់បាក់គី**

**(១)-ស៊ើបការណ៍ យកពត៌មាន ប្រមូលពត៌មាន តាមដានយកការណ៍** អំពីពួកគណៈបក្សប្រឆាំង នឹងពួកវីរៈជន វរៈជន ឥស្សរៈជនខ្មែរ ពួកបញ្ញាជនខ្មែរ និងពួកអ្នកជាតិនិយមខ្មែរ ព្រមទាំងស៊ើបអង្កេតរាល់សកម្មភាពជីវិតផ្ទាល់ខ្លួនរបស់ប្រជាជនខ្មែរ ជីវភាពរបស់ប្រជាជនខ្មែរដែលមានទំនាក់ទំនងប្រក្រតី ឬក៏ខុសប្រក្រតីជាមួយបណ្តារពួកមន្ត្រី ថ្នាក់ដឹកនាំរដ្ឋាភិបាលអាយ៉ង ពួកបក្សប្រឆាំង និងតាមដានផងដែរនៅរាល់សកម្មភាពគ្រប់យ៉ាងរបស់ពួកមន្ត្រីរដ្ឋាភិបាលអាយ៉ងគ្រប់ស្រទាប់ចាប់តាំងពីពួកមន្ត្រីទាហ៊ានយោធា មន្ត្រីនគរបាល មន្ត្រីស៊ីវិល ប្រធានភូមិ ប្រធានឃុំ ចៅហ្វាយស្រុក អភិបាលខណ្ឌ អភិបាលខេត្ត រហូតដល់រដ្ឋមន្ត្រី នាយករដ្ឋមន្ត្រី សភាតំណាងរាស្ត្រ មន្ត្រីជាន់ទាបជាន់ខ្ពស់ក្នុងជួរតុលាការ ព្រមទាំងធ្វើជាទាហ៊ានចារកិច្ច ប៉ូលីសស៊ើបការណ៍របស់ពួករដ្ឋាភិបាលអាយ៉ងផងដែរ ហើយប្រសិនបើលទ្ធផលពត៌មានសបង្ហាញថា ពួកទាំងនោះខុសប្រក្រតី វេចវេរ កលចង់ក្បត់បក្ស ឬ ជាជនក្បត់បក្ស និងរាល់ពួកដែលដើរខុសពីបន្ទាត់គោលនយោបាយយួនកុំមុយនីស្ត៍ ពួកអស់ទាំងនេះ ត្រូវបានក្រុមអង្គការឧក្រិដ្ឋជនសំងាត់បាក់គី នាំបញ្ជូនឈ្មោះទៅកាន់លោក ហុក ឡង់ឌី ឬទៅថ្នាក់លើជាអ្នកសំរេច ថាតើត្រូវចាប់ខ្លួនដាក់គុក ត្រូវកសាងអប់រំកែបែប្រ ឬក៏ត្រូវសំលាប់ចោល (សូមបញ្ជាក់ថា ពាក្យថ្នាក់លើ គឺមានន័យថារដ្ឋាភិបាលក្រុងហាណូយយួនកុំមុយនីស្ត៍នេះឯង ហើយទំលាប់វិន័យរបស់ពួកគេគឺថា បើគ្មានបញ្ជារពីថ្នាក់លើទេ គឺមិនហ៊ានធ្វើ មិនហ៊ានសំលាប់ឬចាប់ចងអ្វីឡើយ =បើមានបញ្ជាពីថ្នាក់លើ ពួកគេធ្វើ តែបើគ្មានបញ្ជាគឺពួកគេមិនធ្វើ)។

**(២)-ផ្សព្វផ្សាយពត៌មាន បំភ្លៃពត៌មាន បំភ្លើសពត៌មាន និងសាបព្រួសពត៌មាន**បំបាក់ស្មារតីប្រជារាស្ត្រខ្មែរគ្រប់ស្រទាប់វណ្ណៈអោយភ័យខ្លាចបាក់ស្បាតមិនហ៊ានងើបឡើងតតាំងប្រឆាំងតវ៉ា ឬនិយាយស្តីអំពីគ្រប់រាល់អំពើពុករលួយលក់ជាតិទឹកដីរបស់រដ្ឋាភិបាលអាយ៉ងយួន រាល់គ្រប់ទង្វើរខុសប្រក្រតី និងរាល់សកម្មភាពទន្ទ្រានវាតទិត្របាក់លេបទឹកដីព្រំដែនខ្មែរ ព្រំប្រទល់ស៊ីម៉ាខ្មែរ-យួន ឬសកម្មភាពសំលាប់ភ្នែកស្រស់ឡើយផ្ទុយទៅវិញប្រជារាស្ត្រខ្មែរគ្រប់ស្រទាប់វណ្ណៈបែរជាភ័យខ្លាចមហាគ្រោះថ្នាក់ចំពោះមុខដែលកើតមានប្រចាំថ្ងៃទៅវិញ ហើយព្យាយាមសម្ងំសុខ ដោយសង្ឃឹមថា ដាំដើមគរជាប្រភពនៃភាពសុខក្សេមក្សាន្តគ្រប់យ៉ាង

ប៉ុន្តែធាតុពិតគឺផ្ទុយស្រឡះពីអ្វីដែលប្រជារាស្ត្រខ្មែររំពឹងទុក ព្រោះថាពួកកុំមុយនីស្ដិ៍តែងតែប្រកាន់ខ្ជាប់នៅគោលការណ៍ដែលថា "**បញ្ជាគឺបញ្ជា ផែនការគឺផែនការ** "។ រាល់គ្រប់ផែនការងងឹត ល្បិចខ្មៅក្រខ្វក់ទាំងឡាយរបស់រដ្ឋាភិបាលក្រុងហាណូយត្រូវបានក្រុមពួកក្រុមអង្គការឧក្រិដ្ឋជន សំងាត់បាក់គីយកទៅផ្សព្វផ្សាយសាបព្រួសនៅក្នុងសង្គមខ្មែរដើម្បីញុះញង់បំបែកបំបាក់ប្រជារាស្ត្រខ្មែរ ប្រជាជាតិខ្មែរអោយបែកបាក់គ្នាជាបំណែក១គ្រប់ស្រទាប់វណ្ណៈ។ ពួកបាក់គីក្រៅពីលួចឆក់ប្លន់ជីវិត និងសំលាប់ ឃាតកម្មនយោបាយស៊ីគេនោះពួកវាពូកែ និងប្រសព្វផងដែរខាងឃោសនាបញ្ចុះបញ្ចូលផ្លាស់ប្តូរទឹកចិត្តប្រជាករខ្មែរតាមជនបទស្រែចំការ ឬតាមក្រុមប្រជាជនទីក្រុងដែលពុំមានការរៀនសូត្រចេះដឹង អោយទទួលយកអ្វីដែលពួកវានិយាយល្បួងលួងលោម បញ្ឆោតបញ្ឆេរលើកជើងរាស្ត្រខ្មែរល្ងង់ខ្លៅអោយជឿពាក្យផ្អែមល្ហែមរបស់ពួកវា ហើយយល់ព្រមផ្តល់ពត៌មាន រាយការណ៍អោយពួកវាដោយមិនដឹងខ្លួន ព្រោះពួកក្រុមអង្គការឧក្រិដ្ឋជនសំងាត់បាក់គីនេះគឺពូកែខាងប្រើមនុស្សទៅតាមទីកន្លែង តាមស្ថានភាពជាក់ស្តែង បើទីតាំងគោលដៅជាមនុស្សមានសំបុរស្បែកខ្មៅ ពួកវាចាត់មនុស្សដែលមានស្បែកសំបុរខ្មៅទៅទីនោះដើម្បីស្ទាបស្ទង់ស្ថានភាពចិត្តសាស្ត្រ សិក្សាភូមិសាស្ត្រជាក់ប្រាកដ មុនបើកយុទ្ធនាការលើទីតាំងគោលដៅនោះ ហើយពួកមនុស្សដែលស៊ីនុយពួកវានោះ

ក្លាយខ្លួនជាអ្នកផ្តល់ពត៌មានរាយការណ៍អោយពួកក្រុមអង្គការឧក្រិដ្ឋជនសំងាត់បាក់គី ពេលចូលអន្ទាក់ ក៏ដកខ្លួនពុំរួច ហើយលង់កាន់តែជ្រៅ ទីបំផុតស្ថិតក្នុងការគំរៀមកំហែងរបស់ពួកវា ប្រៀបបីដូចជាសមាជិករបស់ក្រុមអង្គការឧក្រិដ្ឋជនសំងាត់បាក់គីដែរ គ្រាន់តែបណ្តោះអាសន្ន មិនអចិន្ត្រៃយ៍ទេ ហើយការយល់ដឹងពីពួកបាក់គីគឺតិចតួចបំផុត ព្រោះពួកនេះបន្សល់ដានតិចណាស់មុនផ្លាស់ប្តូរទៅចាប់គោលដៅថ្មីនោះ។ ក្រៅពីនេះ ពួកវាតែងតែដើរផ្សាយបំផុសនៅពត៌មានប្រឌិតក្លែងក្លាយ បំផ្លែងពត៌មាន បំភ្លៃពត៌មានផ្លាស់ប្តូររឿងរ៉ាវហេតុការណ៍ពីអាក្រក់ទៅល្អ ពីល្អទៅអាក្រក់ ពីពិតទៅមិនពិត ពីមិនពិតទៅពិត ដោយបង្វែរសាច់រឿងតាមគោលដៅដែលថ្នាក់លើចង់បាន ដោយមានការសហការពីរដ្ឋអំណាចមូលដ្ឋានជួយជ្រោងជ្រែងសព្វបែបយ៉ាងដើម្បីសំរេចបញ្ជារថ្នាក់លើអោយខាងតែបាន ដូចជារឿងឃាតកម្មនយោបាយ ពួកវាប្រែទៅជា

រឿងឈ្លោះគ្នា រឿងគំនុំផ្ទាល់ខ្លួន ឬរឿងគ្រួសារទំនាស់ផ្ទៃក្នុងទៅវិញ ចំណែករឿងចោរកម្មលួចឆក់ប្លន់នោះ ពួកវាបែរជាដើរតួជាអ្នកគំរាមកំហែងជីកសួររកភស្តុតាង តឹកតាង "ចេះតែថាហើយ ប្រយត្ន័អត់ភស្តុតាងច្បាស់លាស់ គេប្តឹងបកវិញ,,,,,,កុំនាំរឿងដាក់ខ្លួន,,,,,,កុំយកជ័រភ្ញៅបៀតក្បៀក,,,,,,ប្រយត្ន័ងាប់ដូចខ្មោចឆ្កែរ,,,,,,បើមិនអញ្ជឹងទេ ពួកវាប្រែរូបទៅជាសាក្សីក្នុងសាច់រឿងនោះតែម្តង ដូចជាករណីរឿងឃាតកម្ម ឬជារឿងគ្រោះថ្នាក់ផ្សេងៗនោះ ពួកសមាជិកក្រុមអង្គការឧក្រិដ្ឋជនសំងាត់បាក់គីបែរជាដើរតួថា ពួកវាបាននៅកន្លែងកើតហេតុនោះដែរ ពួកវាបានឃើញ,,,,,,,បានឮ,,,,,ថែមទាំងពន្យល់សាច់រឿងយ៉ាងក្បោះក្បាយទៀតផង ហើយធ្វើការផ្សព្វផ្សាយសព្វទីកន្លែងដោយមានប្រព័ន្ធឃោសនារបស់រដ្ឋាភិបាលមានវិទ្យុ សារពត៌មានកាសែត ទស្សនាវដ្ដី ទូរទស្សន៏ និងបណ្តាញឃោសនាផ្សេងៗទៀតចូលរួមផងដែរដើម្បីបង្វែរសាច់រឿងចំណែកកងកំលាំងប៉ូលិស ទាហ៊ាន កងរាជអាវុធហត្ថជួយបំភ្លឺក្នុងរឿងនេះ ហើយថែមទាំងគំរាមកំហែងនៅរាល់ជនណាដែលមិនជឿពួកគេបកស្រាយពន្យល់ ឬសំលាប់បំបិទមាត់នៅរាល់ជនណាដែលដឹងសាច់រឿងយ៉ាងជាក់ច្បាស់ប្រាកដ។ រីឯបើរឿងចោរកម្ម ប្លន់សំលាប់ ឬ ការសំលាប់យ៉ាងឃោរឃៅសាហាវព្រៃផ្សៃនោះ ពួកវាបែរជាបង្វែរទៅជារឿងផ្សេងទៅវិញ ពេលខ្លះជារឿងគំនុំ រឿងសងសឹក រឿងផិតក្បត់ រឿងសាហាយស្មន់,,,,,រឿងគ្រោះថ្នាក់ចរាចរ,,,,,,,រឿងយល់ស្រឡំ,,,,,រឿងទាស់សំដីគ្នា,,,,,ឬក៏ពួកវាផ្សាយថាចោរ ឃាតករ ចាប់បានហើយ ចោរឃាតករបាញ់ចោលហើយ កប់ចោលហើយ,,,,,។ល។ និង ។ល។ សរុបពួកក្រុមអង្គការឧក្រិដ្ឋជនសំងាត់បាក់គី និងកងកំលាំងរដ្ឋាភិបាលអាយ៉ង ហាក់បីដូចជាធ្វើរឿងតែមួយធ្វើកិច្ចការតែមួយយ៉ាងស៊ីសង្វាក់គ្នាដើម្បីបំរើឆន្ទះគោលបំណងរបស់ក្រុងហាណូយ ធ្វើអោយមានភាពស្របច្បាប់ជាអន្តរជាតិនៅរាល់បទឧក្រិដ្ឋដែលពួកគេប្រព្រឹត្តិ និងធ្វើអោយមានប្រតិមតិក្នុងខួរក្បាលរាស្ត្រខ្មែរទទួលយក ឬសង្ស័យនៅរាល់រឿងពិតទាំងឡាយទៅតាមបំណងដែលយួនចង់បាន គឺយល់ស្របជឿជាក់ទាំងបង្ខំចិត្តនៅរាល់គ្រប់ការបំផុសពត៏មានមិនពិត ការបំភ្លៃនិងបំផ្លែងពត៏មាន ការសាបព្រុសមនោគមវិជ្ជាក្បត់ជាតិដល់ប្រជារាស្ត្រខ្មែរ គំរាមកំហែង បំបាក់ស្មារតី ប្រជាពលរដ្ឋខ្មែរ អោយខ្លាចបាក់ស្បាតមិនហ៊ាន

ក្រោកឡើងប្រឆាំងពួកវា មិនហ៊ានមាននិន្នាការចូលរួមក្នុងបក្សប្រឆាំង ហើយភ័យខ្លាចមានគ្រោះថ្នាក់ដល់ខ្លួន និងជឿជាក់ងថា**"ជីវិតរស់ ស្លាប់ គឺអាស្រ័យបក្សប្រជាជន ជាអ្នកសំរេច"**ហើយមានតែបង្ខំចិត្តជឿ និងអនុវត្តន៏តាមបញ្ជាផែនការទិសដៅរបស់រដ្ឋាភិបាលអាយ៉ងយួន គឺគណះបក្សប្រជាជនកម្ពុជាទេ ព្រោះគ្មានជំរើស ហើយបើប្រជាជនខ្មែរទៅពឹងលើ ច្បាប់អន្តរជាតិ ឬក៏ អង្គការសហប្រជាជាតិ គឺប្រៀបបីដូចកាប់បំពង់រងចាំទឹកភ្លៀង ដូចរងចាំផ្កាយធ្លាក់ពីលើមេឃ ព្រោះកម្ពុជាមិនមែនអ៊ីរ៉ាក់ ឬអាហ្គានីស្ថានដែលសំបូរទៅដោយប្រេងកាតធនធានធម្មជាតិជាទីស្រេកឃ្លាន ត្រេកត្រអាលរបស់មហាអំណាចនោះទេ។

**(៣)-បង្កើនភាពច្របូកច្របល់ វឹកវរចលាចរ អស្ថេរភាព និងអសន្តិសុខនៅក្នុងសង្គមខ្មែរ** ហើយយកលេសនេះដើម្បីបង្ហាញឬទ្ធានុភាពនៃកងកំលាំងប្រដាប់អាវុធដ៏សាហ៊ាវឃោរឃៅដែលស្ទាត់ជំនាញខាងប្រហារ និងប្រល័យប្រជាជានខ្មែរស្លូតត្រង់ដែលគ្មានដឹងល្បិចឃាតកម្ម ឧក្រិដ្ឋកម្មកំបាំងមុខរបស់រដ្ឋាភិបាលអាយ៉ងយួនដែលតែងតែប្រើលេសឃាតកម្ម ភេរវកម្ម លួចឆក់ប្លន់ជីវិតសំលាប់ និងអស្ថេរភពសង្គម អសន្តិសុខសង្គម និងការពារសុវត្ថិភាពសង្គម ការពារសន្តិសុខសង្គម ការពារស្ថេរភាពសង្គម ដើម្បីបង្កើននៅភាពច្រួលច្របល់ភ័យខ្លាចដល់ប្រជារាស្ត្រខ្មែរ និង ដើម្បីបំភាន់ភ្នែកសហគមន៏អន្តរជាតិថា កងកំលាំងរដ្ឋាភិបាលពួកវាកំពុងតែប្រឹងប្រែងធ្វើការដើម្បីបុព្វហេតុសន្តិសុខជាតិតែប៉ុណ្ណោះ រួចហើយវាយកំលាំងតាមតំបន់គោលដៅដោយប្រើអំណាចផ្តាច់ការតាមអំពើចិត្តក្នុងការចាប់ចង ចាប់ដាក់គុក វាយដំសំលាប់ កាប់សំលាប់ បាញ់បោះបាញ់ប្រហារជនស្លូតត្រង់ខ្មែរតាមអំពើចិត្តហើយបិទផ្លាកថាបង្ក្រាបចោរ បង្ក្រាបក្មេងពាលបងតូចបងធំ ឬបង្ក្រាបក្មេងទំរើសទំយើរស្ទីគេនោះ ប៉ុន្តែធាតុពិតគឺរដ្ឋាភិបាលអាយ៉ងប្រើល្បិចប្រើលេសនេះលេសនោះហើយប្រើប្រាស់ពួកក្រុមអង្គការឧក្រិដ្ឋជន សំងាត់បាក់គី និងកងកំលាំងប្រដាប់អាវុធរបស់ពួកវា ដើម្បីបំរើផលប្រយោជន៏រដ្ឋាភិបាលក្រុងហាណូយ និងអនុវត្តន៏តាមបញ្ជាសំងាត់របស់ចៅហ្វាយយួនតែប៉ុណ្ណោះ ហើយ**ពួកវាចាត់ទុកសហគមន៏អន្តរជាតិ អង្គការសហប្រជាជាតិ និងអង្គការផ្សេងៗ គ្រាន់តែជាទីងមោងចាំចាបមិនដឹងខ្យល់អ្វី ក្រៅពីផ្តល់ជំនួយ** និងទទួលផលពីជំនួយនោះវិញ តាមរយះការដោះដូរនឹងអ្វីផ្សេងទៀត

ដែលស្មានមិនដល់ដូចជា ធនធានរ៉ែ ធនធានធម្មជាតិ សិទ្ធិវិនិយោគ ប្រាក់កំរៃជើងសារ ឬលុយសំណូក ដែលរដ្ឋាភិបាលអាយ៉ងអោយ ដើម្បីបិទភ្នែកធ្វើមិនដឹងមិនឮលើគំនរឈាម និងទឹកភ្នែករបស់ប្រជារាស្ត្រខ្មែរ (សហគមន៍អន្តរជាតិ អង្គការសហប្រជាជាតិ និងអង្គការផ្សេងៗជាស្ថាប័ន ប៉ុន្តែមនុស្សដែលបំរើអោយស្ថាប័នទាំងនោះគឺគ្រាន់តែជាបុគ្គលមនុស្ស ដែលទទួលផលប្រយោជន៍យ៉ាងមហិមារ គ្រាន់តែធ្វើមិនដឹងមិនឮនៅរាល់ហេតុការណ៍ពិតកើតមានក្នុងប្រទេសកម្ពុជាតែប៉ុណ្ណោះ ខ្ញុំសុំទោស នេះជាឧទាហរណ៍ទេណា សុំអស់លោកអង្គការកុំប្រកាន់ខ្ញុំអី ដូចជាករណីលោក វ៉ាង-គីមូន ទៅទស្សនកិច្ចនៅកម្ពុជា ប្រសិនបើអា ហ៊ុន-សែន អោយ ១000 លានដុល្លាសហរដ្ឋអាមេរិក ហើយគ្រាន់តែធ្វើមិនដឹងមិនឮរឿងឧក្រិដ្ឋកម្មឃាតកម្ម ភេរវកម្មបោកគ្រាប់បែក និងការរំលោភសិទ្ធមនុស្សរបស់អា ហ៊ុន-សែន ហើយយកលេសថាសំណុំរឿងពិភពលោកច្រើនពេករវល់ជាប់ តើលោក វ៉ាង-គីមូន គិតយ៉ាងម៉េចដែរ ព្រោះខ្ញុំឆ្ងល់ណាស់ អា ហ៊ុន-សែន សំលាប់ជនជាតិខ្មែររាប់មិនអស់ រួមទាំងភេរវកម្មបោកគ្រាប់បែកមុខរដ្ឋសភាថ្ងៃទី ៣0 ខែមិនា ឆ្នាំ ១៩៩៧ ទៀតផងប៉ុន្តែអង្គការសហប្រជាជាតិមិនចាប់ ហ៊ុន-សែន កាត់ទោស បែរជារួមដៃជាមួយអា ហ៊ុន-សែន បង្កើតតុលាការសាលាក្តីខ្មែរ លាងកំហុសអោយយួនឈ្លានពានខ្មែរទៅវិញ មិនដឹងថាហេតុអ្វីបានទៅជាយ៉ាងនេះ? រួមទាំងសហរដ្ឋអាមេរិកទៀតដែលបានដឹងរឿងអា ហ៊ុន-សែន ច្បាស់ តែបែរជាសម្ងំអោយអា ហ៊ុន-សែន បន្តអំពើឧក្រិដ្ឋកម្មថែមទៀត តើសហរដ្ឋអាមេរិកបានទទួលផលប្រយោជន៍អ្វីពីអា ហ៊ុន-សែន ហើយពាក្យថា **លិទ្ធិប្រជាធិបតេយ្យ តំលៃមនុស្សជាតិ និងសិទ្ធិមនុស្សនៅឯណា**? គ្រាន់តែសួរលេងៗទេ បើយល់ថាប៉ះពាល់ដល់ផលប្រយោជន៍អស់លោក សូមមេត្តាប្រហារជីវិតខ្ញុំថែមម្នាក់ទៀតក៏មិនអ៊ីដែរ ក៏គ្រាន់បើជាងខ្ញុំស្លាប់នៅក្រោមដៃអា ហ៊ុន-សែន ដែរ) ។

**(៤)-រកលុយ រកចំណូលអោយគណៈបក្សប្រជាជនកម្ពុជា** និងអោយលោក ហុក ឡង់ឌី ដូចដែលជនរួមជាតិខ្មែរបានជ្រួតជ្រាបហើយថា "រដ្ឋាភិបាលអាយ៉ងយួនកុំមុយនីស្តិ៍បានក្តោបអំណាចនយោបាយទាំងប្រាំក្នុងដៃគឺ អំណាចនិតិបញ្ញត្តិ អំណាចនិតិប្រតិបត្តិ អំណាចតុលាការ អំណាចប្រព័ន្ធឃោសនា និងអំណាច

ម៉ាហ្វីយ៉ា ( ជាអំណាចប្រើក្នុងផ្លូវងងឹតដើម្បីបំភាន់ភ្នែកមហាអំណាច សហគមន៍អន្តរជាតិតែប៉ុណ្ណោះ អំណាច ម៉ាហ្វីយ៉ា មានដូចជាក្រុមបងធំបងតូចក្រុមចោរ លួច ចោរប្លន់ ចោរចាប់ជំរិត ពួកឆបោក ពួករកស៊ីគ្រឿង ញៀន ពួករកស៊ីជួញដូរអាវុធ ពួកមេបនរកស៊ី ជួញដូរមនុស្ស និងពួកឃាតករស៊ីឈ្នួល ព្រមទាំងពួក ភេរវករ សំរាប់ធ្វើភេរវកម្ម និងធ្វើឃាតកម្មនយោបាយ តែប៉ុណ្ណោះ) និងកាន់អំណាចសេដ្ឋកិច្ចប្រាំក្នុងដៃ ទៀតគឺ ចំណូលដែលបានមកពីពន្ធដារពន្ធគយ ចំណូលបានមកពីជំនួយបរទេស ចំណូលដែលបានមកពី កំម្ចីបរទេស ចំណូលដែលបានមកពីការលក់ដូរធនធានធម្មជាតិខ្មែរមានដូចជាព្រៃឈើដីភ្នំស្ទឹងបឹងបួរសមុទ្រ រ៉ែ ជីវចំរុះ,,,,,,,, ។ល ។ និង ។ល ។,,,,,,, និង ចំណូលដែលបានមកអំពីសេដ្ឋម៉ាហ្វីយ៉ា ( លុយដែលបានមកអំពី អំពើពុករលួយលួចលុយចំណូលជាតិ លួចកេងកឹបលុយកំម្ចីបរទេស លួចលុយជំនួយបរទេសធ្វើជាលុយរបស់ ខ្លួន និងរបស់បក្សខ្លួន លុយចំណូលដែលបានមកអំពីពួកក្រុមពួកបងធំបងតូច ក្រុមពួកចោរលួចចោរប្លន់ ក្រុមចោរចាប់ជំរិត ពួកឆបោក ការរកស៊ីគ្រឿងញៀន រកស៊ីជួញដូរអាវុធ រកស៊ី ជួញដូរមនុស្ស និង ឃាតកម្មស៊ីឈ្នួល ការចងការប្រាក់ ការរកស៊ីកាងបាញ់បោះ,,,,,,,,,,,មុខរបរទាំងអស់នេះ មានលក្ខណៈជា ឯកជនត្រូវបានកងកំលាំងប្រដាប់អាវុធរបស់រដ្ឋាភិបាលជាអ្នកការពារសំរួលអោយមានភាពរលូនដោយយក កំរៃ និងឈ្នួលការពារ ហើយជាជាលក្ខណៈរដ្ឋអំណាចដែលគណះបក្សប្រជាជនខ្លួនឯងជាអ្នករកស៊ីផ្ទាល់ជា ទ្រង់ទ្រាយធំ) គណះប្រជាជនជាអ្នករៀបចំឆាកល្ខោនអោយមានលក្ខណៈជាបណ្តាញខ្សែសង្វាក់ ជាអង្គការ ចាត់តាំងមានរចនាសម្ពន្ធ័ច្បាស់លាស់ក្នុងបណ្តាញចោរលួចចោរប្លន់ ចោរចាប់ជំរិត ក្រុមឃាតករស៊ីឈ្នួល និង ក្រុមរកស៊ីជួញដូរគ្រឿងញៀន ជួញដូរមនុស្ស,,,,,, ។ល ។ និង ។ល ។,,,,,នៃអង្គការឧក្រិដ្ឋជនសំងាត់ បាក់គីដែលស្ថិតនៅក្នុងការគ្រប់គ្រងផ្ទាល់របស់លោក ហុក-ឡង់ឌី និងក្រោមការជួយជ្រោមជ្រែងផងដែរ ពីកង កំលាំងប្រដាប់អាវុធរបស់រដ្ឋាភិបាលអាយ៉ង ។ ពួកអង្គការឧក្រិដ្ឋជនសំងាត់បាក់គីដែលដើរតួនាទីជា អង្គរក្សរបស់ លោក ហុក-ឡង់ឌី និងជាក្រុមពួកអន្តរពាល ជាឃាតករ ជាកងកំលាំងប្រដាប់អាវុធ និងជា ចារជនពិសេសរបស់យួនផងដែរនោះ លើសពីនេះទៅទៀត ពួកក្រុមអង្គការឧក្រិដ្ឋជនសំងាត់បាក់គីដើរ

តួនាទីជាអ្នករកចំណូលតាមរយៈការរកស៊ីប្លន់ជីវិតលួចឆក់ ឃាតកម្មស៊ីឈ្នួល និងកាងទីតាំងរកស៊ី ធ្វើអោយលុយចំណូល បានហូរចូលយ៉ាងក្រាស់ក្រៃទៀតផង ហើយបើតាមពួកអ្នកដែលធ្លាប់បានចេញចូលផ្ទះលោក ហុក-ឡង់ឌី ជិតប៊ុរីកីឡាបានអោយដឹងថា ចាប់ពីពាក់កណ្ដាលខែរហូតដល់ចុងខែ លុយចំណូលរបស់លោក ហុក-ឡង់ឌី ត្រូវបានយកមកចាក់គរពេញបន្ទប់ដែលប្រពន្ធកូនគាត់មិនដែលរវីរវល់ទៅរាប់លុយនោះទេ គ្រាន់តែចាត់ពួកអ្នកចូលបន្ទប់រាប់លុយ និងរៀបលុយតាមរបៀប ដុំដោយដុំ វាយដោយវាយ ដុល្លាដោយដុល្លា លុយរៀលដោយរៀល(Source$^{C1}$),,,,,។ល។ និង ។ល។ អង្គការឧក្រិដ្ឋជនសំងាត់បាក់គីនេះរកចំណូលបានយ៉ាងច្រើនក្រាស់ក្រៃល បន្ថែមលើជំនួយពន្ធដារពន្ធគយ ព្រោះថាកាលពីគ្រានោះ មិនទាន់មានជំនួយបរទេស ឬក៏មានកម្ចីបរទេសដែលប្រភពចំណូលយ៉ាសន្ធឹកសន្ធាប់ដូចក្រោយពេលនៃការបោះឆ្នោតឆ្នាំ ១៩៩៣ រហូតមកដល់បច្ចុប្បន្នទេហើយកំលាំងឃាតកអាថ៌កំបាំងក៏មិនខ្លាំងក្លាដូចបច្ចុប្បន្ននេះដែរ ដោយសារហេតុនេះហើយ ទើបសព្វថ្ងៃនេះ **ទោះបីគណៈបក្សប្រជាជនកម្ពុជាបានស្ថាបនា និងក្តោបក្តាប់គ្រប់គ្រងក្បាលម៉ាស៊ីនគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតនៅប្រទេសកម្ពុជាយ៉ាងណែននៅក្នុងដៃរបស់ពួកវាក៏ដោយ ក៏ពួកវាបង្ខំចិត្តផ្តល់កៅអីខ្លះអោយទៅលោក សម-រង្សី និង លោក គឹម-សុខា ដើម្បីអោយកាន់ក្តអោយគណៈបក្សប្រជាជននោម ព្រោះពួកវាអាចទាញយកចំណូលយ៉ាងសន្ធឹកសន្ធាប់ពីជំនួយបរទេស និងលុយកម្ចីបរទេស ដោយគ្រាន់តែពាក់ផ្លាកថា "មានគណៈបក្សប្រឆាំង គឺមានលិទ្ធិប្រជាធិបតេយ្យ"។**

**(៥)-ការពារជនជាតិយួន ជនបង្កប់យួន និងឈ្មួញទុច្ចរិតយួន**ដូចជាក្រុមពួករកស៊ីខុសច្បាប់ជួញដូរមនុស្ស គ្រឿងញៀន ជួញដូរអាវុធ និងទំនិញខុសច្បាប់ ទំនិញគេចពន្ធជាដើម,,,,,,។ល។ និង ។ល។ ជនជាតិយួនបានដើរតួនាទីជាជនបង្កប់យួន ត្រូវបានវាយសព្វទីកន្លែង មានន័យថាទីកន្លែងណាដែលមានប្រជាជនយួនរស់នៅ ទីកន្លែងនោះនឹងប្រែជាទីតាំងដែនរដ្ឋបាលយួនដែលមានអង្គការចាត់តាំងយួននៅទីនោះប្រៀបបីដូចជារដ្ឋាភិបាលទី២របស់យួន ដែលប្រជាជនយួនទាំងប្រុសទាំងស្រី ទាំងក្មេងទាំងចាស់សុទ្ធតែជាចារជនសុទ្ធតែជាសមាជិកនៃអង្គការចាត់តាំងរដ្ឋបាលយួនស្ថិតនៅក្រោមការការពារ និងជួយជ្រោមជ្រែងរបស់ពួក

សមាជិកសកម្មនៃអង្គការឧក្រិដ្ឋជនសំងាត់បាក់គី។ **ជនជាតិយួនរាប់លាននាក់ត្រូវបានបង្ហូរចូលស្រុកខ្មែរគឺប្រៀបបីដូចទឹកជ្រោះធ្លាក់ពីលើកំពូលភ្នំចុះមកក្រោម ចាប់ពីឆ្នាំ ១៩៧៩ រហូតមកដល់បច្ចុប្បន្ន ដើម្បីសំរេចនៅគោលនយោបាយលេបទឹកដីខ្មែរតាមរយះនយោបាយសមានកម្ម និងនយោបាយផុងសាច់ឈាម ប្រែជាតិខ្មែរអោយទៅជាយួនដូចស្រដៀងនឹងនយោបាយសហពន្ធ័ឥណ្ឌូចិនរបស់លោក ហូ-ជីមិញ ដែលយកកម្ពុជាឡាវ និងយួនក្លាយជាប្រទេសតែមួយឈ្មោះថា សហពន្ធ័ឥណ្ឌូចិន ស្ថិតក្រោមការត្រួតត្រាគ្រប់គ្រងផ្តាច់មុខរបស់យួន** ចំណែកឯសមាជិកខ្មែរ និងឡាវមានតួនាទីត្រឹមតែធ្វើអាយ៉ងយួន មិនចេះ មិនដឹងខ្យល់អ្វីទាំងអស់ គឺចេះតែប្រមូលលុយអោយយួនតាមរយះសេដ្ឋកិច្ច៥ និងសំលាប់តែរាស្រ្តខ្លួនឯងតែប៉ុណ្ណោះដើម្បីយកចិត្តយកថ្លើមចៅហ្វាយយួន ដូចជាករណីអា ហ៊ុន សែន បានធ្វើ និងកំពុងធ្វើលើប្រជារាស្រ្តខ្មែរចាប់តាំងពីឆ្នាំ ១៩៧៩ រហូតមកដល់បច្ចុប្បន្ននេះយ៉ាងជាក់ស្តែងស្រាប់។ ជនជាតិយួនដែលមករស់នៅស្រុកខ្មែរមិនត្រឹមតែដើរតួនាទីជាជនជាតិខ្មែរស្របច្បាប់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងធ្វើជាចៅហ្វាយរបស់ខ្មែរទៀតផង។

**(៦)-ផ្តល់ពត៏មានដល់ក្រុងហាណូយទាន់ហេតុការណ៏ និងបោសសំអាតភាពក្រខ្វក់ក្នុងកែវភ្នែកយួន ឬហៅថាខ្មាំងរបស់ក្រុងហាណូយ** (ក្រុងហាណូយចាត់ទុកជាខ្មាំង ជាឧបសគ្គដ៏ធំរបស់ពួកវានោះ គឺសំដៅទៅលើពួកបញ្ញាជនខ្មែរ ពួកអ្នកស្នេហាជាតិខ្មែរ ពួកអ្នកជាតិនិយមខ្មែរ វរៈជនខ្មែរ ឥស្សរៈជនខ្មែរ ប្រជាជាតិខ្មែរដែលគាំទ្របុព្វហេតុជាតិទឹកដី និងពួកអ្នកដែលមិនជឿលើមនោគមន៏វិជ្ជាបោកប្រាស់របស់យួន អ្នកដែលហ៊ានតវ៉ាប្រឆាំងនៅអ្វីដែលមិនសមហេតុផល ឬហ៊ានអះអាងនៅរាល់ការពិត ព្រមទាំងពួកមន្រ្តីអាយ៉ងយួនដែលរារែកចិត្តក្នុងការអនុត្តន៏ឧបាយកលសំងាត់របស់យួន) ចេញអោយអស់ពីរដ្ឋាភិបាលអាយ៉ងយួន។ ពួកអង្គការឧក្រិដ្ឋជនសំងាត់បាក់គីត្រូវបានដាក់ពង្រាយស្ទើរតែពាសពេញប្រទេសកម្ពុជាតាំងពីទីក្រុងរហូតដល់ជនបទ ទោះបីកំលាំងពួកនេះមិនច្រើនក៏ដោយ ក៏ពួកវាមានការជួយជ្រោងជ្រែងពីប្រជាជនយួន បណ្តាញសំងាត់យួន ជនអន្តោប្រវេសយួនដែលទើបតែមករស់នៅស្រុកខ្មែរនិយាយខ្មែរមិនទាន់ទាំងច្បាស់ផងឱ្យរឹងមាំទោះបីពួកគេមានសញ្ជាតិខ្មែរភ្លាមៗគ្រាន់តែចាប់ផ្តើមចូលស្រុកខ្មែរក៏ដោយ ហើយពួកគេដើរតួជាជំនួយដ៏

សំខាន់សំរាប់ជួយពួកឧក្រិដ្ឋជនសំងាត់បាក់គី ដើម្បីបោសសំអាតខ្មាំងផ្ទៃក្នុង និងផ្ទៃក្រៅ ដោយផ្តល់ពត៌មានសំខាន់ៗដោយបែងចែកប្រភេទពួកអ្នកដែលត្រូវបានគេបោសសំអាត ថាជាមនុស្សរបៀបណា ហើយត្រូវបានរៀបចំផែនការអោយស្លាប់របៀបណាទៅលើមនុស្សដែលត្រូវបានចាត់ទុកជាបន្លានៅក្នុងកែវភ្នែករបស់ក្រុងហាណូយ ឬក៏ជាឧបសគ្គរាំងស្ទះដល់ផែនការរបស់ពួកគេនោះ? ត្រូវសំលាប់ដោយរបៀបណាជាមួយរឿងហេតុទាំងឡាយអោយសមហេតុសមផលនោះ ឬក៏ត្រូវអោយជាប់គុកក្នុងករណីណាមួយដែលពួកអាយ៉ងរារែកចិត្តនៅក្នុងការអនុវត្តបញ្ជាថ្នាក់លើនោះ?

**(៧) -បញ្ចូលមនោគមន៏វិជ្ជាពាលាអាវ៉ាសែដល់ស្រទាប់យុវជនខ្មែរ** អោយស្វែងរកសប្បាយឆ្កួតនឹងស្រីស្រាល្បែងគ្រឿងញៀនរាំរែកផឹកស៊ីសប្បាយហ៊ឺហារ ស្វែងរកមធ្យោបាយរកលុយដោយមិនបានគិតខ្វល់រឿងអ្វីឡើយ និងបង្ហាត់បង្រៀននៅរបៀបប្រព្រឹត្តិបទឧក្រិដ្ឋដូចជាលួចឆក់ប្លន់ជីវិត វះកាបូបកាប៉ៅ បន្លំ ឆបោកឃាតកម្ម បាញ់បោះកាង ដើម្បីរកលុយបានយ៉ាងងាយស្រួល ដើម្បីបំពុលដល់សង្គខ្មែរអោយវង្វេងស្រវឹងគ្មានដឹងអ្វីទាំងអស់។ ប្រជាជានខ្មែរកាន់ព្រះពុទ្ធសាសនាស្លូតបូតសុភាពរាបសារ ទន់ភ្លន់មានសីលធម៏ដូចប្រជាជនថៃបច្ចុប្បន្ននេះអញ្ចឹង មិនដែលស្គាល់អ្វីដែលហៅថាបន្លំឆបោក លួចឆក់ ប្លន់ជីវិត បាញ់បោះកាងបងធំបងតូចអ្វីនោះទេ។ ដូច្នេះពួកក្រុមឧក្រិដ្ឋជនសំងាត់បាក់គីមានតួនាទីពិសេសបំផុតគឺនាំវប្បធម៏ពាលាអាវ៉ាសែមកបញ្ចូលក្នុងវប្បធម៏ខ្មែរដោយយកស្រីខូចយួនជាអ្នកបង្រៀនផ្ទាល់នៅរបៀបប្រើប្រាស់គ្រឿងញៀន បន្ទាប់ពីពួកគេចាប់ផ្តើមញៀនហើយ ពួកបាក់គីជាគ្រូទី២ ចាប់ផ្តើមបង្រៀននៅវិធីរកលុយងាយៗ បណ្តុះបណ្តាលនៅរបៀបយុទ្ធសាស្រ្តសាហាវព្រៃផ្សៃ ហើយពួកគេតែងតែដើរតួដូចបងធំ សំលាប់ប្រហារប្រជាជនធ្វើជាគំរូដើម្បីអោយយុវជនខ្មែរធ្វើតាម បើមានរឿងរ៉ាវ ពួកគេចេញមុខកាង ចេញមុខជួយធ្វើជាខ្នងដល់យុវជនខ្មែររហូតចេះចាំមេរៀនឆក់ប្លន់សំលាប់រកស៊ីខុសច្បាប់ដោយមិនចាំបាញ់សួរគ្រូអ្វីឡើយ តែពេលទទួលលុយគឺត្រូវតែដឹងគុណគ្រូ ដឹងគុណខ្នងបង្អែក ដោយមានវិធីស៊ីផឹកស្រីស្រាល្បែងថ្នាំញៀន និងមានស្រោមសំបុត្រហៅថា "**ទឹកចិត្តស្លួតស្មើង** "គឺជាលុយសគុណតបស្នងខ្នងបង្អែកមានបណ្តាសក្តិខ្ពស់ៗក្នុងរដ្ឋាភិបាលអាយ៉ងបន្ទាប់មកពួកគេសុំការណែនាំពីរបៀបធ្វើបទឧក្រិដ្ឋដែលមានប្រសិទ្ធិភាពជាងមុន និងទទួលបានប្រាក់កាសច្រើនសន្ធឹកជាងមុន និងសុំពឹងពាក់ការពារអោយបានច្រើនជាងមុនដើម្បីបង្កើនភាពកក់ក្តៅដល់ពួកគេ។

ក្រៅពីនេះ ពួកសមាជិកអង្គការឧក្រិដ្ឋជនសំងាត់បាក់គីមានភារៈពិសេសមួយទៀតគឺបណ្តុះនៅខួរក្បាលអប្រក្រតីដល់សង្គមខ្មែរ អោយប្រកាន់ខ្ជាប់នៅជំហរស្អប់ខ្ពើមគ្នា មិនទុកចិត្តគ្នា ខ្លាចរអាគ្នា និងចងគំនុំ សងសឹក ចងអាឃាតគ្នាទៅវិញទៅមក ជាពិសេសធ្វើអោយនិយាយតែពីរឿងអាក្រក់ពីគ្នា បង្អាប់បន្ទោក មួលបង្កាច់តែអំពីខ្មែរគ្នាឯង និងបញ្ចេញសាច់ដុំបាញ់កាប់ចាក់សំលាប់ប្រហារតែខ្មែររួមឈាមគ្នាឯងហើយ លើកតំកើនជាតិសាសន៍ដទៃ គោរពកោតខ្លាចជាតិសាសន៍ដទៃៗ សូម្បីតែនិយាយដើមពីក្រោយក៏តែមិនហ៊ានផង ជាពិសេសគឺ សាសន៍យួន សាសន៍ចិនហ្នឹងឯង តែផ្ទុយទៅវិញបែរជាឃើញជនជាតិខ្មែរខំប្រឹងអួងក្អេងក្អាងសំដែងនូវភាពសាហ៊ាវឃោរឃៅព្រៃផ្សៃដាក់ខ្មែរគ្នាឯងទៅវិញ។ ប្រជាជាតិខ្មែរស្ទើរតែលែងស្គាល់អ្វីទៅដែលហៅថាការពិត តថភាព ឧត្តមគតិជាតិ ព្រលឹងវិញ្ញាណស្នេហាជាតិ ឬក៏មនសិការជាតិ ស្មារតីសម្បជញ្ញៈជាតិស្អីគេនោះទេ។ សូមបញ្ជាក់ថាពួកក្រុមអង្គការឧក្រិដ្ឋជនសំងាត់បាក់គី ត្រូវបានគណៈបក្សប្រជាជនកម្ពុជាបំបិទចោល កំទេចចោលនៅឆ្នាំ ១៩៩៧ បន្ទាប់ពីរដ្ឋប្រហារថ្ងៃ៥-៦ កក្កដា ឆ្នាំ ១៩៩៧ ទំលាក់សម្តេចក្រុមព្រះនរោត្តមរណឫទ្ធិចេញពីតំណែង។ ការបំបិទចោល សំលាប់កំទេចចោលនៅពួកក្រុមអង្គការឧក្រិដ្ឋជនសំងាត់បាក់គី គឺដោយសារតែគណៈបក្សប្រជាជនបារម្ភខ្លាចបែករឿងសំងាត់ភេរវកម្មនយោបាយដែលពួកគេធ្វើចាប់ពីឆ្នាំ១៩៩៣ រហូតដល់១៩៩៧ ដូចជាការដាក់បន្ទុះគ្រាប់បែកចងកៅស៊ូជាបន្តបន្ទាប់ ឃាតកម្មនយោបាយ ការបាញ់ប្រហារប្រជាជនស្លូតត្រង់ ការប្លន់ជីវិតដែលធ្វើឡើងដោយរដ្ឋាភិបាលអាយ៉ងយួន,,,,,,,។ល។ និង ។ល។ លើសពីនេះទៅទៀតដោយសារពួកបាក់គីដឹងសាច់រឿងច្រើនខ្លាំងពេក ចេះក្បួនយុទ្ធសាស្រ្តល្បិចប្រព្រឹត្តិបទឧក្រិដ្ឋយ៉ាងស្ទាត់ជំនាញពេកដែលធ្វើអោយគណៈបក្សប្រជាជនពិបាកគ្រប់គ្រងពួកក្រុមអង្គការឧក្រិដ្ឋជនសំងាត់បាក់គី ហើយម្យ៉ាងវិញទៀតដោយសារតែលោកជាស៊ីម ហ៊ុនសែន លោក ហុក ឡង់ឌី និង លោក ជា សុផារ៉ា ជាចៅហ្វាយក្រុងភ្នំពេញនៅជំនាន់នោះបានរៀបចំបង្កើតស្ថាបនានៅអង្គការឧក្រិដ្ឋជនបែបថ្មីដែលហៅថាអង្គការ អេស អូ វ៉ាយ (S.O.Y) មានន័យថាអង្គការយុវជនពិសេស (Special Organization of Youths) ជំនួសអោយអង្គការឧក្រិដ្ឋជនសំងាត់បាក់គី ហើយគណៈបក្សប្រជាជនយកកងកំលាំងរដ្ឋាភិបាលរួមដៃគ្នាជាមួយពួកសមាជិកសកម្មរបស់អង្គការ អេស-អូ -វ៉ាយ (S.O.Y) សំលាប់ពួកក្រុមអង្គការឧក្រិដ្ឋជនសំងាត់បាក់គី ដើម្បីបំបិទតាង បំបិទកស្សិណសាក្សីទៅថ្ងៃក្រោយដើម្បីជៀសវាងយប់យូរសុបិន្តច្រើននាំវិបត្តិទៅអនាគត។

## ២.អង្គការយុវជនពិសេស អេស.អូ.វ៉ាយ (S.O.Y = Special Organization of Youths)



**ហ៊ុន-ណាល់** ជាចោរលួច រៀនថ្នាក់ទី៤ នៅវិទ្យាល័យព្រះសីហនុខេត្តកំពង់ចាម ពេលខ្វាក់ភ្នែកក៏រត់ចូលព្រៃ ប្តូរឈ្មោះ មកជា **ហ៊ុន-សែន** ឪពុកឈ្មោះ **ហ៊ុន-នៀង** ជាចោរលួចគោនៅស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម ម្តាយឈ្មោះ **ឌី-ប៊ុក** ជាអ្នកលក់នំអាកោរតាមភូមិ ។

រូប **ហ៊ុន-សែន** នាឆ្នាំ១៩៨៣ ឈ្មោះដើមគឺ **ហ៊ុន-ណាល់** ជាចោរលួចនៅក្រូចឆ្មារ ខេត្តកំពង់ចាម រហូតដល់អ្នកស្រុកតាមចាប់ រត់ដួលជុងមែកត្របែកខ្វាក់ភ្នែកម្ខាង រត់ចូលព្រៃម៉ាគី ដូរឈ្មោះជា **ហ៊ុន-សែន** ពូកែខាងប្រើ **ល្បិចឆ្កែព្រុស** ទើបយួនលើកបន្ទុបជា **រដ្ឋមន្ត្រីក្រសួងការបរទេស** នាពេលយួនឈ្លានពានត្រួតត្រាខ្មែរ ។ **កុំថាឡើយតែប្រវត្តិចោរខ្វាក់ភ្នែករបស់ខ្លួន** សូម្បីតែព្រឹត្តិការណ៍ប្រវត្តិសាស្ត្រពិត **យួនឈ្លានពានខ្មែរនាឆ្នាំ១៩៧៩ ក៏វាព្រុសហើយព្រុសទៀត កុហក់ ១000 ដង ឱ្យតែគេជឿ១ដង គឺជោគជ័យ** ព្រុសដល់តែជនមនុស្សអគតិមួយចំនួន និងប្រទេសមួយចំនួនជឿថា **យួនរំដោះខ្មែរឆ្នាំ១៩៧៩**។ ដើម្បីសំលាប់ជាតិខ្មែរបំផុតពូជសងសឹកនឹងភ្នែកខ្វាក់ម្ខាងរបស់ខ្លួន អានេះបានអនុវត្តិន៏ផែនការ **ក៥** របស់យួនដើម្បី **បំផ្លាញព្រៃប្រល័យខ្មែរ ក្នុងនាមឆ្កែរស្គាល់ចិត្តម្ចាស់** ។ ជាមេភេរវករបញ្ជាឱ្យបោកគ្រាប់បែកលើហ្វូងបាតុករថ្ងៃ៣០មិនា១៩៩៧នៅមុខរដ្ឋសភា មេរដ្ឋប្រហារថ្ងៃ៥-៦កក្កដា១៩៩៧ដើម្បីលុបសន្ធិសញ្ញាក្រុងប៉ារីស អនុវត្តសន្ធិសញ្ញាព្រំដែនយួនខ្មែរឆ្នាំ១៩៨២-១៩៨៣-១៩៨៥។ ជាមេស្ថាបនិកអង្គការឧក្រិដ្ឋជនសំងាត់អេស.អូ.វ៉ាយ ឆ្នាំ១៩៩៧ និងជាប្រធានផ្តាច់មុខនៃអង្គការឧក្រិដ្ឋជនសំងាត់អាវខ្មៅ បន្ទាប់ពីលោក ហុក-ឡង់ឌី ត្រូវបានសំលាប់បំបិទមាត់នៅខែវិច្ឆិការ ឆ្នាំ១៩៩៨ ។



**ជា-សុផារ៉ា** ជាចៅហ្វាយក្រុងភ្នំពេញនាសម័យបោកគ្រាប់បែកលើហ្វូងបាតុកម្មស៊ីវិលមុខរដ្ឋសភាឆ្នាំ១៩៩៧ បានអនុវត្តផែនការរដ្ឋប្រហារ ៥-៦ ខែកក្កដា១៩៩៧ ជាអ្នកផ្តួចផ្តើមគំនិតបង្កើតក្រុមបងតូចបងធំនៃអង្គការឧក្រិដ្ឋជនសំងាត់ អេស-អូ-វ៉ាយ ឆ្នាំ១៩៩៧ និងបានអនុវត្តបញ្ជាហ៊ុន-សែន រៀបចំកំលាំងពួកក្រុមក្មេងស្ទាវក្រុមបងតូចបងធំ ពួកសមាជិកនៃអង្គការឧក្រិដ្ឋជនសំងាត់ អេស-អូ-វ៉ាយ វាយ បង្រ្កាបសំលាប់ពួកបាតុកម្មប្រឆាំងឆ្នាំ១៩៩៨ និងប្រើកំលាំងពួកនេះធ្វើបាតុកម្មវាយកំទេចដុតបំផ្លាញស្ថានទូតថៃប្រចាំក្រុងភ្នំពេញ នៅខែមករា ឆ្នាំ ២00៣

អង្គការឧក្រិដ្ឋជនសំងាត់ អេស អូ វ៉ាយ មានន័យថាអង្គការយុវជនពិសេស គឺជាប្រភេទនៃអង្គការឧក្រិដ្ឋជនសំងាត់មួយរបស់គណះបក្សប្រជាជនកម្ពុជា ត្រូវបានបង្កើតឡើងដោយស្តេចចោរ ហ៊ុន-សែន នៅក្នុងឆ្នាំ ១៩៩៧ បន្ទាប់ពីរដ្ឋប្រហារនៅថ្ងៃ ៥-៦ កក្កដា ១៩៩៧ បណ្តេញសម្តេចក្រុមព្រះនរោត្តមរណឫទ្ធិចេញពីអំណាច។ សម្តេចស្តេចចោរ ហ៊ុន សែន បានបញ្ជាអោយលោក ជា-សុផារ៉ា (ជាអភិបាលក្រុងនៃរាជធានីភ្នំពេញ រហ័ស្សនាមសំងាត់របស់គាត់គឺ ការ-ប្រាំ **K-5** ត្រូវបានគេហៅថាបងការប្រាំ) រៀបចំបង្កើតអង្គការឧក្រិដ្ឋជនសំងាត់ អេស អូ វ៉ាយ ដែលមានលំនាំបែបបទ មានចរិតលក្ខណៈស្រដៀងគ្នាទៅនឹងស្ថាប័នពួកឆ្មាំក្រហមរបស់លោក **ម៉ៅ-សេទុង** នៅក្នុងកំឡុងសម័យបដិវត្តន៍វប្បធម៌នៃរបបសាធារណៈប្រជាមានិតចិននា (People's Republic of China) ប៉ុន្តែខុសគ្នាពីពួកឆ្មាំក្រហមរបស់លោក ម៉ៅ សេទុង ដែលចេញមុខជាចំហរតាមលក្ខណៈផ្លូវច្បាប់ ចំណែកឯពួកក្រុម អេស អូ វ៉ាយ មានលក្ខណៈជាលួចលាក់មិនចេញមុខ ធ្វើសកម្មភាពដោយអាថ៌កំបាំង ហើយចំពោះការសំលាប់ប្រជាជនដ៏សាហាវឃោរឃៅការប្រព្រឹត្តិបទឧក្រិដ្ឋលើប្រជាជនខ្លួនឯងយ៉ាងសាហាវព្រៃផ្សៃនោះគឺមានដូចគ្នាបេះបិទ គឺមានន័យថាៈ "**រាល់គ្រប់ទង្វើរដែលពួកកុំមុយនីស្តធ្វើ គឺសុទ្ធតែមានបញ្ជាពីថ្នាក់លើទាំងអស់ បើគ្មានបញ្ជា គឺមិនហ៊ានធ្វើទេ ទោះបីកុំមុយនីស្តប្រើរូបភាពជាចោរ ឬជាឃាតករក៏ដោយ សុទ្ធជាបញ្ជារបស់ថ្នាក់លើទាំងអស់**"។ ក្នុងការបង្កើតអង្គការឧក្រិដ្ឋជនសំងាត់ អេស អូ វ៉ាយ នេះ លោក ជា សុផារ៉ា បានពិភាក្សាជាមួយលោក ជា ស៊ីម ជាមេដឹកនាំគណៈបក្សប្រជាជនកម្ពុជា អំពីពួកមនុស្សដែលសក្តិសមនឹងតែងតាំងជាមេដឹកនាំអង្គការយុវជនពិសេសនោះ។ បន្ទាប់ពីកិច្ចពិភាក្សាគ្នារវាង ហ៊ុន-សែន ជា-ស៊ីម និង ជា-សុផារ៉ា រួចរាល់មក ពួកគេក៏បានសំរេចចិត្តជ្រើសរើសយកលោក កែន-ចំរើន (ជាអនុប្រធានកងពលអ៊ី-៧០ [E-70] ឈ្មោះដើមគឺ ហ៊ុន-ដារ៉ា រហ័ស្សនាមហៅ កែន-ដាវីត ដែលត្រូវបានហ្វឹកហាត់ និងបង្វឹកសិល្បះក្បាច់គុណនិនចា្ច និងក្បួនយុទ្ធសាស្រ្តដាកកុងនៅក្រុងហាណូយ ចាប់តាំងពីគាត់អាយុ ១៤ ឆ្នាំ) អោយធ្វើជាប្រធានអង្គការឧក្រិដ្ឋជនសំងាត់ អេស.អូ.វ៉ាយ ((Source[A3]))។ បន្ទាប់ពីលោក កែន-ចំរើន ក្លាយជាប្រធានអង្គយុវជនពិសេស អេស.អូ.វ៉ាយ មក លោក កែន-ចំរើន និងលោក ជា-សុផារ៉ា ដោយមានការយល់ព្រម និងឯកភាពពីថ្នាក់លើគឺ ហ៊ុន-សែន ផងនោះ ពួកគេក៏បង្កើតក្រុមបងធំបងតូច និងក្រុមជនអន្ធពាលជាច្រើនក្រុមតាំងពីក្រុងភ្នំពេញរហូតដល់ខេត្ត ស្រុក ខ័ណ្ឌ ភូមិឃុំ,,,,,,,,ពាសពេញទូទាំងប្រទេសកម្ពុជាគឺគ្រាន់តែរាជធានីភ្នំពេញ

មានក្រុមបងធំបងតូចរហូតដល់ជាង ៦០ ក្រុម។ នៅក្នុងការបង្កើតក្រុមបងធំបងតូចដ៏ច្រើនសន្ធឹកសន្ធាប់បែបនេះ គណៈបក្សប្រជាជនកម្ពុជាបានចាត់តាំងពួកអ្នកមានបណ្តាសក្តិសមល្មមចាប់ពីសក្តិពីរបីឡើងទៅដល់ផ្កាយនៅក្នុងជួរកងកំលាំងប្រដាប់អាវុធរបស់រាជរដ្ឋាភិបាលមានខាងផ្នែកប៉ូលីសទាហ៊ាន ពួកចារបុរសខាងទាហ៊ានប៉ូលីស កងអង្គរក្សរបស់ពួកថ្នាក់ដឹកនាំជាន់ខ្ពស់ កងរាជអាវុធហត្ថដែលមានចិត្តឆៅដៃដល់សាហាវឃោរឃៅពូកែខាងបាញ់បោះកាប់ចាក់ ស្តាប់បង្គាប់បញ្ជាថ្នាក់លើដោយមិនចាំបាច់គិតពីហេតុផល ពួកមេបនរកស៊ីជួញដូរមនុស្ស ពួកជួញដូរគ្រឿងញៀន ពួកជួញដូរទំនិញ និងអាវុធខុសច្បាប់ ហើយនិងពួកក្មេងពាលក្មេងអាណាថាដែលមានចិត្តកាចសាហាវព្រៃផ្សៃគ្មានមនោសញ្ចេតនា គ្មានទីពំនឹកអាស្រ័យប៉ុន្តែពួកអ្នកអស់ទាំងនោះត្រូវតែស្ថិតក្នុងក្របខណ្ឌគណៈបក្សប្រជាជនកម្ពុជា ហើយស្មោះត្រង់ដាច់ខាតចំពោះគណៈបក្សប្រជាជនកម្ពុជា ត្រូវបានបក្សជ្រើសតាំង និងចាត់តាំង អោយធ្វើជាមេក្រុមបងធំបងតូចដែលពួកគេទាំងនោះត្រូវបាននិយមហៅថា "លោកបងធំ! លោកបងធំ! "ស្អីគេនោះ។ ពួកមេបងធំនិមួយៗមានតួជានាទីទទួលខុសត្រូវលើក្រុមបងតូចបងធំរបស់ខ្លួន ដឹកនាំកូនចៅរបស់ខ្លួនរកលុយចំណូលតាមគ្រប់មធ្យោបាយ និងតំរង់ទិសកូនចៅរបស់ខ្លួនអោយដើរតាមត្រីវិស័យទិសដៅរបស់គណៈបក្សប្រជាជន និងអនុវត្តន៏តាមបញ្ជារបស់គណៈបក្សប្រជាជនកម្ពុជាដែលដាក់អោយពួកគេធ្វើ បន្ថែមលើការរកចំណូលអោយបក្ស ។ ពួកមេបងក្រុមបងធំនិមួយៗមានតួនាទីកៀណ្ឌប្រមូលមនុស្សអោយចូលក្រុមរបស់ខ្លួន និងចាត់ចែងមនុស្សក្នុងក្រុមរបស់ពួកគេស្របតាមសភាពការណ៏ និងរបត់នយោបាយដែលគណៈបក្សប្រជាជនដាក់ទិស។ សូមញ្ជាក់ថា **ពួកសមាជិក កូនចៅ អាម៉ឺអាថោង មនុស្សនៅក្នុងក្រុមបងតូចបងធំទាំងនោះគឺមិនដឹងខ្យល់អ្វីទាំងអស់ មិនដឹងរឿងរ៉ាវហេតុការណ៏ ឬអង្គហេតុអ្វីទាំងអស់ ហើយក៏មិនដឹងថាពួកគេកំពុងតែបំរើអោយគណៈបក្ស និងរាល់កិច្ចការទាំងឡាយដែលពួកគេកំពុងធ្វើគឺសុទ្ធតែជារឿងនយោបាយដែលពាក់ព័ន្ធយ៉ាងស៊ីជំរៅទៅនឹងគណៈបក្សប្រជាជនកម្ពុជា** ផ្ទុយទៅវិញ **ពួកកូនចៅអាម៉ឺអាថោង ពួកសមាជិកនៅក្នុងក្រុមបងតូចបងធំអស់ទាំងនោះគ្រាន់តែដឹងថាពួកគេខ្លាច គោរព និងស្តាប់បង្គាប់បញ្ជារបស់មេបងធំរបស់ពួកគេ** ហើយពួកគេយកលុយដែលពួករកបានអោយមេបងធំរបស់ពួកគេ ដើម្បីស៊ីផឹកសូកប៉ាន់ថ្នាក់លើ និងរកខ្នងបង្អែកត្រួសត្រាយផ្លូវអោយពួកគេដើរ ហើយពួកគេដឹងតែព្យាយាមបំពេញកាតព្វកិច្ចដែលមេបងធំរបស់ពួកគេដាក់អោយធ្វើ និងធ្វើអ្វីៗគ្រប់យ៉ាងដើម្បីធ្វើអោយលោកបងធំរបស់ពួកគេសប្បាយចិត្ត ពេញចិត្តនឹង

ពួកគេ ដោយសង្ឃឹមថាមេបងធំរបស់ពួកគេនឹងទុកការងារថ្មីៗទៀតអោយពួកគេធ្វើនៅថ្ងៃមុខ ហើយពួកគេនឹងទទួលបានផលកំរៃ ប្រយោជន៏ខ្លះៗពីការងារអស់ទាំងនោះ ។ **មានតែមេក្រុមបងធំតែប៉ុណ្ណោះទើបមានសិទ្ធិពេញលេញក្នុងនាមជាសមាជិក ឬក៏ជាសមាជិកពេញសិទ្ធិរបស់អង្គការឧក្រិដ្ឋជនសំងាត់ អេស.អូ.វ៉ាយ** ហើយពួកមេបងធំអស់ទាំងនោះ ត្រូវបានគណៈបក្សប្រជាជនចាត់អោយចូលរួមប្រជុំជាមួយថ្នាក់ដឹកនាំ និងពួកមេដឹកនាំពិសេសនៃកងកំលាំងប្រដាប់អាវុធរបស់គណៈបក្សប្រជាជនកម្ពុជានៅតាមមូលដ្ឋានរបស់ពួកគេ ដើម្បីទទួលបញ្ជា និងផែនការពិសេសដែលបក្សដាក់អោយពួកគេអនុវត្តន៏ ហើយពួកអធិបតីតំណាងអង្គប្រជុំបានអនុញ្ញាតិអោយពួកមេបងធំទាំងនោះរាយការណ៏នៅរាល់ពត៏មានខុសប្រក្រតី ពួកជនទាំងឡាយដែលត្រូវបានសង្ស័យថាជាពួកប្រឆាំង ជាបក្សពួកប្រឆាំង ជាពួកក្បត់ ឬពួកដែលមានបំណងចង់ក្បត់ និងពួកដែលធ្វើអោយរាំងស្ទះដល់ការអនុវត្តន៏ផែនការរបស់គណៈបក្សប្រជាជនកម្ពុជា លើសពីនេះទៅទៀតពួកមេបងធំទាំងនោះត្រូវបានអនុញ្ញាតិអោយផ្តល់មតិយោបល់នៅអ្វីដែលគួរធ្វើ ឬអ្វីដែលមិនគួរធ្វើ ដើម្បីបោសសំអាតពួកប្រឆាំង ពួកដែលធ្វើអោយរាំងស្ទះដល់ការអនុវត្តន៏ផែនការរបស់បក្ស ថាតើគួរត្រូវគាប្បីចាត់វិធានការយ៉ាងដូចម្តេចនោះ? ហេតុដូច្នេះហើយ ទើបពួកមេបងធំទាំងនោះដឹងរាល់កិច្ចសំងាត់ផ្ទៃក្នុងរបស់គណៈបក្សប្រជាជន យ៉ាងច្បាស់ជាក់ប្រាកដ ថែមទាំងទទួលបានប្រយោជន៏យ៉ាងធំសម្បើម និងគុណសម្បត្តិពីបក្សផងដែរ មានដូចជាអំណាចបុណ្យសក្តិ ទ្រព្យសម្បត្តិប្រាក់កាស លាភសក្ការៈផ្សេងៗជារង្វាន់លើកទឹកចិត្ត រួមផ្សំនិងពាក្យលើកសរសើរបញ្ជោរលើកជើងផងដែរ ប៉ុន្តែពួកមេក្រុមបងធំបងតូចអស់ទាំងនោះ ក៏ទទួលរងគ្រោះថ្នាក់យ៉ាងខ្លាំងណាស់ដែរ ព្រោះពួកគេត្រូវបានគណៈបក្សប្រជាជនសំលាប់បំបិទមាត់ ត្រូវដាក់គុក ឬត្រូវគំរៀមកំហែងដល់អាយុជីវិតដោយវិធីផ្សេងៗ ដោយសារតែពួកមេក្រុមបងធំទាំងនោះដឹងរឿងសំងាត់ច្រើនពេក បន្សល់ដានច្រើនពេក ធ្វើការមិនស្អាត ចាត់ការមិនរលូន ឬក៏ពួកគេមិនស្តាប់បង្គាប់បញ្ជាថ្នាក់លើ រឹងរូស ធ្វើអោយខូចផែនការ មិនអនុត្តន៏តាមផែនការថ្នាក់លើដាក់អោយ និងករណីក្បត់បក្សជាដើម,,,,, ។ល ។ និង ។ល ។ ( សូមបញ្ជាក់ថាគណៈបក្សប្រជាជនគឺជាពួកកុំមុយនីស្ត៏ផ្តាច់ការ ដូច្នេះពួកគេតែងតែប្រជុំពួកបក្ខជន សកម្មជន ឥស្សរៈជនសំខាន់ៗនៅក្នុងបក្សជារឿងរៀងរាល់សប្តាហ៏ រាល់ខែ រាល់ឆ្នាំ ដើម្បីពង្រឹង និងពង្រីកកំលាំងអំណាច វិសាលភាពបក្ស រកចំណូលអោយបក្សអោយបានច្រើនជាងពេលមុនៗ និងលាងខួរក្បាល ខាត់ដុសជំនឿមនោគមន៏វិជ្ជា ស្របតាមផែនការទិសដៅរបស់បក្ស ដើម្បីរក

មធ្យោបាយបោសសំអាតខ្មាំងផ្ទៃក្នុងផ្ទៃក្រៅរបស់ពួកគេ និងបំបាត់ចោលពួកស្រពិចស្រពិលមិនច្បាស់លាស់ សមដូចដែលពួកគេពោលថា **"បើមិនមែនជាមនុស្សក្នុងបក្ស មិនចូលបក្ស គឺមានតែជាខ្មាំង " ដូច្នេះបើជាខ្មាំង សុទ្ធតែក្នុងបញ្ជីស្បែកខ្មៅទាំងអស់** ) ។

ហ៊ុន សែន និងគណៈបក្សប្រជាជនបានប្រើប្រាស់អង្គការឧក្រិដ្ឋជនសំងាត់ អេស អូ វ៉ាយ នៅក្នុងគោលបំណងពិសេសដូចខាងក្រោមនេះ

**(១)-សមាជិកអង្គការឧក្រិដ្ឋជនសំងាត់ អេស-អូ-វ៉ាយ ត្រូវបានប្រើប្រាស់ជាឧបករណ៍សំលាប់រង្គាលពួកក្រុមអង្គការឧក្រិដ្ឋជនសំងាត់បាក់គីនៅក្នុងគោលបំណងបំបិទភស្តុតាងពួកក្រុមឧក្រិដ្ឋជនសំងាត់បាក់គី** ដើម្បីបញ្ចប់នៅរាល់បញ្ហាផលវិបាករបស់ពួកបាក់គី និងកំទេចសាក្សីឧក្រិដ្ឋជនទាំងអស់មិនអោយបែកធ្លាយបែករឿងអាថ៌កំបាំងនៃបទឧក្រិដ្ឋឃាតកម្ម និងភេរវកម្មប្លន់ជីវិត,,,,,លិចធ្លុទៅខាងក្រៅ ។ ពួកក្រុមសមាជិកអង្គការឧក្រិដ្ឋជនសំងាត់បាក់គីរាប់រយនាក់ត្រូវបានពួកកងកំលាំងប្រដាប់អាវុធរបស់រាជរដ្ឋាភិបាលរួមដៃសហការជាមួយពួកសមាជិកអង្គការឧក្រិដ្ឋជនសំងាត់ អេស-អូ-វ៉ាយ សំលាប់យ៉ាងសាហាវព្រៃផ្សៃបំផុត ហើយគណៈបក្សប្រជាជនបានបិទផ្លាកពួកអង្គការឧក្រិដ្ឋជនសំងាត់បាក់គីថាជាចោរប្លន់ ជាឃាតករ ជាពួកចោរចាប់ជីវិតមនុស្ស និងជាពួកយួនសេរីផងដែរ ឬជាក៏ជាចលនារំដោះ ចលនាក្បត់,,,,,,,, ។ល ។ និង ។ល ។ ពួកសមាជិកអង្គការឧក្រិដ្ឋជនសំងាត់ អេស អូ វ៉ាយ ដោយមានការគាំពារជួយជ្រោងជ្រែងពីពួកកងកំលាំងប្រដាប់អាវុធរបស់រាជរដ្ឋាភិបាល និងមានការរៀបចំផែនការយុទ្ធសាស្រយ៉ាងម៉ត់ចត់ពីថ្នាក់ដឹកនាំគណៈបក្សប្រជាជនកម្ពុជាផងនោះ ពួកគេត្រូវបានបញ្ជាអោយសំលាប់ពួកបាក់គីយ៉ាងសាហាវឃោរឃៅព្រៃផ្សៃបំផុតដោយប្រើរូបភាពជាប្រជាជនវាយចោរស្លាប់នៅតាមទីប្រជុំជន ឬទីកន្លែងធ្វើដែលពួកបាក់គីធ្វើសកម្មភាព ព្រោះថ្នាក់លើរបស់ CPP ជាអ្នកបញ្ជាពួកសមាជិកអង្គការចាត់តាំងឧក្រិដ្ឋជនសំងាត់បាក់គី អោយធ្វើសកម្មភាពលួចឆក់ប្លន់ជីវិត សំលាប់ឃាតកម្ម,,,,,,,,ហើយបានបញ្ជាឱ្យពួកក្រុមក្មេងស្ទាវ ពួកក្រុមបងតូចបងធំ ពួកក្រុមសមាជិក នៃអង្គការចាត់តាំងឧក្រិដ្ឋជនសំងាត់អេស-អូ-វ៉ាយ ក្លែងជាប្រជាជនរងចាំទីកើតហេតុហើយធ្វើពុតជាផ្អើលឆោឡោជ្រួលច្របល់ មកចូលជួយជនរងគ្រោះ ព្រួតគ្នាចូលរួមវាយចោររហូតដល់ស្លាប់ធ្វើហាក់បីដូចជាមានគំនុំនឹងពួកចោរខ្លាំងណាស់ ហើយប្រជាជនក៏ផ្អើលចោមរោមមើល បង្កើតជាភាពច្របូកច្របល់ លាយឡំគ្នារវាងប្រជាជនសមញ្ញ និងពួកក្រុមសមាជិកនៃអង្គការឧក្រិដ្ឋជនសំងាត់អេស-អូ-វ៉ាយ ។



នេះជាសកម្មភាពពួកក្រុមក្មេងស្ទាវ ពួកក្រុមបងតូចបងធំ ពួកក្រុមសមាជិកនៃអង្គការឧក្រិដ្ឋជនសំងាត់អេស-អូ-វ៉ាយ ក្លែងភេទធ្វើជាប្រជាជនរងចាំទីកើតហេតុ ធ្វើជាផ្អើលឆោឡោមកវាយសំលាប់ពួកឧក្រិដ្ឋជន ដែលជាគោលដៅបំបិទមាត់បំបាត់ដានអតីតកាលរបស់គណៈបក្សប្រជាជនកម្ពុជា។

ពេលខ្លះស្ទៀកពាក់កងកំលាំងទៅបាញ់ប្រហារសំលាប់ពួកបាក់គីស្រស់ៗតែម្តង ដោយបិទផ្លាក ប្រកាសប្រាប់ប្រជាជនថាបាញ់ចោរសំលាប់ព្រោះចោរ តដៃ! ។ ពួកសមាជិកនៃអង្គការចាត់តាំងឧក្រិដ្ឋជនសំងាត់បាក់គីត្រូវបានគេសំលាប់ និងត្រូវបានស្លាប់ជាបន្តបន្ទាប់ ប៉ុន្តែដើម្បីសំរេចបេសសកម្មជាតិរបស់ពួកគេ ពួកគេសុខចិត្តក្រាញនៀលមិនរត់គេចខ្លួនជាដាច់ខាត ហើយព្យាយាមអនុវត្តតាមបញ្ជាថ្នាក់លើគឺ លោក ហុក-ឡង់ឌី ដោយគ្មានការសង្ស័យអ្វីឡើយ។ ចំណែកលោក ហុក-ឡង់ឌី បានពង្រឹងជំនឿទុកចិត្តអោយពួកបាក់គីថែមទៀត ដោយលោក ហុក-ឡង់ឌី ខ្លួនឯងនេះបានក្លែងធ្វើជាមានទំនាស់ជាមួយ ហ៊ុន-សែន ក្នុងរឿងប្រជែងអំណាចគ្នានៅក្នុងបក្ស ហើយមានការប៉ះទង្គិចគ្នាយ៉ាងបែបនេះ ដែលជាសិល្បះសង្រ្គាមមួយរបស់យួនដែលបានរៀបចំឆុតឆាកល្ខោនអោយក្រុមអាយ៉ងរបស់ខ្លួននៅក្នុងគណៈបក្សប្រជាជនដើម្បីពង្រឹងអំណាច និងក្តោបអំណាចក្នុងប្រទេសកម្ពុជាអោយកាន់តែរឹងមាំ និងចាក់គ្រឹះយ៉ាងណែនក្នុងដៃនោះ យួនកុំមុយនីស្តិ៍បានបញ្ជាអោយអាយ៉ងរបស់ខ្លួនបែងចែកជា ៣ពួក ឬជា៣ខ្សែ នៅក្នុងគណៈបក្សប្រជាជនគឺ ខ្សែ ជា-ស៊ីម, ស-ខេង ខ្សែ ហ៊ុន-សែន និងខ្សែ ហុក-ឡង់ឌី ដែលខ្សែទាំងបីនេះធ្វើកិច្ចការតាមមុខសញ្ញារៀងៗខ្លួនទៅតាមខ្សែរញ្ជាក់ និងការបង្គាប់បញ្ជារបស់យួន ដែលរូបភាពខាងក្រៅមើលទៅហាក់បីដូចកំពុងបែកបាក់គ្នា ប្រជែងអំណាចគ្នានៅក្នុងជួរបក្ស ប៉ុន្តែតាមការពិតពួកគេទាំង៣ខ្សែនេះគឺគ្រាន់តែជាឧបករណ៍ប្រើប្រាស់ដើម្បីបំរើគោលបំណងលេបត្របាក់ទឹកដីខ្មែរប៉ុណ្ណោះ មិនបានបែកបាក់គ្នា មានទំនាស់នឹងគ្នាអ្វីឡើយ ដូចជាករណីបោកគ្រាប់បែកមុខរដ្ឋសភាវាយប្រហារលើជនបាតករស៊ីវិលគឺ លោក ហុក-ឡង់ឌី (អគ្គស្នងការប៉ូលីសជាតិផ្កាយមាស៤) ជាអ្នកផ្តល់យោបល់អោយប្រើគ្រាប់បែកវាយប្រហារ រីឯ ហ៊ុន-សែន

(នាយករដ្ឋមន្ត្រីទី២)គឺជា អ្នកបញ្ជាអោយក្រុមអង្គរក្សរបស់ខ្លួនឱ្យវាយប្រហារដោយគ្រាប់បែកទៅលើរូបលោក សម-រង្ស៊ី និងហ្វូង បាតុករស៊ីវិលកាលពីថ្ងៃទី ៣០ ខែមិនា ឆ្នាំ ១៩៩៧ ចំណែកឯលោក ស-ខេង (រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ)និង លោក ជា-សុផារ៉ា (អភិបាលក្រុងរាជធានីភ្នំពេញ) ជាពួកអ្នកសំរួលដំណើរការវាយប្រហារនេះអោយមានភាពរលូន ហើយបន្ទាប់ពីវាយប្រហារដោយគ្រាប់បែករួចភ្លាមៗនោះ លោក ជា-សុផារ៉ា ជាអ្នកយកឡានទឹកទៅលាងសំអាតទីកន្លែងកើតហេតុ និងបានយកម៉ាស៊ីនឆក់យកកំទេចគ្រាប់បែកចេញពីទីកន្លែងកើតហេតុ ដើម្បីបំបាត់នៅរាល់ភស្តុតាងដែលសេសសល់ និងជួយសំរួលពត៌មានកើតហេតុអោយផ្ទុយពីការពិត បូកនឹងប្រតិមិតិក្នុងរឿងបទឧក្រិដ្ឋភេរវកម្មនេះ ដែលធ្វើពួកគណៈបក្សផ្សេងដទៃទៀតយល់ច្រលំ ហើយគិតខុស សន្និដ្ឋានខុស និងផ្សព្វពត៌មានខុស អោយគណៈបក្សប្រជាជនកម្ពុជាថែមទៀតផង។ មូលហេតុនេះហើយ ទើបពួកអង្គការបាក់គីតស៊ូបំពេញបេសកម្មដោយឥតសង្ស័យ និងឥតញញើតរុញរាឡើយ ដោយសារភាពក្លាហានហួសប្រមាណគ្មានគិតពិចារណានេះហើយ បានជាពួកគេបាត់បង់ជីវិតយ៉ាងសន្ធឹកសន្ធាប់ ព្រោះលោក ហុក-ឡង់ឌី បានបញ្ជាអោយពួកបាក់គីធ្វើសកម្មភាពប្លន់ជីវិតសំលាប់ជួញដូរ,,,,,,,,, ហើយ លោក ហុក-ឡង់ឌី ខ្លួនឯងនិងគណះបក្សប្រជាជន ជាពួកអ្នកបញ្ជាកងកំលាំងប្រដាប់អាវុធនិងក្រុម អេស. អូ.វ៉ាយ រងចាំប្រហារពួកបាក់គី ដូច្នេះហើយ ទោះបីជាពួកបាក់គីនៅកន្លែងទីណាក៏ដោយ ក៏ត្រូវបានកងកំលាំងប្រដាប់អាវុធរបស់រាជរដ្ឋាភិបាល និងពួកសមាជិកអង្គការឧក្រិដ្ឋជនសំងាត់ អេស អូ វ៉ាយ ប្រម៉ាញ់ពួកបាក់គីបានយ៉ាងងាយជាទីបំផុត។ គ្មានរបាយការណ៏បញ្ជាក់ច្បាស់លាស់ថាពួកបាក់គីចំនួនប៉ុន្មាននាក់ត្រូវបានសំលាប់ទេ តែបើតាមសំដីរបស់លោក កែន-ចំរើន ជាប្រធានអង្គការឧក្រិដ្ឋជនសំងាត់ អេស អូ វ៉ាយ បានអោយដឹងថា "អា មិន និង អាថាច់ ចាន់ ជាមនុស្សសេសសល់ចុងក្រោយបំផុតដែលមានសំណាងមកជាប់គុកនៅព្រៃស តែពួកវាគ្រាន់តែរស់បណ្តោះអាសន្នប៉ុណ្ណោះ ព្រោះពួកវាគ្រាន់តែតួអង្គឧបករណ៏នៃឆាកល្ខោន តាមប្រភព (Source$^{C2}$)។តែបើតាមលោក ទូច-មៅ ដែលជាចោរប្លន់នៅអាគារសេ នៃគុកព្រៃស បាននិយាយថានៅខែតុលា ឆ្នាំ២០០៧ ថា រូបគាត់បានជាប់បន្ទាប់វិន័យ(ជាបន្ទាប់ទារុណកម្មគ្មានពន្លឺថ្ងៃ)ជាមួយបងមិន និងបងចាន់ ដែលជាអង្គរក្សលោក ហុក-ឡង់ឌី នៅក្នុងខែ ធ្នូ ឆ្នាំ ២០០៦ នោះ បានដឹងរឿងជាច្រើនអំពីពួកគាត់ បងមិន និងបងចាន់ បាននិយាយថាកាលពីគាត់នៅក្រៅសំបូរលុយផឹកស៊ីណាស់ គិតតែសប្បាយ ជាពិសេសពេលប្លន់ជីវិតម្តងៗ លុយមិនដឹងជាយកទៅ

ណាអស់ទេ ប៉ុន្តែលុយទាំងនោះប្រៀបដូចជាមានស្លាប ពួកគាត់បានតែមកត្រឹមកាន់រយៈពេលខ្លីតែប៉ុណ្ណោះ រួចហើយលុយទាំងនោះនឹងហោះចេញទៅវិញ ព្រោះប៉ាប៉ាអោយមនុស្សមកយកអស់ ទុកតែបន្តិចបន្តួចសំរាប់ពួកគាត់សប្បាយផឹកស៊ីស្រីស្រាតែប៉ុណ្ណោះ ប៉ាប៉ា (ហុក-ឡង់ឌី) អោយពួកគាត់ធ្វើតែករណីធំៗប៉ុណ្ណោះ បើអោយពួកគាត់ទៅប្លន់វិញ គឺចាប់ពីរាប់ម៉ឺនដុល្លាឡើងទៅ ពួកគាត់មិនធ្វើទេចំពោះរឿងតូចតាចនោះ។ ខ្ញុំបានព្យាយាមរកលោកមិន និងលោកចាន់ដែរ ប៉ុន្តែមិនមានឱកាសបានជួបពួកគាត់សោះ ព្រោះពួកគាត់ទាំង២នេះ ត្រូវបានចាងហ្វាងគុកព្រៃ-ស ព្យាយាមអោយចោរវាយសំលាប់បំបិទមាត់ តែដោយសារវិជ្ជាគុនពួកគាត់ខ្លាំង ក៏មិនស្លាប់ ដូច្នេះបានជាចាងហ្វាងគុកព្រៃ-ស ចាប់ពួកគាត់ដាក់ក្នុងបន្ទប់វិន័យ ហើយបន្ទាប់មកក៏បញ្ជូនពួកគាត់ទៅកាន់គុកត្រពាំងឃ្លុង ក្រោយមកក៏បានដំណឹងពីលោកធូ-ដ៉ាវ៉ាថា អាមិន អាចាន់ ត្រូវបានគេសំលាប់បំបិទភស្តុតាងទៅហើយ។

**(២) -រកលុយអោយគណះបក្សប្រជាជនកម្ពុជាតាមរយះ**ការលួចឆក់ប្លន់ ជំរិតសំលាប់ ជួញដូរមនុស្ស អាវុធទំនិញខុសច្បាប់ ជួញដូរ និងចែកចាយគ្រឿង ញៀនអោយបក្ស លាងលុយក្រខ្វក់ ឃាតកម្មស៊ីឈ្នួល កុហក់បោកប្រាស់,.,.,.,។ល។ និង។ល។ គណះបក្សប្រជាជនប្រកបមុខរបរងងឹតសព្វយ៉ាងដើម្បីបង្កើនប្រាក់ចំណូលចូលបក្សក្នុងការពង្រឹងអំណាចរបស់ខ្លួន ហើយមុខរបរជួញដូរគ្រឿងញៀនគឺជាអាទិភាពចំបងបំផុតក្នុងការបង្កើនប្រាក់ចំណូលចូលបក្សអោយកាន់តែច្រើនអណេក ហើយបញ្ជូនាំចេញនាំចូលគ្រឿងញៀនទៅកាន់ប្រទេសក្រៅ មិនទាន់គ្រប់គ្រាន់ទេ ដូច្នេះ ការបង្កើតក្រុមបងធំបងតូចទូរទាំងប្រទេសទើបបន្ថែមចំណូលកើនទ្វេរាប់សិបដងសំរាប់គណះបក្សប្រជាជនក្នុងការពង្រឹងបណ្តាញចារកម្ម បំពាក់គ្រឿងឧបករណ៍ចារកម្មអាស្សាណូទំនើប (modern spy bugs) (Source$^{Special}$) ដើម្បីពង្រឹងអំណាចផ្ទៃក្នុង និងកំទេចពួកបក្សប្រឆាំងអោយបានកាន់តែឆាប់រហ័សថែមទៀត។ ករណីរកស៊ីគ្រឿងញៀនក្នុងទ្រង់ទ្រាយធំនេះ គឺមានចរាចរនៅក្នុងស្រុក និងនាំចេញទៅបរទេសដែល ចាប់ពីរាប់គីឡូក្រាមឡើង ទៅរហូតដល់ថ្នាក់ រាប់រយ និងរាប់សិបតោន ដែលពួកគេបែងចែកជា ៣ ប្រភេទនៃមុខទំនួញគឺៈ

**-ប្រភេទទី១ គឺជាប្រភេទគ្រឿងញៀនដែលមិនទាន់បានកែច្នៃសោះ** គឺជាគ្រឿងញៀនផលិតផលជាវត្ថុធាតុដើមមានដូចជាកញ្ឆា គ្រាប់ពូជគ្រឿងញៀន ឬដើមរុក្ខជាតិដទៃៗទៀតដែលពួកគេអាចដាំក្នុងប្រទេសខ្មែរបាន ហើយផលិតចេញជាទ្រង់ទ្រាយធំសំរាប់ការនាំចេញទៅក្រៅប្រទេស ហើយបើតាមប្រភពឯកសារដែល

មានចំណងជើងថា **U.S. accuses Hun Sen on drugs; terrorism** ប្រទេសកម្ពុជាបានក្លាយជាប្រទេសពាណិជ្ជកម្មធំចម្បងបំផុតមួយនៃការផ្ទេរថ្នាំញៀនប្រភេទហេរ៉ូអ៊ីន និងកញ្ឆា នៅអាស៊ីអាគ្នេយ៍នៅក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ ហើយថ្នាំញៀនកញ្ឆារបស់ប្រទេសកម្ពុជាត្រូវបានចាប់រឹបអូសបានទំងន់ចំនួន ១២០ តោន នៅក្នុងទ្វីបអឺរ៉ុបនៅក្នុងកំឡុងឆ្នាំ ១៩៩៦ (Cambodia has become a major transshipment point for Southeast Asian heroin and marijuana in recent years, with 120 tons of Cambodian marijuana seized in Europe during 1996 សូមមើលវិបសាយ **http://www.garella.com/rich/grenpost.htm** **).** ក្នុងរឿងករណីដូចគ្នាដែរ នៅក្នុងប្រទេស ថ្នាំញៀនកញ្ឆារបស់លោក ឧកញ៉ា ម៉ុង ឫទ្ធី ចំនួន ៧ តោន តាមប្រភព (**Source**$^{D1}$) ដែលលោក ហូ សុខ (មកពីបក្សហ្វុនស៊ិនប៉ិច ជាអនុរដ្ឋលេខាធិការនៃ ក្រសួងមហាផ្ទៃនៅក្នុងរដ្ឋាភិបាលចំរុះអាណត្តិទី១) បានចាប់បានកញ្ឆារបស់លោក ម៉ុង ឫទ្ធី ចំនួន ៧ តោននៅ ឆ្នាំ ១៩៩៧ នៅកំពង់ផែក្រុងព្រះសីហនុ ពីកុងទីន័រដែលបិទផ្លាកថាកៅស៊ូនោះ។ ប៉ុន្តែលោក ហេង-ពៅបានអះអាងថារូបលោកជាអ្នករឹបអូសយកកញ្ឆា ៧ តោន ដែលលាក់ក្នុងកុងទីនឺ ដាក់ក្នុងកប៉ាល់រួចជាស្រេច បំរុងនឹងនាំចេញទៅកាន់ប្រទេសន័រវេ (Norway) នៅកំពង់ផែក្រុងព្រះសីហនុ ជារបស់ក្រុមហ៊ុន របស់លោក ម៉ុង ឫទ្ធី ដែលជាមិត្តជិតស្និតរបស់ហ៊ុន-សែន ហើយបន្ទាប់មកលោក ហូរ-សុខ ជាអនុរដ្ឋលេខាធិការ នៃក្រសួងមហាផ្ទៃមកពីគណៈបក្សហ្វុនស៊ិនប៉ិច បានសុំអោយលោក ហេង-ពៅ ចាប់ខ្លួនលោក ម៉ុង-ឫទ្ធី តែលោក ហេង-ពៅ មិនអាចធ្វើបានព្រោះលោក ម៉ុង-ឫទ្ធី ជាប់ពាក់ពន្ធ័នឹងលោក ហ៊ុន-សែន គឺមិនអាចប៉ះពាល់បានឡើយ (**Source**$^{D1}$)។ តែត្រូវបាន ហ៊ុន-សែន ព្រមានគំរាមបកវិញថា បើចង់ចាប់ លោកឧកញ៉ា ម៉ុង ឫទ្ធី អោយពាក់មួកដែកមកផង ទីបំផុតបន្ទាប់រដ្ឋប្រហារ លោក ហូរ-សុខ ត្រូវបានសំលាប់ស្លាប់យ៉ាងអណោចអធមក្នុងរដ្ឋប្រហារថ្ងៃ ៥-៦ ខែកក្កដា ឆ្នាំ ១៩៩៧ ព្រោះលោក ហូរ-សុខ គឺជាវីរៈជនឆ្លាតវៃស្មោះត្រង់នឹងជាតិ ដែលជាឧបសគ្គរាំងស្ទះដល់ពាណិជ្ជកម្មម៉ាហ្វីយ៉ារបស់គណៈបក្សប្រជាជនកម្ពុជា និងធ្វើអោយរាំងស្ទះដល់ការអនុវត្តបេសសកម្មរំលាយជាតិខ្មែររបស់ក្រុងហាណូយ។ គោលដៅដ៏ធំបំផុតរបស់យួនកំមុយនីស្តនៅក្នុងបេសសកម្មរំលាយជាតិខ្មែរ គឺផែនការបោសសំអាតខ្មាំងក្រុងហាណូយ ដើម្បីដកបន្លាចេញពីទ្រូង និងដកស្នឹមចេញពីកែវភ្នែកគឺកំទេចរាល់ពួកអ្នកជាតិនិយមខ្មែរ និង ពួកវីរៈជនស្នេហាជាតិខ្មែរ ចំណែកឥស្សរៈជន គ្រាន់តែជារឿងបន្ទាប់បន្សំតែប៉ុណ្ណោះ គឺយួនចំលងយកទាំងស្រុងនៅយុទ្ធសាស្ត្រសិល្បៈសង្គ្រាមរបស់ស្តេចចិនឈ្មោះ **ស៊ឺះ ហ៊ីង ទី**

Shih Huang Ti (256 B.C-206 B.C) ដែលវាយទន្ទ្រានលេបយកនគរជិតខាងទាំង៨ ហើយសំលាប់ពួកអ្នកចេះដឹង ពួកអ្នកប្រាជ្ញចោលអស់ រួចបង្រួបបង្រួមធ្វើជានគរតែមួយ ឈ្មោះព្រះអង្គធ្វើជាឈ្មោះនគរ ហៅថា នគរឆិន (China) គឺប្រទេសចិន ហ្នឹងឯង សូមមើលសៀវភៅ WORLD HISTORY by Irving L.Gordon, second Edition (Revised 1982) ។



***មេដៃរកស៊ីគ្រឿងញៀនចិញ្ចឹមបក្ស***

*Mong Reththy receiving a medal from Hun Sen*

**-ប្រភេទទី២:ជាប្រភេទគ្រឿងញៀនជាលក្ខណៈផលិតផលសំរេច** ដែលបាននាំចូលពីខាងក្រៅប្រទេសចូលមក មានដូចជា ហេរ៉ូអ៊ីន ទឹកកក ,,,,,,,,,,ជាដើម ដែលគណៈបក្សប្រជាជននាំមកពីប្រទេស ភូមា ឬក៏ពីប្រទេសឡាវ ចូលមកប្រទេសកម្ពុជា ហើយនាំចេញទៅកាន់ប្រទេសទាំង៥៦ នៅក្នុងបណ្តាញម៉ាហ្វីយ៉ា ដែលពួកគេរកស៊ីជាមួយ។ តាមសំដីរបស់លោក **កែន-ចំរើន** (ឈ្មោះនៅក្នុងក្រុមអន្ធពាល Mafia បានហៅរូបគាត់ថា **កែន-ជាវីត**) បានពោលថា ក្នុងរយៈពេលដែលគាត់កាន់តំណែងជាប្រធាន អង្គការឧក្រិដ្ឋជនសំងាត់ អេស អូ វ៉ាយ គណៈបក្សប្រជាជនកម្ពុជា បានចាត់រូបគាត់អោយដើរតួជា**ថៅកែធំ** ដើម្បីនាំគ្រឿងញៀនចេញក្រៅប្រទេស ជាពិសេសគឺហេរ៉ូអ៊ីន ទៅកាន់ ៥៦ ប្រទេស មានដូច ជាប្រទេស ថៃ ម៉ាឡេស៊ី ប៊ុយនេតៃវ៉ាន់ ហុងកុង កាណាដា ចក្រភពអង់គ្លេស សហរដ្ឋអាមេរិក រុស្សី,,,,,,,,,,,,, ។ល។ និង ។ល។ នៅពេលដែលលោក កែន-ចំរើន ធ្វើជាថៅកែធំនោះ គឺគណៈបក្សប្រជាជនអនុញ្ញាតិអោយគាត់ប្រើប្រាស់តាមចិត្តចង់ ហើយគាត់អាចផ្ញើរថ្នាំហេរ៉ូអ៊ីនចំនួយ បួន-ប្រាំ គីឡូក្រាមភ្ជាប់ជាមួយថ្នាំហេរ៉ូអ៊ីនរាប់តោនរបស់គណៈបក្ស

ប្រជាជនកម្ពុជាផងដែរ។ The Cambodian drug trade includes cannabis, methamphetamine, and high graded heroin ប្រទេសកម្ពុជាជាប្រទេសពាណិជ្ជកម្ម គ្រឿងញៀនរួមមាន កញ្ឆា មិតាអំហ្វេតាមីន និង ហេរ៉ូអ៊ីនកំរិតខ្ពស់ នេះបើតាមប្រភព (Source$^{D3}$) ហើយក្រៅពីលោក កែន-ចំរើន ដែលដើរតួជាថៅកែធំនោះ នៅមានលោក ថេង-ប៊ុនម៉ា ម៉ុងរិទ្ធី,........ សុទ្ធតែត្រូវបានបញ្ជា និងរៀបចំឡើងដោយឥស្សរៈជនមេដឹកនាំជាន់ខ្ពស់របស់គណៈបក្ស ប្រជាជនកម្ពុជាដែលមាន ហ៊ុន-សែន លោក ជា-សុផារ៉ា លោក ហុក-ឡង់ឌី និងពួកក្រុមឧត្តមសេនីយដទៃៗទៀត នៅក្នុងជួរកងកំលាំងប្រដាប់អាវុធរបស់រាជរដ្ឋាភិបាលកម្ពុជាដូចជាករណីនៅ ក្នុងឆ្នាំ ១៩៩៧ លោក ថេង-ប៊ុនម៉ា និង ហ៊ុន-សែន បានរកស៊ីគ្រឿងញៀនចូលហ៊ុនគ្នា ហើយ ហ៊ុន-សែន បានប្រើល្បិចពាលស៊ីពាលលេងលោកថេង-ប៊ុនម៉ា ស្ទើរអស់ចុងអស់ដើម។

| | |
|---|---|
| <br>មេម៉ាហ្វីយ៉ាខ្មែរឈ្មោះ លោក **ថេង-ប៊ុនម៉ា** | លោក **ថេង-ប៊ុនម៉ា** ជាមហាសេដ្ឋីថ្នាំញៀនរបស់កម្ពុជា ជាម្ចាស់សណ្ឋាគារប្រណិត ឈ្មោះ "Intercontinental" នៅភ្នំពេញ ជាម្ចាស់កាសែតរស្មីកម្ពុជា Rasmei Kampuchea ជាសារពត៌មានម៉ាហ្វីយ៉ា (Mafia) ខ្មែរធំជាងគេបោះពុម្ពផ្សាយ ១៨ 000ច្បាប់ក្នុង១ថ្ងៃនិងជាព្រឹទ្ធាចារ្យបង្រៀនពួកមេដឹកនាំគណៈបក្សប្រជាជនកម្ពុជា អោយចេះវិធីរស៊ីជួញដូរគ្រឿងញៀនជាមួយពួកម៉ាហ្វីយ៉ា ៥៦ប្រទេសលើពិភពលោក ដើម្បីរកលុយចិញ្ចឹមបក្ស។ http://www.ask.com/wiki/Drugs_in_Cambodia |

បានបញ្ជាអោយលោក ថេង-ប៊ុនម៉ា ទទួលខុសត្រូវក្នុងការនាំចេញហេរ៉ូអ៊ីន ទំងន់ ៦៧៥0 គីឡូក្រាមផ្ទុកនៅក្នុង ៥៣ កុងតឺន័រ នាំចេញទៅកាន់ប្រទេសដាណឺម៉ាក ប៉ុន្តែត្រូវបានរដ្ឋាភិបាលដាណឺម៉ាកចាប់ និងរឹបអូសយកថ្នាំហេរ៉ូអ៊ីនអស់ទាំង នេះ (Source$^{B4\ and\ B5}$) ហើយនៅពេលនោះ ហ៊ុន-សែន បានខឹងសម្បានឹងលោក ថេង-ប៊ុនម៉ា យ៉ាងខ្លាំង ហើយតំរូវអោយលោក ថេង-ប៊ុនម៉ា សងមាសសុទ្ធចំនួន ៥ តោនមកអោយហ៊ុន-សែន វិញ ប៉ុន្តែលោក ថេង-ប៊ុនម៉ា បានទៅទីក្រុង ហុងកុង ទិញមាសសុទ្ធបានតែចំនួន ១ តោន យកអោយ ហ៊ុន-សែន។ ហ៊ុន-សែន បានរឹបអូសយកសណ្ឋាគារប្រណិតថ្នាក់ផ្កាយ៥ ឈ្មោះអ៊ីនធឺកុងទីណង់តាល់

របស់លោក ថេង-ប៊ុនម៉ា នៅទីក្រុងភ្នំពេញធ្វើជាផ្ទះរងចាំលោក ថេង-ប៊ុនម៉ា យកមាសសុទ្ធ ឬលុយមកដូរ (he luxury hotel "Intercontinental" in Phnom Penh) ហើយត្រូវបានដាក់បំរាមហាមមិនអោយលោក ថេង-ប៊ុនម៉ា ចូលជួបជាដាច់ខាត ។

ករណីនៅឆ្នាំ ២០០៣ លោក ហេង-ពៅ បានចាប់រឹបអូសយកថ្នាំញៀនហេរ៉ូអ៊ីន ចំនួន ៣៦ គីឡូក្រាម ពីលោក ងួរ-សម្បត្តិ នៅខ័ណ្ឌទួលគោករាជធានីភ្នំពេញគឺជាមនុស្សរបស់លោកឧត្តមសេនីយផ្កាយ៣ ឈ្មោះសៅ-សុខា និង ពាក់ព័ន្ធនឹងលោកឧត្តមសេនីយផ្កាយ២ ឈ្មោះលោក ដុំ-ហាក់ តែត្រូវបាន ហ៊ុន-សែន បានឃាត់លោក ហេង-ពៅ ហាមមិនឱ្យចាប់លោក ដុំ-ហាក់ និងសំលាប់លោក ងួរ-សម្បត្តិ បំបិទមាត់ http://ki-media.blogspot.com/2006/08/transcript-and-original-statement-of.html ដោយសារតែ លោក ដុំ-ហាក់ និងលោកសៅ-សុខា គ្រាន់តែដើរតួនាទីជាថៅកែធំថ្នាំញៀន ជួសមុខឱ្យ គណៈបក្សប្រជាជនកម្ពុជា ជួសមុខឱ្យ ហ៊ុន-សែន ជាប្រមុខ ដើម្បីចែកចាយបោះដុំអោយពួកសមាជិកអង្គការឧក្រិដ្ឋជនសំងាត់ អេស-អូ-វ៉ាយ យកលក់បន្តអោយពួកក្រុមក្មេងស្ទាវក្រុមបងតូចបងធំតែប៉ុណ្ណោះ ។

**-ប្រភេទទី៣ : ជាគ្រឿងញៀនកែច្នៃផលិតនៅក្នុងប្រទេស** ដោយគ្រាន់តែនាំវត្ថុធាតុដើមចូលមកពីខាងក្រៅហើយកែច្នៃចេញជាគ្រឿងញៀនដ៏មហាគ្រោះថ្នាក់ដូចជាប្រភេទថ្នាំយ៉ាម៉ា ថ្នាំគ្រីរ ខេ ការ៉ុបិត,,,,,,,, ជាដើម ថ្នាំអស់ទាំងនេះសុទ្ធតែផលិតដោយគណៈបក្សប្រជាជន ជាពិសេសជនជាតិយួនដែលរកស៊ីបើកបនស្រី ឬជនពាក់ពន្ធ័នឹងបនបារ សុទ្ធតែចេះទាំងអស់ ហើយពួកគេចេះផ្លាស់ប្តូរវត្ថុធាតុដើមយ៉ាងស្ទាត់ជំនាញទៅតាមអ្វីដែលពួកគេមាន ។ បើតាមសំដីលោកគីមវ៉ាន់សាង ដែលជាមេបនម្នាក់ជាប់គុកដោយសារប្រពន្ធប្រើល្បិនោះ នៅបន្ទប់៣២ អាគារអា A នៃគុកព្រៃស នៅខែវិច្ឆិការ ឆ្នាំ ២០០៦ បានបង្ហើបអោយដឹងថា

អ្នកដែលស្ទាត់ជំនាញក្នុងការផលិតថ្នាំញៀនដូចជា ថ្នាំខេ ថ្នាំគ្រីរ ថ្នាំយ៉ាម៉ា ,,,,,,គឺតាសេង នៅសណ្ឋាគារហូលីដេ ជាមនុស្សរបស់ ហ៊ុន-តូ ក្មួយប្រុសរបស់ ហ៊ុន-សែន ។ ក្នុងការលួចរូបមន្តដើម្បីផលិតថ្នាំយ៉ាម៉ានោះលោក គិម-វ៉ាន់សាង បានព្យាយាមយកចិត្តយកថ្លើមស្រីស្នេហ៍របស់តាសេងឈ្មោះអាមុីដែលជាសិស្សជំនិតផងដែរហើយចេះវិធីផលិតថ្នាំយ៉ាម៉ាយ៉ាងស្ទាត់ជំនាញដែលមានគុណភាពលើសថ្នាំមកពីខាងក្រៅទៅទៀត

គាត់បានបញ្ជាក់ថែមទៀតថាគ្រប់ពួកអ្នករកស៊ីបើកហាងស្រីគឺចេះទាំងអស់ ខ្ញុំក៏សួរគាត់ផលិតបែបយ៉ាងម៉េច គាត់ថា យើងត្រូវតែឆ្លាតពីវត្ថុធាតុដើមត្រូវតែប្រែប្រួលតាមអ្វីដែលយើងមាន ដំបូងយើងត្រូវយកធាតុផ្សំ ទឹកស៊ីលិច (ដើម្បីយកពណ៌) ប្រេងម្រះព្រៅ (ដើម្បីយកក្លិនក្រអូប) កញ្ឆា (បើបានហេរ៉ូអ៊ីនកាន់តែប្រសើរ, កញ្ឆាធ្វើអោយងងុយដេក តែបើត្រូវមេអាស៊ីតវិញ វាក្លាយជាអត់ងងុយតែធ្វើអោយញៀន) ម្សៅកាហ្វេអ៊ីន (ធ្វើអោយអត់ងងុយ ស្រវឹង ង៉ាំង) ម្សៅគ្រាប់ឈូក (ដាក់យកបរិមាណអោយបានច្រើន) កិនកំទេចលាយ បញ្ចូលគ្នា ជាទឹកប៊ុកៗ រួចលាយជាមួយមេអាស៊ីត កូរតែមួយភ្លែតឆួតរីង ហើយយកទៅចាក់ពុម្ភលក់ ប៉ុន្តែក្នុងការលក់ដូរត្រូវចចំណាយច្រើនទៅលើពួកកងកំលាំង និងទៅលើខ្នងបង្អែកនៅក្នុងតំបន់របស់គាត់ គ្មានអ្នករកស៊ីណាមួយដែលមិនចំណាយ ហើយឈរជើងហ្នឹងនោះទេ។

ក្នុងលំដាប់គ្រឿងញៀនប្រភេទទី៣ នេះ គណះបក្សប្រជាជនកម្ពុជាបានផលិតដ៏ច្រើនសន្ធឹកសន្ធាប់ ហើយត្រូវការដីដាំដុះយ៉ាងធំសម្បើមដើម្បីដាំកញ្ឆា និងដើមអាភៀនដោយលួចលាក់ ដីធ្លីនៅស្រុកខ្មែរមិនថាដីភ្នំ ដីទំនាប ឬដីព្រៃឡើយ អោយតែមានបំរាមហាមឃាត់មិនអោយប្រជាជនឆ្លងកាត់ ឬដើរជិតបៀត គឺសុទ្ធតែជាដីដាំដើមកញ្ឆា និងដាំរុក្ខជាតិផលិតថ្នាំញៀនទាំងអស់ ទោះបីរដ្ឋាភិបាលបិទផ្លាក ប្រើរូបភាពបែបណាក៏ដោយ គឺគ្រាន់តែជាល្បិចបំភាន់ភ្នែកប្រជាជនទាំងអស់ ជាពិសេសដីព្រៃភ្នំ (ពាក្យដីវិនិយោគ និង ដីបន្ទាយកងទ័ព ដីក្រុមហ៊ុន ដីថៅកែបរទេស គឺជាលេសបិទបាំងយ៉ាងសាមញ្ញរបស់គណះបក្សប្រជាជន) ដែលជាតំបន់ហាមឃាត់របស់ពួកគេ។ ដូច្នេះកញ្ឆា ជាអាទិភាពសេដ្ឋកិច្ចយ៉ាងចម្បងសំរាប់បង្កើននៅប្រាក់ចំណូលទ្វេរាប់សិបដងអោយគណៈបក្សប្រជាជនសំរាប់កែច្នៃចេញជាប្រភេទគ្រឿងញៀនដទៃៗទៀតដូច ជាថ្នាំគ្រាប់ ថ្នាំខេ ថ្នាំយ៉ាម៉ា,,,,,,,,និងថ្នាំរាប់សិបប្រភេទទៀតដែលមានលក្ខណះបំភាន់ភ្នែកមើលទៅដូចថ្នាំពេទ្យធម្មតា ឬជារូបរាងស្ករគ្រាប់ នំនែកផ្សេងៗ ,,,,,,,,ក្រៅពីនេះកញ្ឆាត្រូវបានលក់នៅក្នុងស្រុក និងនាំចេញទៅក្រៅប្រទេស ចំណែកប្រេងម្រះព្រៅវិញ គ្រាន់តែជាផលិតផលផ្គួបផ្សំតែប៉ុណ្ណោះ។ ដូច្នេះហើយ បញ្ហាទីផ្សារ និងបញ្ហាបញ្ចេញទំនិញគ្រឿងញៀនទាំងនេះបានចោទឡើងដែលគណៈបក្សប្រជាជនត្រូវតែ

រកមធ្យោបាយដោះស្រាយជាបន្ទាន់ មូលហេតុនេះហើយដែលគណះបក្សប្រជាជនចាំបាច់ត្រូវតែបង្កើតចេញជាក្រុមបងតូចបងធំ ហើយបង្វឹកពួកគេអោយប្រើថ្នាំញៀន ដែលក្នុងករណីបង្ហាត់បង្រៀននេះ ពួកគេអោយយុវជន ក្មេងស្ទាវសាកល្បងដោយអត់យកលុយ ឬយកក្នុងកំរៃស្តួចស្តើងបំផុត រហូតដល់ពួកយុវជន ពួកក្មេងស្ទាវក្លាយទៅជាញៀនថ្នាំ ទើបពួកគេលក់ឡើងថ្លៃកប់ក្តោងតែម្តង។ ចំណែកឯពួកមេក្រុមបងធំនិមួយៗ (លោកបងធំ) មានឋានះត្រឹមតែជាសមាជិកអង្គការឧក្រិដ្ឋជនសំងាត់ អេស អូ វ៉ាយ តែប៉ុណ្ណោះ ពួកមេបងធំទាំងនោះមានតួនាទីអនុវត្តន៏តាមបញ្ជារបស់មេដឹកនាំគណះបក្សប្រជាជន ទទួលថ្នាំញៀនពីគណៈបក្សប្រជាជនកម្ពុជាយកទៅលក់ចែកចាយអោយកូនចៅអាម៉ិអាថោង និងមនុស្សនៅក្នុងក្រុមបងតូចបងធំរបស់ខ្លួន ហើយប្រមូលប្រាក់កំរៃចំណេញពីការលក់ថ្នាំញៀននេះអោយទៅថ្នាក់លើ ហើយប្រាប់កូនចៅរបស់ខ្លួនថាជាលុយសូកប៉ាន់ ជាលុយសគុណ ជាលុយសំរាប់ខ្នងបង្អែកដើម្បីរកស៊ីទៅថ្ងៃក្រោយ ក្រៅពីនេះ តួនាទីរបស់មេបងធំត្រូវដឹកនាំកំលាំងមនុស្សលុយ និងផ្តល់មធ្យោបាយអោយរកលុយដល់បក្សពួកកូនចៅរបស់ខ្លួន។ បើតាមសំដីរបស់លោក ហេង-សុវណ្ណារិទ្ធិ ហៅបងហ៊ីលីព (Source[A5]) បានប្រាប់ថាលោកបានធ្លាប់ចូលរួមប្លន់ហាងមាស ហាងដូរលុយ,,,,,ជាមួយលោក ហ៊ុន-ពៅ (ជាកូនរបស់ ហ៊ុន-ណារី និងក្មួយរបស់ ហ៊ុន-សែន)មានពេលខ្លះ ហ៊ុន-ពៅ បានប្លន់បីកន្លែងក្នុងមួយថ្ងៃក៏មាន សូម្បីតែហាងប្តូរប្រាក់លី-ហ៊ួរ នៅជិតផ្សារអូឬស្សីក៏ ហ៊ុន-ពៅ ជាអ្នកប្លន់ដែរ ហើយ ហ៊ុន-ពៅ នេះគឺជាអ្នកនៅពីក្រោយឆាកសកម្មភាពក្មេងស្ទាវប្លន់រំដោះអ្នកទោស នៅតុលាការក្រុងភ្នំពេញ ហើយបញ្ជាអោយកងកំលាំងសំលាប់បំបិទមាត់ស្ទើរតែទាំងអស់ ទុកតែអ្នកដែលមិនដឹងថា ហ៊ុន-ពៅ បញ្ជាអោយប្លន់តែប៉ុណ្ណោះ ក្រោយមកខ្លាចបែករឿងសំងាត់ ហ៊ុន-ណារី បានបញ្ជូន ហ៊ុន-ពៅ ទៅកាន់ប្រទេសភូមា មួយរយះ។ តែបើតាមលោក ផន-ផល នៅបន្ទប់លេខ ១៧ អាគារអា នៃគុកព្រៃស បានប្រាប់ខ្ញុំថា ពួកគាត់គឺជាចោរ អាការ នៅខេត្តកណ្តាល នៅក្នុងក្រុមរបស់ពួកគាត់ភាគច្រើនសុទ្ធតែជាប៉ូលីស មួយក្តាប់តូចជាទាហ៊ាន ការធ្វើសកម្មភាពប្លន់ស្លៀកពាក់ស៊ីវិល ពេលខ្លះស្លៀកពាក់ឯកសណ្ឋានផងដែរ ប៉ុន្តែការប្លន់របស់ពួកគាត់ ភាគច្រើនប្រើកាំភ្លើង

អាការ ច្រើនជាប្រើកាំភ្លើងខ្លី ដូច្នេះរដ្ឋាភិបាលអោយរហ័ស្សនាមថា ចោរអាការ ។ លុយដែលបានមកពីប្លន់ ត្រូវចំណាយទៅលើប្រធានអង្គភាព ថ្នាក់លើមួយភាគធំ សល់បន្តិចបន្តួចយកទៅ ទិញថ្នាំជក់ ស៊ីផឹកស្រីស្រា សប្បាយអស់ តែបើមិនធ្វើអត់មានអីច្រកក្រពះ ព្រោះប្រាក់ខែតិច ជួនមិនទាំងបើកអោយទៀត គិតៗទៅ រកលុយអោយតែថ្នាក់លើតែប៉ុណ្ណោះ ព្រោះថ្នាក់លើគោះលុយមិនឈប់ ស៊ីមិនចេះឆ្អែត ទីបំផុតគឺ ថ្នាក់លើហ្នឹងឯងជាអ្នកចាប់ពួកគាត់ វាយដុំធ្វើទារុណកម្មរហូតគ្រាំក្នុងក្អួតឈាមតាមមាត់ បង្ខំអោយពួក គាត់ឆ្លើយតាមចិត្តដែលពួកគេចង់បាន ម្នាក់ៗសុទ្ធតែទទួលទោសចាប់ពី ១៥ឆ្នាំ រហូតដល់ ៣0 ឆ្នាំឡើងលើ ក៏មាន។ ចំណែកលោកសុខ-ធី ហៅ បូ-កាប់ឆៅ បាននិយាយថាគាត់គឺជាមនុស្សជំនិតរបស់ កែន-ចំរើន ពួកគាត់មិនចេះប្លន់ ឬធ្វើសកម្មភាពផ្តេសផ្តាស់ទេ គឺមើលទៅតាមកាលៈទេសៈ បើថ្នាក់លើបើកអោយធ្វើ គឺ ពួកគាត់ធ្វើ តែបើថ្នាក់មិនអនុញ្ញាតិទេ គឺពួកគាត់មិនធ្វើទេ ជាពិសេសនៅពេលបង្ក្រាបបាតុកម្មម្តង១គឺពួក គាត់សប្បាយរកលុយណាស់ ព្រោះអ៊ីគណៈបក្សប្រជាជនបើកដៃអោយពួកគាត់ធ្វើសកម្មភាពដោយសេរី ប៉ុន្តែបានលុយមកគឺត្រូវតែអោយថ្នាក់លើ បើមិនអញ្ចឹងទេ គឺត្រូវគេចាប់ដាក់គុក។ លោកសុខធី បានបន្ថែម ទៀតថាគាត់មិនមែនជាអ្នករៀនចេះដឹងអ្វីទេ ប៉ុន្តែតាមការជាក់ស្តែងដែលគាត់បានឃើញនោះគឺថាជីវិតជា ចោរ គឺរកលុយសំរាប់តែចិញ្ចឹមគេ មិនអាចធ្វើមានបានទេ ព្រោះថា បើមិនអោយថ្នាក់លើ ក៏ត្រូវយកលុយ សូកតុលាការដែរ ព្រោះថ្នាក់លើចាប់ដាក់គុក ហើយតុលាការជាអ្នកកាត់ទោស មិនខុសពីសែហ្វនិយាយទេ **បើជាប់គុកហើយគឺគេក្បៀបដូចអំពៅលុះត្រាតែអស់ទឹក** គុកមិនត្រឹមតែជាម៉ាស៊ីនក្បៀបទឹកអំពៅទេ តែ ពេលខ្លះក៏ជាទ្រុងសំរាប់រក្សាជ្រូក ទុកអោយតុលាការជាអ្នកកាប់សាច់យក។ ចំពោះលោក មុំ-ម៉េត វិញ មិនមែនធ្វើការអោយអង្គការអេស,អូ,វ៉ាយ នោះទេ ប៉ុន្តែគាត់គឺជាអង្គរក្សអាវខ្មៅរបស់លោក ហ៊ុន-សែន ក្រោយមកគេចឈប់ធ្វើដូរឈ្មោះមកជាមនុស្សធម្មតាវិញព្រោះអ៊ីគាត់ធុញទ្រាន់នឹងសំលាប់មនុស្សជារៀង រាល់ថ្ងៃដែលហ៊ុន-សែន តែងតែបញ្ជូគាត់អោយធ្វើដូចជាសំលាប់ពួកប្រឆាំង សំលាប់អ្នកដែល ហ៊ុន-សែន ទាស់ចិត្ត សំលាប់អង្គរក្សដែលត្រូវបំបិទមាត់ គឺសំលាប់មិនចេះចប់មិនចេះហើយ ដោយសារតែការធុញ

ទ្រាន់បែបហ្នឹងហើយ ទើបគាត់ដូរមុខរបរមករកស៊ីឆបោកវិញ ព្រោះគ្រាន់តែប្រើថ្វីមាត់ គឺអាចយកលុយបានដោយងាយ មិនចាំបាច់ប្រើកាំភ្លើងអ្វីឡើយ តែត្រូវតែបង់អោយទៅក្រសួងមហាផ្ទៃក្នុងមួយខែគឺចំនួន ១៥០ ដុល្លាសហរដ្ឋអាមេរិក រួមទាំងប្រាក់ខែរបស់គាត់ទៀតផង ព្រោះពួកគាត់សុទ្ធតែកាន់កាតពីរបីកន្លែង ដូចជាកាតប៉ូលីស កាតទាហ៊ាន កាតអង្គរក្ស,,,,,,,,។ល។ រីឯឈ្មោះ សយ-ចាន់ណា និងឈ្មោះបុត្រ ជាអង្គរក្សហ៊ុន-សែន នៅអាគារសេ នៃគុកព្រៃ ស បានប្រាប់ខ្ញុំនៅខែកុម្ភះ ឆ្នាំ ២០០៩ ថា ពួកគាត់ជាអង្គរក្សយាមផ្ទះ និងរត់តាមឡាន ហ៊ុន-សែន ពួកគាត់ពីមុនគ្រាន់តែជាក្មេងដើរលេងប៉ុណ្ណោះ ក្រោយមកក៏មានគ្នីគ្នាហៅចូលធ្វើជាអង្គរក្សព្រោះស្រួលរកលុយ តែពេលចូលស៊ុប គឺមេរបស់ពួគាត់នៅបន្ទាយ ជាប្រធានអង្គរក្សគិតតែពីគោះលុយ គោះស៊ីផឹកមិនឈប់ ហើយបង្ហាញពីផ្លូវរកលុយ ព្រមទាំងបញ្ជាក់ថា ធ្វើអ្វីក៏ដោយ ធានាមិនមានបញ្ហាឡើយ អោយតែគេចផុតពីកន្លែងកើតហេតុ ហើយរត់ចូលបន្ទាយបាន គឺអ្វីៗផុតហើយ មិនចាំបាច់បារម្ភទេ។ គ្រប់អងរក្ស សុទ្ធតែរកស៊ីប្លន់ រកស៊ីកាងបាញ់បោះ និងរកស៊ីមុខរបរមិនធម្មតា និងចេះប្រើប្រាស់ថ្នាំញៀនទាំងអស់។

**(៣)-អង្គការឧក្រិដ្ឋជនសំងាត់ អេស អូ វ៉ាយ ត្រូវបានប្រើប្រាស់សំរាប់ធ្វើបាតុកម្មស៊ីវិល**ដើម្បីវាយកំទេចគោលដៅ និងបង្រ្កាបបាតុកម្មដែលប្រឆាំងនឹងគណៈបក្សប្រជាជនកម្ពុជា ជាពិសេសគឺបង្រ្កាបនិងសំលាប់បាតុកម្មមហាជនស៊ីវិលដែលមាននិន្នាការសមានចិត្តគាំទ្រគណៈបក្សប្រឆាំងដូចជាព្រឹត្តិការណ៏សំលាប់រង្គាលបង្រ្កាបពួកបាតុកម្មស៊ីវិលដែលគាំទ្របក្សប្រឆាំងនៅខែកញ្ញាឆ្នាំ ១៩៩៨ នៅមុខរដ្ឋសភា មុខសណ្ឋាគារកាំបូដយ៉ាណា និងទល់វត្តបូទុម នៅក្បែរវត្តលង្ការ ដែលត្រូវបានសំលាប់ប្រជាជនស្លូតត្រង់ខ្មែរអស់រាប់រយនាក់ និងសំលាប់ពួកសមាជិកគណៈបក្ស។ នៅពេលនោះគឺគ្រាន់តែក្រុមលោក បូ-កាប់ឆៅ ដែលជាក្រុមបងតូចបងធំរបស់ពួកក្មេងអាណាថាតែមួយក្រុមគឺសំលាប់ប្រជាជនបានប្រមាណជាជាង ៦០ នាក់ ហើយចុះទំម្រមក្រុមបងតូចបងធំឯទៀតៗ ដែលលោក កែន-ចំរើន កែណ្ឌមកពីបណ្ដារខេត្តក្រុងផ្សេងៗទៀតទូទាំងប្រទេសនេះ តើសំលាប់ប្រជាជនខ្មែរបានចំនួនប៉ុន្មានទៅ? នៅពួកកងកំលាំងប្រដាប់អាវុធពួកអង្គរក្សស្ដេចចោរ ហ៊ុន-សែន ,,,,,,,,ដែលក្លែងបន្លំធ្វើជាបាតុករស៊ីវិលគាំទ្រគណៈបក្សប្រជាជនកម្ពុជា

រួមដៃសហការជាមួយអង្គការឧក្រិដ្ឋជនសំងាត់អេស-អូ-វ៉ាយ បានសំលាប់រង្គាលពួកបាតុកម្មប្រជាជនស៊ីវិល ដែលគាំទ្រពួកបក្សប្រឆាំងអស់ជាច្រើននាក់ទៀត ជាពិសេសនោះគឺពួកកងកំលាំងប្រដាប់អាវុធតែម្តងដែល បានចាប់ពួកបាតុករស៊ីវិលរបស់បក្សប្រឆាំងយកទៅសំលាប់ចោល និងយកទៅទំលាក់នៅជ្រោះពិចនិលទាំង រស់រាប់រយនាក់ទៀត នេះបើតាមសំដីរបស់លោក មុំ-ម៉េត ជាអង្គរក្សអាវឈុតខ្មៅរបស់អា ហ៊ុន-សែន បាន និយាយខ្ញុំនៅបន្ទប់លេខ ១៧ អាគារអា នៃគុកព្រៃ-ស នាខែមករា ឆ្នាំ ២០០៧ និង សូមមើលវិបសាយ វិដេអូ ស្តីពីពួកកងកំលាំងប្រដាប់អាវុធរបស់ ហ៊ុន-សែន និង ពួកអង្គការឧក្រិដ្ឋជនសំងាត់អេស-អូ-វ៉ាយ សំដែងសមត្ថភាពសំលាប់ប្រជាជនខ្មែរ និងព្រះសង្ឃខ្មែរយ៉ាងសាហាវនៅខែកញ្ញា ឆ្នាំ ១៩៩៨ ដើម្បីប្តូរយក **ឱកាសរកលុយពិសេស** ដែលគណៈបក្សប្រជាជនកម្ពុជានឹងផ្តល់អោយពួកគេបន្ទាប់ពី បង្ក្រាបបាតុកម្មហើយ

(1) http://www.youtube.com/watch?v=wzBWG3Uj4JM

--------->Hun Sen's armed forces and S.O.Y killing Khmer people and monk

(2).http://www.youtube.com/watch?v=9t7AYmx3saM&feature=related

--------->S.O.Y demonstraton with helping of CPP armed forces killed and rob Khmer people

3-) http://www.youtube.com/watch?v=QGNXN4X_eVw&NR=1) ។

**មូលហេតុអ្វីបានជាសមាជិកអង្គការឧក្រិដ្ឋជនសំងាត់ អេស-អូ-វ៉ាយ និងមនុស្សនៅក្នុងក្រុមបងតូចបងធំ ពេញចិត្តនឹងសំលាប់ប្រជាជនខ្មែរស្លូតត្រង់ដែលគ្មានគំនុំជាមួយខ្លួនយ៉ាងដូច្នេះ?**

ក្នុងការប្រើប្រាស់ពួកសមាជិកអង្គការឧក្រិដ្ឋជនសំងាត់ និងពួកក្រុមអ្នកលេងក្រុមបងធំបងតូចដែល បំរើអោយអង្គការឧក្រិដ្ឋជនសំងាត់ អេស,អូ,វ៉ាយ ដោយមិនដឹងខ្លួននោះ គណៈបក្សប្រជាជនកម្ពុជាមិន បានចំណាយអ្វីធំដុំឡើយ ផ្ទុយទៅវិញគណៈបក្សប្រជាជនកើបភោគផលទ្រព្យសម្បត្តិកំណប់ដ៏មហាសាល លុយដុល្លា ដ៏សន្ធឹកពីប្រជាជនខ្មែរ ដោយគ្រាន់តែប្រើប្រាស់ក្រុមបងតូចបងធំជាកត្តាលីករតែប៉ុណ្ណោះ គឺកើប លុយបាន យ៉ាងងាយស្រួលបំផុតពីប្រជាជនខ្មែរ តាមរយៈលួចឆក់ប្លន់ជិះតលក់គ្រឿងញៀនឆបោក,,,,,,,,,, មិនត្រឹមតែចំណេញផ្នែកសេដ្ឋកិច្ចប៉ុណ្ណោះទេ គឺគណៈបក្សប្រជាជនកម្ពុជាថែមទាំងប្រើប្រាស់ពួកសមាជិក អង្គការឧក្រិដ្ឋជនសំងាត់ អេស អូ វ៉ាយ និងក្រុមបងតូចបងធំក្នុងផ្នែកនយោបាយទៀតដូចជាប្រើប្រាស់ អោយដើរតួជាបាតុករសំរាប់ការពារផលប្រយោជន៏គណៈបក្សប្រជាជន និងផលប្រយោជន៏យួនដូចជាករណី

ធ្វើបាតុកម្មវាយដុតស្ថានទូតថៃ ធ្វើបាតុកម្មបំរើឱ្យគោលបំណងរបស់គណៈបក្សប្រជាជន និងដើរតួនាទីជាបាតុកម្មស៊ីវិលដើម្បីបង្ក្រាបបាតុកម្មស៊ីវិលរបស់បក្សប្រឆាំង ដូចជាករណីបង្ក្រាបបាតុកម្ម នៅខែកញ្ញា ឆ្នាំ ១៩៩៨ ដែលរៀបចំឡើងដោយគណៈបក្សប្រជាជនកម្ពុជា ដោយចាត់អោយកងកំលាំងប្រដាប់អាវុធ រួមសហការជាមួយពួកសមាជិកអង្គការឧក្រិដ្ឋជនសំងាត់ អេស.អូ.វ៉ាយ ទៅ សំលាប់បង្ក្រាបបាតុកម្មប្រជាជនស៊ីវិលដែលគាំទ្របក្សប្រឆាំង។ នៅក្នុងការសំលាប់បង្ក្រាបបាតុកម្មប្រជាជនស៊ីវិលដែលគាំទ្របក្សប្រឆាំងនេះ ហ៊ុន-សែន បាន បានបញ្ជាអោយកំលាំងរបស់អង្គការឧក្រិដ្ឋជនសំងាត់ អេស.អូ.វ៉ាយ ដែលមានក្រុមបងតូចបងធំ និងបណ្តុញក្រុមជនអន្ធពាលជាសកម្មជននោះ អោយដើរតួជាបាតុករស៊ីវិលគាំទ្រគណៈបក្សប្រឆាំងដោយមានក្រុមកងកំលាំងប្រដាប់អាវុធស្លៀកពាក់ស៊ីវិល និងក្រុមអង្គរក្សពួកមេដឹកនាំកំពូល១ចូលរួមក្លែងជាបាតុករ ដើម្បីធ្វើបាតុកម្មបង្ក្រាបបាតុកម្មស៊ីវិលរបស់ប្រជាជនខ្មែរ និងបង្ក្រាបបាតុកម្មរបស់ពួកគណៈបក្សប្រឆាំង។ នៅពេលថ្នាក់លើ ពិសេស ហ៊ុន-សែន មានការខ្លាចរអារនឹងប្រើកងកំលាំងប្រដាប់អាវុធសំលាប់រង្គាលបាតុករនៅក្នុងបាតុកម្មរបស់គណៈបក្សប្រឆាំង ហ៊ុន-សែន បានប្តូររូបភាពមកប្រើពួកក្រុមអង្គការឧក្រិដ្ឋជនសំងាត់ អេស.អូ.វ៉ាយ អោយដើរតួក្លែងភេទជាបាតុករស៊ីវិល ទៅសំលាប់រង្គាលពួកគណៈបក្សប្រឆាំងជំនួសអោយកងកំលាំងប្រដាប់អាវុធរបស់គណៈបក្សប្រជាជនវិញ នៅក្នុងខែកញ្ញា ឆ្នាំ ១៩៩៨។ នៅពេលដែលលោក កែន-ចំរើន បានទទួលបញ្ជាពី ហ៊ុន-សែន ហើយ គាត់បានបញ្ជាទៅពួកមេបងធំ និងពួកមនុស្សជំនិតរបស់គាត់អោយប្រមូលកំលាំងអោយបានច្រើនដើម្បីធ្វើបាតុកម្ម បង្ក្រាបបាតុកម្មពួកប្រឆាំង ហើយលោក កែន-ចំរើន បានបញ្ជាទៅឈ្មោះ បូកាប់ឆៅ (Source$^{A6\ and\ A7}$)អោយទៅប្រាប់ពួកមេដឹកនាំក្រុមបងតូចបងធំទាំងអស់នៅក្នុងក្រុងភ្នំពេញ ដែលមានជាង ៦០ ក្រុម អោយប្រមូលមនុស្ស និងក្រុមបក្សពួករបស់ខ្លួនដើម្បីធ្វើបាតុកម្មបង្ក្រាបពួកប្រឆាំង ថែមទាំងបង្ហើបនៅ**ឱកាសរកលុយពិសេស**ផងមានន័យថារដ្ឋអំណាចរបស់គណៈបក្សប្រជាជនកម្ពុជាទុកពេលអោយពួកក្រុមបងតូចបងធំ និងសមាជិកបក្សពួកនៅក្នុងអង្គការឧក្រិដ្ឋជនសំងាត់ អេស.អូ.វ៉ាយ មានឱកាសរកលុយដោយសេរីនៅក្នុងរយៈពេលចាប់ពី ៣

ថ្ងៃ ទៅ ១ សប្តាហ៍ ឬទៅមួយខែ ទៅតាមក្រុមបងតូចបងធំនិមួយៗដែលសំរេចស្នាដៃនៅក្នុងការបង្រ្កាប ល្អ ឬមិនល្អ គុណភាពប្រសិទ្ធិភាពនៅក្នុងការបង្រ្កាបនោះ ធ្វើអោយគណះបក្សប្រជាជនពេញចិត្ត ឬអត់? ហើយនៅក្នុងឱកាសរកលុយដែលមានថេរៈវេលាកំណត់ដែលគណះបក្សប្រជាជនកម្ពុជាផ្តល់អោយពួកគេ គឺបានសេចក្តីថា ពួកបងតូចបងធំ ពួកក្រុមជនអន្ធពាល និងបក្សពួករបស់ពួកគេ ដែលស្ថិតនៅក្នុងអង្គការឧក្រិដ្ឋជនសំងាត់ អេស,អូ,វ៉ាយ នោះ មានសិទ្ធិនៅក្នុងការរកលុយដោយការលួចឆក់ប្លន់ជីវិត ឃាតកម្ម ស៊ីឈ្នួល ជួញដូរមនុស្ស ជួញដូរថ្នាំញៀន ឬការរកលុយដោយមធ្យោបាយណាក៏ដោយ គឺមិនមានទោសពៃ មិនមានការចាប់ចងអ្វីឡើយ គឺគណះបក្សប្រជាជនកម្ពុជាអនុញ្ញាតិអោយពួកគេធ្វើ នៅក្នុងឱកាសពិសេសដែលមានអាទិភាពដូចមានលិខិតបេសកកម្មរបស់ ហ៊ុន-សែន នៅក្នុងដៃ។ នៅពេលដែល ពួកបងតូចបងធំ ពួកក្រុមជនអន្ធពាល និងបក្សពួករបស់ពួកគេ ដែលស្ថិតនៅក្នុងអង្គការឧក្រិដ្ឋជនសំងាត់ អេស,អូ,វ៉ាយ បានដំណឹងពី **ឱកាសរកលុយពិសេស** ពីថ្នាក់លើរបស់ពួកគេហើយ ពួកគេចាប់ផ្តើមមានកំលាំងចិត្តសប្បាយរីករាយឥតឧបមានឹងលាភសក្ការៈដែលគណៈបក្សប្រជាជននឹងផ្តល់អោយពួកគេ ហើយនៅពេលវេលាមកដល់ លោក កែន-ចំរើន បានរៀបចំក្បួនយុទ្ធសាស្រ្តប្រៀបបីដូចជា យុទ្ធសាស្រ្តទាហ៊ាន ដោយគាត់បានប្រមូលផ្តុំ ពួកបងតូចបងធំ ពួកក្រុមជនអន្ធពាល និងក្រុមបក្សពួករបស់ពួកគេ ដែលស្ថិតនៅក្នុងអង្គការឧក្រិដ្ឋជនសំងាត់ អេស,អូ,វ៉ាយ ហើយបានរៀបចំជា ៣ ខ្សែត្រៀមមុននឹងចូលវាយប្រហារដើម្បីសំលាប់ពួកហ្វូងបាតុករប្រជាជនខ្មែរដែលធ្វើបាតុកម្មប្រឆាំងនឹងគណះបក្សប្រជាជន។ ពួកបងតូចបងធំ ពួកហ្វូងជនអន្ធពាល និងបក្សពួកក្រុមកងកំលាំងប្រដាប់អាវុធ ក្រុមអង្គរក្សដែលស្ថិតនៅក្នុងអង្គការឧក្រិដ្ឋជនសំងាត់ អេស,អូ,វ៉ាយ ត្រូវបានបែងចែកជា ៣ខ្សែត្រៀមដូចតទៅនេះ

-**ខ្សែត្រៀមទី១** គឺពួកគេប្រដាប់ដោយអាវុធបន្ទាប់បន្សំដូចជា កាំបិតតាំងតោ ពូថៅ កាំបិតខ្វី ដាវ ដំបងព្រនង់ ដំថ្ម,,,,,,,,,មានទាំងទុងគណះបក្សប្រជាជនកម្ពុជាផងដែរ នេះគ្រាន់តែខ្សែត្រៀមបញ្ឆោតពួកអ្នកកាសែតអន្តរជាតិ ពួកអ្នកសារពត៏មានអន្តរជាតិ ព្រោះនៅគ្រាដំបូងមិនទាន់ជ្រួលច្របល់អាចត្រូវថតបាន។

| | |
|---|---|
|  https://www.msu.edu/course/iss/325/stein/revolt.htm | **ខ្មែរក្រៀមទី១** នៃក្បួនបាតុកម្មរបស់ពួកសមាជិកអង្គការឧក្រិដ្ឋជនសំងាត់ S.O.Y អេស,អូ,វ៉ាយ ដែលត្រូវបាន បញ្ជា និងរៀបចំដោយ ហ៊ុន-សែន និងគណៈបក្សប្រជាជនកម្ពុជាដើម្បីសំលាប់រង្គាលហ្វូងបាតុកម្មរបស់ពួកគណៈបក្សប្រឆាំងដើម្បីប្តូរនឹង **ឱកាសរកលុយពិសេស** ដែលគណៈបក្សប្រជាជនកម្ពុជាផ្តល់ដល់ពួកគេ បន្ទាប់ពីបញ្ចប់បេសកកម្ម។ |
|  **ខ្មែរក្រៀមទី១-ទី២- ទី៣** នៃក្បួនបាតុកម្មអង្គការឧក្រិដ្ឋជនសំងាត់អេស,អូ,វ៉ាយ | **ខ្មែរក្រៀមទី១-ខ្មែរក្រៀមទី២-ខ្មែរក្រៀមទី៣** នៃក្បួនបាតុកម្មរបស់ពួកសមាជិកអង្គការឧក្រិដ្ឋជនសំងាត់ S.O.Y អេស,អូ,វ៉ាយ ដែលត្រូវបាន បញ្ជានិងរៀបចំដោយ ហ៊ុន-សែន និងគណៈបក្សប្រជាជនកម្ពុជាកំពុងដង្ហែរក្បួនមកសំលាប់រង្គាលពួកហ្វូងបាតុកម្មរបស់ពួកគណៈបក្សប្រឆាំងដើម្បីប្តូរនឹង **ឱកាសរកលុយពិសេស** ដែលគណៈបក្សប្រជាជនកម្ពុជាផ្តល់ដល់ពួកគេ បន្ទាប់ពីបញ្ចប់បេសកកម្មរួចរាល់។ |

-**ខ្មែរក្រៀមទី២** គឺពួកគេត្រូវបានបំពាក់ទៅដោយអាវុធដូចខ្មែរក្រៀមទី១ដែរ ប៉ុន្តែមានលាយឡំនឹងកាំភ្លើងខ្លី និងកាំភ្លើងមួយចំនួនដទៃទៀត (Source$^{D5}$)។ ខ្មែរក្រៀមនេះសំលាប់ពួកហ្វូងបាតុកម្មប្រឆាំងមិន

ស្លាប់បានច្រើនទេ តែសំរែកឈឺចាប់ពួកគេមុន ស្លាប់ងាយនឹងធ្វើអោយពួកបាតុករប្រឆាំងបាក់ស្បាតរាងចាល មិនហ៊ានធ្វើទៀតនៅថ្ងៃក្រោយ ។

-**ខ្សែត្រៀមទី៣** គឺត្រូវបានបំពាក់អាវុធដូចខ្សែត្រៀមទី១ ខ្សែត្រៀមទី២ដែរ ប៉ុន្តែពួកគេត្រូវបានបំពាក់បន្ថែមដោយកាំភ្លើងខ្លី កាំភ្លើងវែង កាំភ្លើងពាក់កណ្តាលស្វ័យប្រវត្តិដូចជា A-K, M-16………. ហើយនៅក្នុងខ្សែត្រៀមទី៣នេះ ពួកសមាជិកដែលស្ថិតនៅក្នុងអង្គការឧក្រិដ្ឋជនសំងាត់ អេស,អូ,វ៉ាយ ច្រើនតែជាពួកកងកំលាំងប្រដាប់អាវុធស្លៀកពាក់ស៊ីវិល ពួកចារបុរសស៊ើបការណ៏របស់គណះបក្សប្រជាជន និងពួកកងអង្គរក្សរបស់ ហ៊ុន-សែន ដូច្នេះពួកគេមានសមត្ថភាពខ្ពស់អាចសំលាប់មនុស្សបានច្រើនបំផុត ហើយមានប្រសិទ្ធភាពជាងខ្សែត្រៀមទី១ និងខ្សែត្រៀមទី២ នៃ អង្គការឧក្រិដ្ឋជនសំងាត់ អេស,អូ,វ៉ាយ ។

នៅក្នុងការបង្រ្កាបសំលាប់ពួកហ្វូងបាតុកម្មប្រឆាំងនេះ លោក កែន-ចំរើន មិនត្រឹមតែរៀបក្បួនយុទ្ធសាស្រជា ៣ ខ្សែត្រៀមប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានបញ្ជាអោយក្រុមហ្វូងមនុស្សរបស់អង្គការឧក្រិដ្ឋជនសំងាត់ អេស,អូ,វ៉ាយ អោយផ្លាស់ប្តូរក្បួនពីខ្សែត្រៀមមួយទៅកាន់ខ្សែត្រៀមមួយទៀតដើម្បីវាយប្រយុទ្ធសំលាប់ពួកហ្វូងបាតុកម្មប្រឆាំងអោយមានប្រសិទ្ធភាពខ្ពស់ ។ ក្នុងពេលផ្លាស់ប្តូរក្បួនខ្សែត្រៀមនេះ ពួកហ្វូងបាតុកម្មរបស់អង្គការឧក្រិដ្ឋជនសំងាត់ អេស,អូ,វ៉ាយ នៃត្រៀមទី១ បែងចែកគ្នាសំរាក ដើម្បីរកលុយជាបណ្តើរៗ អ្នកខ្លះប្លន់សំលាប់នៅកន្លែងផ្សេងៗ អ្នកខ្លះវាយយកម៉ូតូនៅជិតក្បែរបរិវេណបាតុកម្ម អ្នកខ្លះលួចឆក់ ,,,,,,,,លួមតែបាតុកម្មចប់សព្វគ្រប់ពួកគេអាចកើបលុយបានយ៉ាងច្រើនក្រាស់ក្រែលបានមួយចំនួនទៅហើយ ។ លុះដល់ពេលរាត្រី គណះបក្សប្រជាជនចាប់ផ្តើមផ្តល់រង្វាន់អោយដល់ពួកហ្វូងមនុស្សរបស់អង្គការឧក្រិដ្ឋជនសំងាត់ អេស,អូ,វ៉ាយ ទៅតាមតួនាទី និងឋានៈរបស់ពួកគេ គឺពួកមេក្រុមតូចៗ ក្នុងម្នាក់ៗទទួលបាន ១០០ ដុល្លា ក្នុងមួយថ្ងៃ (Source$^{A8\ and\ A9}$) ហើយសមាជិកធម្មតាអាម៉ីអាថោងតូចតាច ក្នុងម្នាក់ៗទទួល បានចំនួន ២០០០០ រៀល (ពីរម៉ឺនរៀល) ក្នុងមួយថ្ងៃ រួមទាំងការផ្តល់អាហារមានបាយកញ្ចប់ ស្រា បារី ចំណីអាហារផ្សេងៗ ថ្នាំយ៉ាម៉ាទាំងចានៗ ថ្នាំខេ ថ្នាំគ្រឺ និងថ្នាំញៀន

ហៅរ៉ូអ៊ីន ទៅតាមគុណសម្បត្តិនិងឋានៈនៅក្នុងក្រុមបងតូចបងធំរបស់ពួកគេ អ្នកខ្លះមានឋានៈតូចជាមនុស្សធម្មតានៅក្នុងក្រុម ប៉ុន្តែសំលាប់មនុស្សបានច្រើននៅក្នុងពេលបង្រ្កាបពួកបាតុកម្មប្រឆាំង នោះអាចមានសិទ្ធិជ្រើសរើសថ្នាំញៀនដោយសេរី និងត្រូវបានមនុស្សក្នុងក្រុមសរសើរលើកទឹកចិត្ត រួមទាំងពាក្យសរសើរបញ្ជោរពីលោកបងធំរបស់ពួកគេទៀតផងនៅក្នុងពិធីជប់លៀង ដែលរៀបចំឡើងដោយគណៈបក្សប្រជាជនកម្ពុជា ពួកគេផឹកស៊ីប្រូកប្រាជ្ញរហូតដល់ម្នាក់ៗស្រវឹង និង ង៉ាងថ្នាំរៀង១ខ្លួន អ្នកខ្លះឆ្លៀតរកលុយក្នុងពេលកំពុងផឹកស៊ី ហើយថែមទាំងយកខ្សែករ ជញ្ជៀន លុយ មក បង្ហាញលោកបងធំ និងក្រុមមនុស្សនៅក្នុងក្រុមពួកគេដោយនិយាយថា " លោកបង! ពួកខ្ញុំគ្រាន់តែចេញក្រៅមួយភ្លែតបានប៉ុណ្ណេះ ( ដោយលើកបង្ហាញខ្សែករក្រវិលពេជ្រ ចិញ្ចៀន លុយ) ចំណែកម៉ូតូវិញ ពួកខ្ញុំយកទៅទុកក្នុងឡហើយ ទុកអោយលោកបងធំជាអ្នកចាត់ចែង ! លោកបងធំរបស់ពួកគេ ក៏និយាយទៅកាន់ហ្វូង មនុស្សរបស់ខ្លួនថា ពួកឯងទាំងអស់ឃើញទេ! ពួកវាពូកែណាស់! គ្រាន់តែជប់លៀងផឹកស៊ីប៉ុណ្ណឹងក៏ឆ្លៀតរកលុយបានដែរ! ពួកឯងទាំងអស់កុំភ្លេច! ឱកាសពិសេសរកលុយរបស់យើងមានតែប៉ុន្មានថ្ងៃទេ រួសរាន់ ប្រញាប់ឡើង ! កុំអោយខកពេល! ពេលនោះពួកហ្វូងមនុស្សនៅក្នុងក្រុមបងតូចបងធំរបស់ពួកគេ ក៏ចាប់ផ្តើមចេញទៅរកលុយរៀង១ខ្លួនទៅតាមជំនាញរបស់ពួកគេ ដូចជា លួច ឆក់ ប្លន់ ជិះរិត សំលាប់ ជួញដូរគ្រឿងញៀន ជួញដូរមនុស្ស វាយដំប្រហារគ្នាតាមផ្លូវ លួចគាស់ផ្ទះ បុកហាង បុកទូរមាស,,,,,,,,,,,។ល។ និង ។ល។ សមដូចសំដីរបស់ លោកសុខ-ធីបាននិយាយថា "សំលាប់មនុស្សតែមួយថ្ងៃ មានឱកាសរកលុយបានរាប់ខែណា៎!"។

លោក កែន-ចំរើន ដែលប្រធានអង្គការឧក្រិដ្ឋជនសំងាត់ អេស.អូ.វ៉ាយ តែងតែសំដែងនៅក្តីគោរព និងសរសើរដល់លោក ជា-សុផារ៉ា ជានិច្ច ហើយតែងតែហៅលោក ជា-សុផារ៉ា ថា "ប៉ាប៉ា!! "មិនដាច់ពីមាត់ឡើយក្នុងការទំនាក់ទំនងក្នុងផ្លូវមិនធម្មតា ព្រោះអ៊ីលោក ជា-សុផារ៉ា ជាអ្នកផ្តល់គំនិតអោយដល់ ហ៊ុន-សែន នៅក្នុងការបង្កើតក្រុមបងតូចបងធំ បង្កើតអង្គការឧក្រិដ្ឋជនសំងាត់ អេស.អូ.វ៉ាយ ក្នុងការប្រមូលលុយចំណូលចូលគណៈបក្សប្រជាជនកម្ពុជា និងប្រើប្រាស់ជាឧបករណ៍សំលាប់មនុស្សពួកបក្សប្រឆាំងយ៉ាងមានប្រសិទ្ធិភាពបំផុត ជាពិសេសគ្រាន់តែបិទផ្លាកពួកអ្នកស្លាប់ថាមានរឿងជាមួយពួកក្រុម

អន្ធពាល និងក្រុមបងធំ មានរឿងដោយសារស្រី រឿងចោរប្លន់សំលាប់ រឿងឈ្លោះគ្នាសំលាប់ច្រលំ រឿងរាលកែកាំភ្លើង រឿងជំពាក់លុយ រឿងប្រដែងរបររកស៊ី រឿងជួលគេសំលាប់ដោយសារទំនាស់ រឿងទំនាស់គ្រួសារ រឿងឧប្បត្តិហេតុ រឿងផ្ដើលរត់ជាន់គ្នាស្លាប់ រឿងលិចទូកស្លាប់អស់១ទូក,,,,,, ។ល។ និង ។ល។ នោះ គឺសុទ្ធតែជារឿងឃាតកម្មសំលាប់បំបិទមាត់ទាំងអស់ មិនមែនរឿងឧប្បត្តិហេតុទេ ប៉ុន្តែគណៈបក្សប្រជាជនកម្ពុជាតែតែបង្វែងដានទៅជារឿងផ្សេង ដើម្បីគេចចេញពីការទទួលខុសត្រូវនៅរាល់អំពើដឹខៅ្រក្រខ្វក់និងសាហាវយង់ឃ្នងរបស់ខ្លួនតែប៉ុណ្ណោះ ។

អង្គការឧក្រិដ្ឋជនសំងាត់ អេស.អូ.វ៉ាយ ត្រូវបានគណៈបក្សប្រជាជនប្រើប្រាស់ដើម្បីបំរើផលប្រយោជន៍ប្រជាជាតិយួនផងដែរ ក្នុងពេលអារ្យធម៌ថៃ ខ្សែភាពយន្តថៃ ទំនិញផលិតផលថៃ បានហូរចូលយ៉ាងគំហុកចូលមកកម្ពុជា ហើយជាទីពេញនិយម និងមានប្រជាប្រិយភាពបំផុតរបស់ប្រជាជនខ្មែរ ធ្វើឱ្យប្រទេសយួនលំបាកក្នុងការបង្ហូរទំនិញចូលមកលក់ស្រុកខ្មែរ ទោះបីជាយួនខំប្រឹងធ្វើទំនិញក្លែងក្លាយលក់ដោយសេរីក្នុងប្រទេសខ្មែរយ៉ាងណាក៏ដោយ ក៏នៅតែមិនអាចទៅរួច ដូច្នេះមានតែបញ្ជ ហ៊ុន-សែន រកមធ្យោបាយកាត់បន្ថយឥទ្ធិពលថៃ មូលហេតុនេះហើយ ទើប ហ៊ុន-សែន សំរេចអោយលោក ជា-សុផារ៉ា និង លោក កែន-ចំរើន ប្រើប្រាស់អង្គការឧក្រិដ្ឋជនសំងាត់ អេស.អូ.វ៉ាយ អោយក្លែងធ្វើជាបាតុកម្មស៊ីវិល ឬបាតុកម្មប្រជាជនដើម្បីវាយកំទេចគោលដៅប្រម៉ាញ់ដែល ហ៊ុន-សែន និងយួន ចង់បាននោះ។ ដំបូងទីនៃរូបភាពបាតុកម្មគឺឃើញមានសុទ្ធតែពួកក្រុមក្មេងស្ទាវរបស់អង្គការឧក្រិដ្ឋជនសំងាត់ អេស.អូ.វ៉ាយ ជិះម៉ូតូទាំងហ្វូង១តាមថ្នល់ស្រែកហ៊ោរកញ្ជ្រៀវពាសពេញក្រុងភ្នំពេញ រួមទាំងមានពាក្យជេរប្រមាថដល់តារាខ្សែភាពយន្តថៃ ហៅនាងផ្កាយព្រឹក ដោយឆ្ពោះតំរង់ទៅ រកអត្ថន័យ "ស្រីថៃចង់បានអង្គរវត្តខ្មែរ" បន្ទាប់មកពួកគេបង្កើតភាពជ្រួលច្របល់កាន់តែខ្លាំងទៅ១តាមរយៈ ប្រពន្ធ័ឃោសនារបស់រដ្ឋាភិបាល មានកាសែត វិទ្យុ ទូរទស្សន៍ ទស្សនាវដ្ដី ព្រឹត្តិប័ត្រ និងប្រព័ន្ធឃោសនារបស់ម៉ាហ្វីយ៉ា ដូចជាកាសែតរស្មីកម្ពុជារបស់លោក ថេង-ប៊ុន និងការជួយផ្សព្វផ្សាយតគ្នាពីតំបន់មួយទៅតំបន់របស់ក្រុមបងតូចបងធំ ក្រុមជនអន្ធពាល ដែលដើរតួគ្រប់ប្រភេទមនុស្សតាំងពីតួអង្គរត់មូតូឌុបរហូតដល់មន្ត្រីរាជការ និងកងកំលាំងប្រដាប់អាវុធ បន្ថែមលើល្បិចឆ្កែព្រុសរបស់អា ហ៊ុន-សែន ផងនោះ ធ្វើអោយផុសពត៏មានគ្រប់ទីកន្លែងធ្វើវិទ្ធង្សនាប្រឆាំងនឹងថៃ តាមរយៈពាក្យចចាមអារាមផ្សាយត១គ្នាចេញពីពួកក្រុមមនុស្សនៅក្នុង ក្រុមបងតូចបងធំ និងពួកសមាជិក

របស់ អង្គការឧក្រិដ្ឋជនសំងាត់ អេស,អូ,វ៉ាយ ហើយធ្វើឱ្យបញ្ហាវិបត្តិរីកធំទៅៗឈានដល់ក្បួនបាតុកម្មទ្រង់ទ្រាយធំ បុកសំដៅទៅគោលដៅសំខាន់ៗរបស់ថៃ ហើយចូលទៅវាយកំទេច លួចប្លន់ និងដុតបំផ្លាញទីតាំងផ្សេងៗរបស់ថៃដូចជា វាយកំទេច និងវាយដុតបំផ្លាញមជ្ឈមណ្ឌល (Source$^{D7}$) និងរោងផលិត

| | |
|---|---|
|  [http://www.2bangkok.com/burning.shtml](http://www.2bangkok.com/burning.shtml) | The offices of Cambodia Shinawatra Telecommunications, firebombed, windows smashed, with masonry damage. |
|  | |



Thai owned soft drinks cannery virtually razed to the ground

http://www.2bangkok.com/burning.shtml

ភេសជ្ជៈកំប៉ុងថៃ,,,,,,,,, ហើយទីបំផុតរហូតដល់ឈានចូលទៅវាយដុតកំទេចស្ថានទូតថៃប្រចាំក្រុងភ្នំពេញ នាថ្ងៃទី ៣១ ខែមករា ឆ្នាំ ២០០៣ គឺជាបាតុកម្ម ធ្វើឡើងដោយហ្វូងក្មេងពាលនៅក្នុងក្រុមពួកជនអន្ធពាល




ស្ថានទូតថៃប្រចាំក្រុងភ្នំពេញ ត្រូវបានពួកក្រុមបងតូចបងធំនៅក្នុងអង្គការឧក្រិដ្ឋជនសំងាត់ អេស,អូ,វ៉ាយ ( ត្រូវបានបញ្ជូដោយគណៈបក្សប្រជាជនកម្ពុជា) វាយកំទេច ដុតបំផ្លាញដើម្បីប្តូរនឹងឱកាសរកលុយពិសេស ។ បើសង្រ្គាមកើតឡើង រដ្ឋាភិបាលអាយ៉ងយួន ដឹកនាំដោយ ហ៊ុន-សែន នឹងសំលាប់រង្គាលប្រជារាស្ត្រខ្មែរដើម្បីសងសឹងនឹងភ្នែកខ្វាក់ម្ខាងរបស់ខ្លួន ដោយគ្រាន់តែយកលេសសង្រ្គាមខ្មែរ-ថៃ ក្តោបអំណាចផ្តាច់មុខទាំង

| | |
|---|---|
| | ៣ ក្នុងដៃ ហើយសំលាប់ជាតិខ្មែរដោយចោទថា ខ្មាំង ឬជាចារជនរបស់ថៃតែប៉ុណ្ណោះ ។ http://www.2bangkok.com/burning.shtml |



***ឱកាសរកលុយពិសេស** = ការអនុញ្ញាតិអោយពួកក្រុមបងតូចបងធំ នៅក្នុងអង្គការឧក្រិដ្ឋជនសំងាត់ អេស,អូ,វ៉ាយ មានឯកសិទ្ធិពិសេសក្នុង ការលួចឆក់ប្លន់ជីវិតសំលាប់ ជួញដូរគ្រឿងញៀន ជួញដូរមនុស្ស ឃាតកម្មស៊ីឈ្នួល,,,,,,ដោយគ្មានការចាប់ចង យកទោសពៃអ្វីឡើយ ទៅតាមពេលវេលាកំណត់ជាក់លាក់របស់គណះបក្សប្រជាជនកម្ពុជាដែលបានអនុញ្ញាតិឱ្យពួកគេធ្វើអ្វី បន្ទាប់ពីពួកគេបានសំរេចស្នាដៃសមិទ្ធិផលឱ្យគណះបក្សប្រជាជនកម្ពុជារួចហើយនោះ ។




Rioters set fire to the Thai embassy and attacked Thai-owned businesses in Phnom Penh
http://news.bbc.co.uk/2/hi/asia-pacific/2709261.stm



They were angry at alleged remarks by a Thai actress, saying Angkor Wat belonged to Thailand
http://news.bbc.co.uk/2/hi/asia-pacific/2709261.stm




Many people were injured, and one was killed, as protesters burned and looted buildings

http://news.bbc.co.uk/2/hi/asia-pacific/2709261.stm

រូបភាពទាំងនេះគឺជាក្រុមបងតូចបងធំនៅក្នុងអង្គការឧក្រិដ្ឋជនសំងាត់ អេស,អូ,វ៉ាយ ដែលខំប្រឹងសំដែងសមត្ថភាពវាយកំទិចដុតបំផ្លាញស្ថានទូតថៃប្រចាំនៅក្រុងភ្នំពេញ ដុតរូបព្រះមហាក្សត្រថៃ និង ដុតទុងជាតិថៃ ដើម្បីប្តូរនឹង **ឱកាសរកលុយពិសេស** ដែលគណះបក្សប្រជាជនកម្ពុជានឹងផ្តល់ឱ្យពួកគេរយៈពេល ៣ថ្ងៃ ឬ ១អាទិត្យ ទៅ ១ខែ តាមសមត្ថភាពរបស់ពួកគេ។

និងពួកក្រុមបងតូចបងធំ (Source[D8]) របស់អង្គការឧក្រិដ្ឋជនសំងាត់ អេស,អូ,វ៉ាយ ដែលដឹកនាំដោយលោក កែន-ចំរើន ជាប្រធានអង្គការឧក្រិដ្ឋជនសំងាត់ អេស,អូ,វ៉ាយ ហើយត្រូវបានបញ្ជូរឱ្យធ្វើ បាតុកម្មដោយ ហ៊ុន-សែន និង លោក ជា-សុផារ៉ា នៅក្នុងគោលដៅបំរើផលប្រយោជន៏ចៅហ្វាយយួនរួមគ្នា និង ជួយអភិវឌ្ឍន៏សេដ្ឋកិច្ចយួន និងជួយពង្រីកទីផ្សារបញ្ចេញទំនិញរបស់យួនអោយបានកាន់តែឆាប់រហ័សទៀតផងគឺផលប្រយោជ៏ពាណិជ្ជកម្មយួនតែម្តង ព្រោះថាបានបាតុកម្មរបស់ពួកក្រុមបងតូចបងធំនៃ អង្គការឧក្រិដ្ឋជនសំងាត់ អេស,អូ,វ៉ាយ វាយប្រហារដុតបំផ្លាញស្ថានទូតថៃប្រចាំក្រុងភ្នំពេញ និងមជ្ឈមណ្ឌលពាណិជ្ជកម្មថៃ

និងកន្លែងផ្សេងៗទៀតរបស់ថៃនោះ គឺមិនមែនពួកគេធ្វើឡើងដោយគំនិតជាតិនិយមអ្វីឡើយ សូមមើលរូបៈ



http://reatreygirl.blogspot.com/2009_10_16_archive.html

( គ្រាន់តែប្រជាជនខ្មែរនៅខេត្តស្វាយរៀង និងលោក សម-រង្ស៊ី បានដកបង្គោលព្រំដែនដែលយួនឈ្លានពានចូលពី ៣០០ ម៉ែត្រ ទៅ ៥០០ ម៉ែត្រ ចូលក្នុងដីខ្មែរនោះ លោក សម-រង្ស៊ី ត្រូវបានពួកតុលាការអាយ៉ងយួនកាត់ទោសឱ្យជាប់គុក ២ ឆ្នាំ ពីបទបំផ្លិចបំផ្លាញទ្រព្យសម្បត្តិសាធារណៈ និងអំពីបទញុះញង់ឱ្យមានការបែងចែកពូជសាសន៍ ) ប៉ុន្តែធ្វើឡើងក្នុងគោលបំណងធ្វើរដ្ឋប្រហារសេដ្ឋកិច្ចថៃ ដោយយកលេសលើបញ្ហាទាំងនេះ ដើម្បីរាំងខ្ទប់ពាណិជ្ជកម្មថៃមិនអោយទំនិញរបស់ថៃនាំចូលមកប្រទេសកម្ពុជាដោយងាយស្រួលនោះទេ និងបង្កើតចេញជាផលវិបាកផ្សេងៗជាសេរីនៃទំនាស់ ទោះបីរដ្ឋាភិបាលអាយ៉ងយួនបានសងប្រទេសថៃ ចំនួន ៤៣លានដុល្លាសហរដ្ឋអាមេរិកក៏ដោយ ក៏ជនជាតិយួននៅតែចាត់ទុកថាចំណេញ សមដូចជនជាតិយួនម្នាក់ដែលស្លៀកពាក់ជាឯកសណ្ឋានប៉ូលីសខ្មែរនៅព្រែកអែមបាននិយាយថា "**សងថៃ ៤៣ លានដុល្លាគឺមិនខាតទេ បើយើងយកលុយ ៤៣ លានដុល្លា ទៅទិញទឹកចិត្តប្រជារាស្ត្រខ្មែរអោយឈប់ស្រឡាញ់ចូលចិត្តថៃ ឬកាត់បន្ថយឥទ្ធិពលថៃនោះ គឺមិនបានទេ ឥឡូវនេះពួកយើងមិនត្រឹមតែកាត់បន្ថយឥទ្ធិពលថៃ វប្បធម៌ថៃបានប៉ុណ្ណោះទេ គឺថែមទាំងមានលេសរាំងខ្ទប់ទំនិញថៃ មិនអោយហូរចូលស្រុកខ្មែរដោយសេរីទៀតផង គឺយើង**

**ទេជាអ្នកចំណេញ ចំណែកថៃជាអ្នកខាត** " បន្ទាប់ពីវាយកំទេចដុតបំផ្លាញស្ថានទូតថៃប្រចាំក្រុងភ្នំពេញរួច មិនទាំងបានប៉ុន្មានសប្តាហ៍ផង គេឃើញបដាវែង៧ចងកាត់ទទឹងថ្នល់ស្ទើរគ្រប់វិថីធំៗដោយសរសេរពាក្យថា "**ទំនិញវៀតណាម! ទំនិញវៀតណាម!** " ពេលនោះប្រជាជនខ្មែរគ្មានជំរើសទេ ព្រោះទំនិញថៃត្រូវបានបិទមិនអោយចូលស្រុកខ្មែរ មានតែប្រើទំនិញយួនសិន ទោះបីមិនចង់ក៏ដោយ ។ រដ្ឋាភិបាលអាយ៉ងយួនដឹកនាំដោយ ហ៊ុន-សែន បានប្រើលេសបូកលេស ប្រើរឿងបូករឿង បន្តសើរីនៃបញ្ហាមិនចេះដាច់ មិនចេះចប់មិនចេះហើយ ជាមួយនឹងប្រទេសថៃ ហើយបាននាំចាក់បញ្ចូលរាល់គ្រប់ប្រភេទទំនិញរបស់យួនចូលមកប្រទេសខ្មែរយ៉ាងគំហុក ព្រោះថា បើមិនធ្វើដូច្នេះទេ គ្មានលេសអ្វីដើម្បីផ្លាស់ប្តូរលក្ខខណ្ឌកិច្ចសន្យាអ្វីឡើយ មិនត្រឹមតែប៉ុណ្ណោះថែមទាំងអាចផ្លាស់ប្តូរខាងផ្នែកចិត្តសាស្ត្រប្រជារាស្ត្រខ្មែរបានមួយផ្នែកតូចទៀតផង ។ លើសពីនេះទៅទៀតនោះ ហ៊ុន-សែន អាចយកចំណេញលើស្ថានការណ៍ដោយ **វិធីត្រីងៀតឆ្អៀតពង** បង្កើតព្យុះពន្យុះភ្លៀង គ្មៀងសភាពការណ៍នយោបាយទៅរកលេសទំនាស់ព្រំដែនខ្មែរ-ថៃ លេសជាប៉ះទង្គិចដោយអាវុធបន្តិចបន្តួចដោយសារទំនាស់ជាយដែន នៅក្នុងគោលបំណងដេញវិនិយោគទុនរត់ចេញពីប្រទេសថៃទៅកាន់ប្រទេសវៀតណាម និងប្រទេសចិន ហើយប្រើប្រព័ន្ធឃោសនាបំផ្លែងការពិត ផ្សាយបំពុលសភាពការណ៍




ដដែលៗ បង្វែរខួរក្បាលរាស្ត្រខ្មែរឱ្យផ្តោតលើបញ្ហាទំនាស់ព្រំដែនខ្មែរ-ថៃ ភ្លេចអស់រឿងក្បត់ជាតិ លក់ជាតិ ការប្លន់ដណ្តើមដីធ្លីពីប្រជារាស្ត្រខ្មែរ និងអំពើពុករលួយរបស់ពួកមេដឹកនាំរដ្ឋាភិបាលអាយ៉ងយួន ហើយក្នុងពេលដែលប្រជារាស្ត្រខ្មែរកំពុងតែប្រឈមមុខបញ្ហាក្រីក្រខ្វះមុខខ្វះក្រោយ និងវិបត្តិសព្វបែបសព្វយ៉ាងនោះ គណះបក្សប្រជាជនកម្ពុជា ក៏ប្រើល្បិចជិះក្របីចំលងផុក ដល់ត្រើយសើយគួថ ដើម្បីសំលាប់បំបិទមាត់ពួកក្មេងស្ទាវ ពួកក្រុម បងតូចបងធំនៃ អង្គការឧក្រិដ្ឋជន សំងាត់ អេស,អូ,វ៉ាយ អស់ជិត ៤០០ នាក់តែក្នុងរយៈពេលមិនដល់ ២ ម៉ោងផង ប្រើល្បិចខ្សែភ្លើងឆក់បាក់ស្ពានរត់ផ្អើលជាន់គ្នានៅកោះពេជ្រ ព្រោះថាពួកក្មេងពួកក្មេងអាវ៉ាសែ និងពួកក្រុមបងតូចបងធំនៃអង្គការឧក្រិដ្ឋជនសំងាត់ អេស,អូ,វ៉ាយ អស់ទាំងនេះត្រូវបានគណះបក្សប្រជាជានប្រើប្រាស់ដោយមិនដឹងខ្លួនដើម្បីរកលុយនិងធ្វើការបំរើឱ្យគោលនយោបាយរបស់គណះបក្សប្រជាជនកម្ពុជាដូចជាល្បចឆក់ប្លន់ជីវិត ជួញដូរគ្រឿងញៀន ជួញដូរមនុស្ស ជួញដូរអាវុធ សំលាប់ពួកក្រុមប្រឆាំង ធ្វើបាតុកម្មសំលាប់ពួកបាតុករស៊ីវិលនៅឆ្នាំ ១៩៩៨ និង ធ្វើបាតុកម្មវាយស្ថានទូតថៃប្រចាំនៅទីក្រុងភ្នំពេញ ដើរតួជាពួកចារកិច្ចតាមដានពួកប្រឆាំង បក្សប្រឆាំង និងពួកមនុស្សដែលគណះបក្ស

ប្រជាជនមិនទុកចិត្ត,,,,,,,ម្យ៉ាងទៀតបើទុកពួកអ្នកទាំងនេះតទៅទៀត បារម្ភខ្លាចបែកការណ៍ បែករឿង ធ្លាយអាថ៌កំបាំងសំងាត់ទៅថ្ងៃក្រោយ ដូច្នេះមានតែសំលាប់ពួកគេចោលដើម្បីកុំឱ្យយប់យូរសុបិន្តច្រើន ព្រោះថាពួកមនុស្សនៅក្នុងក្រុមបងតូចបងធំអស់ទាំងនេះគឺ ស្តាប់បង្គាប់លោកបងធំរបស់ពួកគេណាស់ បើសិនជាលោកបងធំរបស់ពួកគេកោះអញ្ជើញពួកគេអោយចូលរួមអបអរសាទរ ចូលរួមជប់លៀង ចូលរួមធ្វើបាតុកម្ម ឬចូលរួមពិធីអ្វីមួយនោះ ពួកគេប្រាកដជាទៅចូលរួមជាមិនខាន គឺពួកគេស្តាប់បង្គាប់បញ្ជាលោកបងធំរបស់ពួកគេជាជាងស្តាប់បង្គាប់ម៉ែឪបងប្អូនរបស់ពួកគេ ដូច្នេះនៅលើកោះពិជ្ជនៅថ្ងៃនោះគឺប្រាកដជាមានផែនការអ្វីមួយដែលលោកបងធំរបស់ពួកគេរៀបចំទុកសំរាប់អោយពួកគេធ្វើ ដូចគ្នានឹងការចូលរួមធ្វើបាតុកម្មសំលាប់ពួកបាតុករបក្សប្រឆាំង និងបាតុកម្មវាយកំទេចដុតបំផ្លាញស្ថានទូតថៃប្រចាំក្រុងភ្នំពេញផងដែរ ដោយពួកគេសង្ឃឹមទុកជាមុនថា **គណៈបក្សប្រជាជនកម្ពុជានឹងប្រើពួកគេអោយធ្វើអ្វីមួយដូចពេលមុនៗ ហើយនឹងផ្តល់ដល់ពួកគេនៅឱកាសរកលុយពិសេស** ដូចពេលមុនៗផងដែរ ប៉ុន្តែពួកគេស្មានមិនដល់ថា គណៈបក្សប្រជាជនកម្ពុជាបានត្រៀមពិធីខ្សែភ្លើងឆក់រត់ផ្អើលជាន់គ្នាស្លាប់ ជំនួសពិសេសជប់លៀងអបអរសារទទល់តែសោះ និងរៀបចំពួកមនុស្សរបស់គណៈបក្សប្រជាជននៅទីកើតហេតុដើម្បីសំដែងល្ខោនធ្វើជាបានឃើញ បានឮ បានរងគ្រោះដែរ ហើយ និយាយបង្វែងដានសភាពការណ៍ពីខ្សែភ្លើងឆក់ មកឧប្បត្តិហេតុផ្អើលរត់ជាន់គ្នាទៅវិញ ទីបំផុតមហាឃាតករ ញីឈ្មោល ហ៊ុន-សែន និង ប៊ុន-រ៉ានី ដែលជាមេឃាតកររៀបចំក្បួនប្រហាររង្គាលនេះ បែរជាធ្វើពុតជាយំ សោកសៅ សោកស្តាយ យ៉ាងទំនងរបស់គេ ( សូមបញ្ជាក់ថានៅក្នុងនោះក៏មានក្មេងធម្មតា និងមនុស្សធម្មចូលរួមស្លាប់ដោយពួកគេមិនបានដឹងសាច់រឿងហេតុការណ៍ត្រៀមទុកជាមុនបែបនេះឡើយ) ។

| | |
|---|---|
|  [http://www.vuthasurf.com/2010/11/feeling-socked-with-hundreds-of-death-during-water-festival/](http://www.vuthasurf.com/2010/11/feeling-socked-with-hundreds-of-death-during-water-festival/) | ពួកក្រុមក្មេងស្ទាវ និង ពួកក្រុមបងតូចបងធំនៃអង្គការឧក្រិដ្ឋជនសំងាត់ អេស-អូ-វ៉ាយ ត្រូវបាន ហ៊ុន-សែន សំលាប់បំបិទមាត់ ដោយប្រើល្បិចឆក់ខ្សែភ្លើង បាក់ស្ពាន រត់ផ្អើលជាន់គ្នាស្លាប់អស់ជិត ៤០០ នាក់ នៅលើកោះពេជ្រ នាខែ វិច្ឆិការ ឆ្នាំ ២០១០។ |
|  [http://www.go6tv.com/2010/11/many-dead-in-cambodia-festival-stampede.html](http://www.go6tv.com/2010/11/many-dead-in-cambodia-festival-stampede.html) | ពួកក្រុមក្មេងស្ទាវ និង ពួកក្រុមបងតូចបងធំនៃអង្គការឧក្រិដ្ឋជនសំងាត់ អេស-អូ-វ៉ាយ ត្រូវបាន ហ៊ុន-សែន សំលាប់បំបិទមាត់ ដោយប្រើល្បិចឆក់ខ្សែភ្លើង បាក់ស្ពាន រត់ផ្អើលជាន់គ្នាស្លាប់អស់ជិត ៤០០ នាក់ នៅលើកោះពេជ្រខែវិច្ឆិការ២០១០។ |

**(៤)-ពួកក្រុមក្មេងស្ទាវ ពួកក្រុមបងតូចបងធំនៃ អង្គការឧក្រិដ្ឋជនសំងាត់ អេស,អូ,វ៉ាយ ត្រូវបានប្រើប្រាស់ដើម្បីធ្វើឃាតកម្មនយោបាយ និងបង្ករភាពវឹកវរចលាចលសង្គម បង្កើតអសន្តិសុខសង្គម អស្ថេរភាពសង្គម**មុនការបោះឆ្នោតសំរាប់អាណត្តិថ្មី និងស្ថានភាពដែលគណះបក្សប្រជាជនគិតថាចាំបាច់ដើម្បីឆ្លៀតកេងយកចំណេញខាងនយោបាយ និងសេដ្ឋកិច្ច ហើយដែល ហ៊ុន-សែន ខ្លួនឯង តែងតែធ្លាប់បានប្រកាសថា

មានតែខ្លួនវាម្នាក់ប៉ុណ្ណោះទេ ទើបអាចទុបស្កាត់មិនអោយមានចោរ ឬបទឧក្រិដ្ឋកើតមានឡើង។ បើសិនវាប្រកាសតាមម៉េក្រូថា មិនឱ្យមានចោរ គឺ មិនមានទេ តែពេលប្រជាជនភ្លេចត្រចៀក គឺចោរមានលើសដើម។ ពួកសមាជិកអង្គការឧក្រិដ្ឋជនសំងាត់ អេស-អូ-វ៉ាយ ជានិច្ចជាកាលត្រូវបានប្រើដើម្បីសំលាប់ប្រជាជនដែលមិនពេញចិត្ត មិនដើរតាម ឬរិះគន់ទិចទៀនគណះបក្សប្រជាជនកម្ពុជា ហើយពួកគេត្រូវបានបញ្ជាអោយសំលាប់ពួកអ្នកដែលមាននិន្នាការទៅរកពួកបក្សប្រឆាំង មាននិន្នាដែលចេញពីគណះបក្សប្រជាជន ឬក្បត់នឹងគណះបក្សប្រជាជនកម្ពុជា។ លើសពីនេះទៅទៀត ពួកក្រុមក្មេងស្ទាវ ពួកក្រុមអន្ធពាល ពួកក្រុមបងតូចបងធំ និងពួកសមាជិកនៃអង្គការឧក្រិដ្ឋជនសំងាត់ អេស-អូ-វ៉ាយ ត្រូវបានប្រើប្រាស់សំរាប់សំលាប់និងគំរាមកំហែងដល់ពួកអ្នកដែលមិនគាំទ្រគណះបក្សប្រជាជនកម្ពុជា គឺមានគោលដៅបោសសំអាតខ្លាំង ដែលត្រូវបានពួកគេប្រកាន់ទ្រឹស្តីមួយដែលថា **អ្នកដែលមិនចូលបក្សមានន័យថាប្រឆាំង មានន័ថាខ្មាំង**។ កិច្ចការពិសេសរបស់ពួកសមាជិកអង្គការឧក្រិដ្ឋជនសំងាត់ អេស-អូ-វ៉ាយ គឺបោសសំអាត និងកំទេចឱ្យអស់រាល់ពួកអ្នកជាតិនិយមខ្មែរ ពួកអ្នកស្នេហាជាតិខ្មែរ ពួកវរះជន ពួកវីរះជនខ្មែរ ពួកឥស្សរះជនខ្មែរ និងពួកអ្នកនយោបាយខ្មែរដែលមាននិន្នាការប្រឆាំង ឬមិនពេញចិត្ត មិនយល់ស្របតាមការអនុវត្តន៍ ការសំរេច និងគោលដៅពិសេសរបស់គណះបក្សប្រជាជនកម្ពុជាដែលជាអាយ៉ងកញ្ជះដាច់ថ្លៃរបស់យួនកុំមុយនីស្តិ៍ក្រុងហាណូយ។

ពួកក្រុមក្មេងស្ទាវ ពួកក្រុមអន្ធពាល ពួកក្រុមបងតូចបងធំ និងពួកសមាជិកនៃអង្គការឧក្រិដ្ឋជនសំងាត់ អេស-អូ-វ៉ាយ ត្រូវបានបញ្ជាអោយសំលាប់ពួកអ្នកនយោបាយ និងពួកអ្នកគាំទ្របក្សប្រឆាំង ពួកអ្នកដែលមាននិន្នាការប្រឆាំង ហើយពួកគេបានធ្វើឃាតយ៉ាងប៉ិនប្រសព្វជាទីបំផុត ដោយបំផ្លែងចេញជារូបភាពផ្សេងៗ ដូចជា ឧប្បត្តិហេតុចៃដន្យ គ្រោះថ្នាក់ចរាចរ ខ្សែភ្លើងឆក់ ឈឺស្លាប់ ខ្យល់គ ឈ្លោះគ្នាទំនាស់គ្រួសាររឿងគ្រួសារ រឿងច្រណែន រឿងប្រណាំងប្រជែង រឿងប្រចន្ទ័ រឿងជំពាក់លុយរឿងបំណុល រឿងប្លន់សំលាប់ មានទំនាស់ជាមួយពួកក្មេងស្ទាវពួកបងតូចបងធំ រឿងស្នេហាត្រីកោណរឿងដណ្តើមស្រីជាមួយពួកអាស្ទាវ រឿងរាលកៃកាំភ្លើង រឿងងាងថ្នាំ,,,,,,,,,។ល។ និង ។ល។



មើលវាពុតធ្វើយំ ដូចមែនទែនអញ្ចឹង! មេឃាតករញីឈ្មោល កំពុងពុតធ្វើយំដើម្បីបំភាន់ភ្នែកមហាជនកុំឱ្យសង្ស័យថាខ្លួន នៅពីក្រោយខ្នងនៃការសំលាប់បំបិទមាត់ពួកក្រុមក្មេងស្ទាវ ក្រុមបងតូចបងធំនៃអង្គការឧក្រិដ្ឋជនសំងាត់អេស-អូ-វ៉ាយ ស្លាប់អស់ជិត ៤០០នាក់ នៅកោះពេជ្រនាខែវិច្ឆិការ ២០១០ ដោយ ប្រើល្បិចឆក់ខ្សែភ្លើងបាក់ស្ពាន រត់ផ្អើលជាន់គ្នាស្លាប់។ ប្រព័ន្ធ ឃោសនាក្នុងដៃផ្សាយកុហក់យ៉ាងម៉េចក៏បាន បើអ្នក ក្នុងស្រុក តវ៉ា ប្រើកងកំលាំងប្រដាប់អាវុធ ឃាតករសំងាត់ សំលាប់ ឬប្រើតុលាការចាប់ដាក់គុក តើនរណាហ៊ាននិយាយ ថា ឆក់ខ្សែភ្លើងស្លាប់? គ្រប់ប្រព័ន្ធឃោសនាស្រុកខ្មែរ ទាំងភាសាខ្មែរ និងអង់គ្លេស សុទ្ធតែជាឧបករណ៏នយោបាយ របស់ ហ៊ុន-សែន ទាំងអស់ បើមិនបំរើ ហ៊ុន-សែន គឺមានតែ ជាប់គុក ដោយចោទថា ផ្សាយពត៏មានមិនពិត និងត្រូវបាន សំលាប់ យ៉ាងសាហ៊ាវ។

នេះជាអាស័យដ្ឋានអ៊ីនធឺនិតស្ដីពីអា ហ៊ុន-សែន បញ្ជូឱ្យ កងកំលាំងប្រដាប់អាវុធសំលាប់រង្គាលព្រះសង្ឃ និងហ្វូង បាតុករយ៉ាងសាហាវឃោរឃៅនៅខែកញ្ញាឆ្នាំ ១៩៩៨ [http://il.youtube.com/watch?v=wzBWG3Uj4JM&feature=related](http://il.youtube.com/watch?v=wzBWG3Uj4JM&feature=related)

មេឃាតករញីឈ្មោលចេះយំ ផែនដីក្រឡាប់ចាក់ទេដឹង?

**ហ៊ុន-សែន** អនុវត្តផែនការ ក៥,ជាអ្នកសំរួលដល់អង្គការ ឧក្រិដ្ឋជនសំងាត់បាក់គី (១៩៩១-១៩៩៧) បង្កើត អង្គការឧក្រិដ្ឋជន សំងាត់ អេស-អូ-វ៉ាយ(១៩៩៧-២០០៣) ជាមេបង្ក្រាប សំលាប់ហ្វូងបាតុករស៊ីវិលខែ កញ្ញា១៩៩៨ ជាមេអង្គការឧក្រិដ្ឋជនសំងាត់អាវខ្មៅ (១៩៩៧-បច្ចុប្បន្ន) និងជាមេ ឃាតករសំលាប់បំបិទ មាត់ពួកក្មេងស្ទាវ ពួកក្រុមបងតូចបងធំនៃអង្គការ ឧក្រិដ្ឋជន សំងាត់ អេស-អូ-វ៉ាយ អស់ ជិត៤០០នាក់ នៅកោះពេជ្រ ខែវិច្ឆិកា ២០១០ ដើម្បីចៀងវាងនៅ "យប់យូរសុបិន្តច្រើន" នាំឱ្យបែករឿងសំងាត់។ បោក អង្គការសហប្រជាជាតិបង្កើតតុលាការសាលាក្ដីខ្មែរ ក្រហម កាត់ទោសពួកខ្មែរក្រហមដូចតុលាការយួនកាត់ ទោសខ្មែរក្រហមឆ្នាំ ១៩៧៩ ដើម្បី លាងទោសកំហុស បទឧក្រិដ្ឋឈ្លានពានរបស់យួនកំមុយនីស្ដ៏ ថែមទាំងបាន ជំនួយលុយដុល្លាដ៏ច្រើនចែកគ្នាចាយយ៉ាងសប្បាយហ៊ឺហា គ្រាន់តែសំដែងល្ខោនកាត់ទោសតែប៉ុណ្ណោះ។



**ប៊ុន-រ៉ានី:** បងខំប្រឹងយំអោយចេញទឹកភ្នែកទៅ!

**ហ៊ុន-សែន:** បងចេះតែសំលាប់មនុស្ស បងពិតជាមិនចេះយំទេ តើបានទឹកភ្នែកមកពីណាទៅ?

**ប៊ុន-រ៉ានី:** យកកូនកន្សែងជូតបន្លំទៅ ទើបសំដែងល្ខោនពុតធ្វើយំសម! មើលពួកសារពត៏មានវាមើលយើងហ្នុំ!

**ហ៊ុន-សែន:** ដើម្បីសំរេចបេសកកម្មរំលាយជាតិខ្មែរបាន បងមានតែធ្វើតាមគំនិតអូនទៅចុះ! (មើលរូបខាងលើ)

សមិទ្ធិផលរបស់ **ហ៊ុន-សែន** នៅក្នុងការសំរេចបេសកកម្មរំលាយជាតិខ្មែររបស់ក្រុងហាណូយគឺមានដូចខាងក្រោមនេះ



ហ៊ុន-សែន ជាមេភេរវករ បោកគ្រាប់បែក មុខរដ្ឋសភាថ្ងៃ ៣០មិនា១៩៩៧។ **គណៈបក្សប្រជាជនកម្ពុជា យកឃាតកម្ម និងភេរវកម្មធ្វើជាឧបករណ៏គ្រប់គ្រងប្រទេសដើម្បីសំរេចបេសសកម្មរំលាយជាតិសាសន៏របស់ក្រុងហាណូយ** ។ នេះជា **ល្បិចសំលាប់មួយគំរៀម១000**

http://editorials.cambodia.org/2008/03/cambodia-infamous-grenade-attack-still.html



រដ្ឋប្រហារនៅថ្ងៃ ៥-៦ ខែកក្កដា ឆ្នាំ ១៩៩៧ ដើម្បីកំទេចភាពរាំងស្ទះនៅក្នុងការអនុវត្តសន្ធិសញ្ញាព្រំដែនខ្មែរ-យួន ឆ្នាំ ១៩៩៨២-១៩៨៣ និង ១៩៨៥ និងបន្តអនុវត្តយុទ្ធសាស្ត្រលេបទឹកដីខ្មែរ រំលាយជាតិសាសន៏ខ្មែរ

http://www.seasite.niu.edu/khmer/ledgerwood/july_56_1997_events.htm

**ច្បាប់អន្តរជាតិនៅឯណា? សិទ្ធិមនុស្ស តំលៃមនុស្សជាតិ និងលិទ្ធិប្រជាធិបតេយ្យនៅឯណា? តើអា ហ៊ុន-សែន** បានផ្តល់ផលប្រយោជន៏អ្វីខ្លះដល់សហគមន៏អន្តរជាតិ បានជាសហគមន៏អន្តរជាតិមិនត្រឹមតែមិនចាប់អា ហ៊ុន-សែន ទេ ថែមទាំងឃិបឃិតជាមួយអា ហ៊ុន-សែន បង្កើតតុលាការសាលាក បណ្តោយអោយខ្មែរក្រហមកាត់ទោសសំដែងល្ខោនលាងបទឧក្រិដ្ឋឈ្លានពានអោយយួនកំមុយនិស្ដ៍ និងផ្តល់ជំនួយដល់ **ហ៊ុន-សែន** ទៀត? តើ **ហ៊ុន-សែនៈ** ឱ្យប៉ុន្មានភាគរយ?



សំលាប់ វាយសំពង ទាត់ធាក់ព្រះសង្ឃខ្មែរបែបយ៉ាងនេះ! នេះឬជា **ជាតិ សាសនា ព្រះមហាក្សត្រ** របស់អា ហ៊ុនសែន?

នេះជាអាស័យដ្ឋានអ៊ីនធឺនិតស្ដីពីសកម្មភាពកងកំលាំងប្រដាប់អាវុធរបស់អា ហ៊ុន-សែន វាយបង្រ្កាប និងសំលាប់ហ្វូងបាតុកម្មរបស់ព្រះសង្ឃ នៅខែ កញ្ញា ឆ្នាំ ១៩៩៨ នៅទីក្រុងភ្នំពេញ

http://il.youtube.com/watch?v=opfPLoKms_U



http://www.youtube.com/watch?v=opfPLoKms_U&NR=1



ព្រះសង្ឃមួយអង្គ ត្រូវបានពួកក្រុមអង្គការឧក្រិដ្ឋជនសំងាត់អេស-អូ-វ៉ាយ វាយបែកឈាម ថ្ងៃ២០ ខែមេសា ឆ្នាំ ២០០៧ បន្ទាប់ចូលរួមបាតុកម្មនៅមុខស្ថានទូតវៀតណាមនិងសហរដ្ឋអាមេរិក។



ក្រុមព្រះសង្ឃធ្វើបាតុកម្មមុខស្ថានទូតយួន ត្រូវបានកងកំលាំងប្រដាប់អាវុធចាប់ដាក់ក្នុងឡាន។

http://www.hrw.org/en/node/79437/section/7

## ៥-ធ្វើចារកម្ម តាមដាន ស៊ើបការណ៍ យកពត៌មាន ប្រមូលពត៌មានអោយគណៈប្រជាជនកម្ពុជា:

ពួកក្រុមបងតូចបងធំ ពួកក្មេងអាណាថា ពួកក្រុមជនអន្ធពាល និងពួកសមាជិកនៃអង្គការឧក្រិដ្ឋជនសំងាត់ អេស-អូ-វ៉ាយ ត្រូវបានប្រើសំរាប់តាមដានសភាពការណ៍ ហេតុការណ៍ សកម្មភាពជីវិតផ្ទាល់ខ្លួនរបស់ប្រជាជនខ្មែរ ថាតើប្រជាជនខ្មែរ គ្រួសារជនជាតិខ្មែរនីមួយៗមានអ្វីខ្លះ? មានសមាជិកប៉ុន្មាននាក់? សមាជិកគ្រួសារនីមួយៗប្រកបមុខរបរអ្វីខ្លះ? នៅទីកន្លែងណាខ្លះ? ចូលផ្ទះ និងចេញពីផ្ទះនៅម៉ោងប៉ុន្មាន? រកប្រាក់ចំណូលបានមួយថ្ងៃប៉ុន្មាន? មានទំនាក់ទំនងជាមួយនរណាខ្លះ? មានសក្តិឋានៈ មុខតំណែង និងតួនាទីប៉ុនណា? មានពាក់ព័ន្ធពួកបក្សប្រឆាំងឬទេ? មានខ្នងបង្អែកប៉ុនណា? នៅក្នុងជួរស៊ីវិល ឬកងកំលាំងប្រដាប់អាវុធ? សក្តិប៉ុន្មាន ផ្កាយប៉ុន្មាន? មានកាំភ្លើងនៅក្នុងផ្ទះឬទេ? ពាក់ព័ន្ធនឹងអង្គការណាខ្លះ? ការតាមដានត្រូវបានធ្វើឡើងតាមក្រុមបងតូចបងធំនិមួយៗនៅប្រចាំតាមតំបន់នីមួយៗ ហើយសកម្មភាពតាមដានស៊ើបអង្កេតត្រូវបានធ្វើឡើងជាប្រចាំថ្ងៃ ជារៀងរាល់ថ្ងៃ រាល់ខែ រាល់ឆ្នាំ ដោយមានការផ្លាស់ប្តូរវេនម៉ោងគ្នា ចែកពេលវេលាគ្នាតាមដាន ប្តូរក្រុមគ្នាចល័តតាមការចាត់តាំងរបស់ថ្នាក់លើ និងការចង្អុលទិសរបស់អាជ្ញាធរមូលដ្ឋានដែនដី។ ដោយសារតែពួកក្រុងបងតូចបងធំ ពួកសមាជិក នៃអង្គការឧក្រិដ្ឋជនសំងាត់ អេស-អូ-វ៉ាយ មានតួនាទីរកលុយចំណូលអោយបក្ស និងថ្នាក់លើផងនោះ ការតាមដានស៊ើបការណ៍ ស៊ើបអង្កេត ឃ្លាំមើល គឺជា **ឱកាសរកលុយពិសេស** តាមជោគជតាហេងស៊យរបស់ក្រុមនីមួយៗរបស់ពួកគេ ទៅតាមលទ្ធភាពជាក់ស្តែង និងសមត្ថភាពរបស់ពួកគេផងដែរ ហើយការរកលុយនេះគឺធ្វើបានទៅតាមឱកាសហុចអោយ មិនថាលួចឆក់ប្លន់នៅតាមផ្ទះទេ សូម្បីតាមថ្នល់ ក៏ពួកគេធ្វើ ដោយមិនប្រកាន់ពេលវេលា ឬទីកន្លែងណានេះទេ ក្រុមអង្គរក្ស ហ៊ុន-សែន និងក្រុមបងតូចបងធំ ពួកអេស-អូ-វ៉ាយ តាមដានខ្ញុំតាមផ្ទះលើដងផ្លូវទេពផននៅឆ្នាំ២០០៣ ២០០៤ ២០០៥ និង ២០០៦ មុនចាប់ខ្ញុំដាក់គុកព្រៃស គឺ ពេលពួកវាឃើញពួកអ្នកដំណើរ ឬស្រីៗជិះមូតូ ពាក់មាស ពេជ្រ ជាប់នឹងខ្លួន ពួកវាចាប់ផ្តើមធ្វើសកម្មឆក់ឬ ក៏ប្លន់តែម្តង ដូចជាឆក់កាបូប ឆក់លុយឆក់គ្រឿងអលង្ការរបស់របររបស់ពួកអ្នកដំណើរ ពេលខ្លះធ្វើអោយ មានគ្រោះថ្នាក់ដល់ពួកអ្នកដំណើរដួលម៉ូតូក្បែរស្លាប់ក៏មាន និងប្លន់ម៉ូតូក្បែរផ្ទះខ្ញុំស្ទើរតែរៀងរាល់ថ្ងៃ តែពួក ប៉ូលីសមិនអើរពើអ្វីឡើយព្រោះគោរពតាមបញ្ជាបក្សដាក់ទិសអោយរកចំណូលបែបយ៉ាងនេះ។

**៦-បំផុសពត៌មាន ប្រឌិតឈុតល្ខោន បំផ្លែងហេតុការណ៍ និងអនុវត្តល្បិចឆ្កែព្រុសរបស់អា ហ៊ុន-សែនៈ**
គណៈបក្សប្រជាជនកម្ពុជាដែលស្ថិតនៅក្រោមការដាក់ទិស និងដឹកនាំតំរង់ទិសរបស់រដ្ឋាភិបាលក្រុងហាណូយ ដែលជាប្រទេសកំមុយនីស្ត៍ផ្តាច់ការតាមដានគ្រប់គ្រងជីវភាពជីវិតផ្ទាល់ខ្លួនរបស់ប្រជាជន ប៉ុន្តែដោយសារពួកមេដឹកនាំយួនកំមុយនីស្តមានការស្ទាត់ជំនាញខាងសិល្បៈសង្គ្រាម ពួកវាបានប្រើប្រព័ន្ធបណ្តញចារកម្មគ្រប់គ្រងដឹកនាំពពួកឆ្កែយ៉ាងល្អ បើឆ្កែមួយណាមិនចេះព្រុស មិនស្តាប់បង្គាប់ និងមិនចេះខាំសំលាប់ប្រជាជនខ្មែរ ត្រូវបានយួនចាប់ដកតំណែងដាក់គុកដូចជាលោក ប៉ែន-សុវណ្ណ ជាគំរូស្រាប់ ឯលោក ចាន់-ស៊ី ត្រូវបានសំលាប់។ ដូច្នេះនៅក្នុងចំណោមឆ្កែយួនទាំងអស់ យួនបានសំរេចជ្រើសរើសឆ្កែអាណាថាគ្មានទីពឹងមកបង្វឹកបង្ហាត់ បង្រៀនអោយចេះព្រុស និងចេះខាំសំលាប់រាស្ត្រខ្មែរ។ បន្ទាប់ពីធ្វើការពិសោធន៍ពួកក្រុមឆ្កែជាច្រើនក្បាលអស់រយះពេលជាច្រើនឆ្នាំមក ពួកមេដឹកនាំយួនកំមុយនីស្តក៏សំរេចជ្រើសរើសអា ហ៊ុន-សែន ដែលជាឆ្កែអាណាថា ជាចោរលួចខ្ទាក់ភ្នែកភ្នែកមួយក្បាល រត់ចូលព្រៃ គ្មានទីជំរក គ្មានចំណីអាហារ មកបង្វឹករហូតដល់អា ហ៊ុន-សែន ពូកែខាងព្រុស និងប្រសព្វខាងខាំសំលាប់ប្រជារាស្ត្រខ្មែរ អោយធ្វើជាមេដឹកនាំរដ្ឋាភិបាលអាយ៉ង។ នៅក្នុងការគ្រប់គ្រងប្រជាជនខ្មែរតាមបែបសង្គមសត្វព្រៃដូចរឿងភាគបុរាណចិន ដែលយកអំពើឃាតកម្ម ភេរវកម្ម ទារុណកម្ម ការលួចឆក់ប្លន់ជីវិត,,,,,,,មកធ្វើជាឱ្យឧបករណ៍គ្រប់គ្រងប្រជាជនខ្មែរយ៉ាងណែនក្នុងដៃនោះ។ រដ្ឋាភិបាលអាយ៉ងបានបន្ថែមប្រព័ន្ធបណ្តញចារកម្ម និងឧបករណ៍ចារកម្មអាសន្សាណូទំនើប រួមជាមួយនិងយុទ្ធសាស្ត្រឆ្កែព្រុសដើម្បីសំរេចសំរេចបេសសកម្មរំលាយជាតិខ្មែររបស់ក្រុងហាណូយអោយបានឆាប់ជាទីបំផុត ហើយបានពាក់អាវលិទ្ធិប្រជាធិបតេយ្យយកបក្សប្រាឆាំងជាឧបករណ៍បោកប្រាស់យកជំនួយសហគមន៏អន្តរជាតិ និងកំចីបរទេសទៅបំប៉នសេដ្ឋកិច្ចយួន និងចិញ្ចឹមប្រជាជនយួនអោយរស់នៅយ៉ាងសំបូរសប្បាយធ្វើជាម្ចាស់លើប្រជាជាតិខ្មែរ យកប្រជាជនខ្មែរធ្វើជាទាសករលើទឹកដីរបស់ខ្លួន ហើយយួនចង់ចាប់ ចង់កាប់សំលាប់ និងលក់ដូរបានស្រេចតែចិត្ត ដោយគ្រាន់តែពាក់អាវប្រជាធិបតេយ្យ និងប្រើប្រាស់ល្បិចឆ្កែព្រុស គឺអាចបោកប្រាស់សហគមន៏អន្តរជាតិយកជំនួយយកកំចី និងបោកអង្គការសហប្រជាជាតិឱ្យបង្កើតតុលាការសាលាក្តីខ្មែរក្រហមកាត់ទោសលាងកំហុសលាងបទឧក្រិដ្ឋឈ្លានពានរបស់យួនយ៉ាង ងាយស្រួលបំផុត មិនដឹងថាពួកសហគមន៏អន្តរជាតិ អង្គការសហប្រជាជាតិ ល្ងង់គិតមិនយល់ ឬក៏ពួកអស់នេះបានទទួលផលប្រយោជន៏អ្វីមួយពីអា ហ៊ុន-សែន និងយួន ហើយពុតធ្វើជាល្ងង់ដើម្បីប្តូរយកផលប្រយោជន៏។

ការប្រើល្បិចឆ្កែព្រុសនេះ ក្រៅពីប្រព័ន្ធឃោនាវិទ្យុ ទូរទស្សន៍ កាសែត ទស្សនាវដ្ដី ពួកកងកំលាំងប្រដាប់អាវុធរបស់រដ្ឋាភិបាលអាយ៉ងនោះ នៅមានពួកក្រុមអង្គការឧក្រិដ្ឋជនបាក់គី អេស-អូ-វ៉ាយ និងអាវខ្មៅអោយជួយស្រែកព្រុសបន្ថែមលើវត្ថុបំណងដែលពួកគេចង់បាន។ ដូចជាអា ហ៊ុន-សែន បានចាត់អោយលោក ភុន-ភាព ចោទសម្ដេចក្រុមព្រះនរោត្តមរណឫទ្ធិ ដោយឥតសមហេតុផល ហើយធ្វើរដ្ឋប្រហារក្ដាប់អំណាចរួចហើយនោះ អា ហ៊ុន-សែន ព្រួយបារម្ភ ខ្លាចបែករឿងសំងាត់ ក៏ប្រើល្បិចសំលាប់លោក ភុន-ភាព ដោយប្រើចិត្តសាស្ត្រមិនអោយពួកខ្មែរក្រហមដែលចុះចូលភ្ញាក់ផ្អើលនោះ បានប្រើប្រាស់ពួកក្រុមបងតូចបងធំ ពួកក្រុមជនអន្ធពាល ពួកសមាជិកនៃអង្គការឧក្រិដ្ឋជនសំងាត់អេស-អូ-វ៉ាយ និងពួកកងកំលាំងប្រដាប់អាវុធរបស់រាជរដ្ឋាភិបាលផ្សាយព្រុសក្រៅផ្លូវការថា លោក ភុន-ភាព ស្លាប់ហើយ ការព្រុសផ្សាយនេះគឺធ្វើឡើងសព្វទីកន្លែង និងធ្វើគ្រប់រូបភាពទាំងអស់ដូចជាដើរតួជាម៉ូតូឌុប កម្មករ អ្នករត់ឡានតាក់ស៊ីស ពួកកងកំលាំងប្រដាប់អាវុធ រហូតដល់ពួកមន្ត្រីរាជការ,,,,,,ហើយទីបំផុតក៏បង្ហាញរូបភាពបទសម្ភាសរបស់លោកភុន-ភាពតាមទូរទស្សន៍ទ-ទ-ក ដើម្បីធ្វើពួកខ្មែរក្រហមដែលចុះចូលលែងផ្ដោតអារម្មណ៍លើលោក ភុន-ភាព,,,,,,,,បន្ទាប់មកលោក ភុន-ភាពត្រូវបានសំលាប់បំបិទមាត់ ហើយក៏លែងមានប្រជាជនទឹកគិតដល់ពីរឿងនេះទៀត,,,,,,,នៅករណីធ្វើឃាតលោកគីម-សុខា មិនបានសំរេច គឺនៅតាមដងផ្លូវស្ដុបទេពផន ពេលលោកគីម-សុខា បានជិះឡានសំដៅមកផ្ទះ ពួកគណៈបក្សប្រជាជនកម្ពុជា បានរៀបចំឡានដឹកដែកដើម្បីបុកសំលាប់លោក គិម-សុខា និងរៀបចំពួកកំលាំងអង្គការឧក្រិដ្ឋជនសំងាត់អេស-អូ-វ៉ាយ ដើម្បីសំដែងល្ខោនក្នុងរឿងនេះ ដោយដើរតួជាអ្នករត់ម៉ូតូឌុប ជាកម្មករ ជាជាងជុសជុលម៉ូតូកង់ ជាមនុស្សឆ្លងកាត់ទីកើតហេតុ ជាប៉ូលិសដែលនៅទីនោះដែរ ជាប្រជាជននៅជិតក្បែរៗនោះ,,,,,រងចាំងសំដែងឈុតឃាតកម្ម,,,,,,,ជាជាងកាត់សក់ជាអ្នកមកកាត់សក់ មកជុសជុលម៉ូត,,,,,,,,ពេលឡានរបស់ លោក គិម-សុខា មកជិតដល់ផ្ទះ ឡានដឹកដែកក៏បើកសំរុកមកបុកឡានលោកគីម-សុខា តែមកបញ្ជិត ធ្វើអោយលោក គិម-សុខា មានឱកាសចុះពីឡានហើយរត់ចូលផ្ទះ,,,,,,ពេលនោះប្រជាជនចោមរោមមើល ក៏មានអ្នកមកសួរនាំអំពីទីកើតហេតុនោះ,,,,,,,,ក្រុមពួកសំដែងល្ខោនក៏ស្ទុះមកសំដែនល្ខោនក៏ចេញមកបកស្រាយពីអំពើឃាតកម្មអោយទៅជារឿងគ្រោះថ្នាក់ចរាចរ,,,,,ពេលប្រជាជនចង់និយាយការពិត ត្រូវបានពួកកងកំលាំងប្រដាប់អាវុធ កំលាំងអង្គការឧក្រិដ្ឋជនសំងាត់អេស-អូ-វ៉ាយចេញមកគំរៀមកំហែងសំឡុតថា"ចេះដឹងស្អី! ពួកគេនៅទីនោះដែរ! ពួកគេឃើញ

ហេតុការណ៍ដែរ! កុំមកនិយាយមួលបង្កាច់! កុំមកចេះដឹងរឿងគេ ចង់នាំរឿងដាក់ខ្លួនហ្អី!" ពេលនោះ មានទាំងអ្នកដកកាំភ្លើងខ្លីចេញពីចង្កេះ សំញ៉ែញចេញក្រៅអាវ ហើយពោលថា "សាច់មិនបានស៊ី ចង់យកឆ្អឹងព្យួរករហ្អី! ខ្លះទៀតពោលថា "អ៊ីឯងចេះដឹងស្អី ចង់ងាប់ហ្អេះ! ចេះដឹងរឿងគេសម្បើមណាស់!" ពេលនោះប្រជាជនដែលឃើញហេតុការណ៍ ប្រែក្លាយស្ងាត់ស្ងៀម ចូលផ្ទះរៀងៗខ្លួន ហើយលោក គិម-សខា ខ្លួនឯង ក៏មិនហ៊ាននិយាយថាជាគ្រោះឃាតកម្មទេ ហើយបែរជារក្សាភាពស្ងៀមស្ងាត់ទៅវិញ។ និយាយអោយខ្លីនៅក្នុងការប្រើល្បិចឆ្កែព្រុសនេះ គណៈបក្សប្រជាជនកម្ពុជាបានពឹងផ្អែកលើក្រុមពួកបងធំបងតូច ក្រុមពួកអង្គការឧក្រិដ្ឋជនសំងាត់អេស-អូ-វ៉ាយ ជាជាងពួកក្រុមកងកំលាំងប្រដាប់អាវុធ និងពួកក្រុមសំងាត់ដទៃៗទៀត បើអា ហ៊ុន-សែន ចង់បានព្យុះពន្យុះភ្លៀង ចង់អោយសប្រែជាខ្មៅ ចង់អោយខ្មៅប្រែជាស គឺតាមតែអំពើចិត្តរបស់វា គឺចាត់អោយក្រុមទាំងនេះទៅព្រុសសព្វទីកន្លែង ព្រុសតាមការកំណត់របស់ថ្នាក់លើ និងព្រុសហើយព្រុសទៀត ព្រុសដដែលៗ ដោយពួកវាដើរតួសំដែងថា ពួកវានៅទីកើតហេតុនោះដែរ ពួកវាបានឃើញ បានរងគ្រោះ បានឮ បានដឹងហេតុការណ៍នៅទីនោះដែរ។ បើរឿងឃាតកម្មនយោបាយវិញ ពួកវាផ្សាយថារឿងប្លន់សំលាប់ ដូចជាករណីរឿង ឃាតកម្មលើរូបលោក ឱម-រដ្ឋសាឌី ត្រូវបានអា ហ៊ុន-សែន ចាត់ពួកអង្គការឧក្រិដ្ឋជនសំងាត់អេស-អូ-វ៉ាយ រួមជាមួយក្រុមកងកំលាំងប្រដាប់អាវុធផងដែរ បានផ្សព្វផ្សាយជាថារឿងប្លន់ទូរស័ព្ទ ដែលខ្លះដើរតួជាអ្នកឌុប ជាអ្នកប្រមឹក ជាអ្នកបំរើ ជាកម្មករ ជាស្រីឡង់សេ ជាមន្ត្រីរាជការ,,,,,,,ផ្សាយហើយផ្សាយទៀត ធ្វើសព្វទីកន្លែង បើប្រជាជនណាហ៊ានតវ៉ា គឺត្រូវបានពួកវាគំរាមសំលាប់ ឬចាប់ដាក់គុក ឬត្រូវបានសំលាប់យ៉ាងវេទនា,,,,,,,, ដូចករណីរឿងអា ហ៊ុន-សែន បានចុះអនុសញ្ញាបំពេញបន្ថែមជាមួយយួន (Additional Convention) នៅខែតុលា ឆ្នាំ ២00៥ ទទួលស្គាល់និងការពារសន្ធិសញ្ញាថ្ងៃទី ១៨ ខែកុម្ភៈ ឆ្នាំ ១៩៧៩ ស្តីពីសន្តិភាព មិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងលោក ហេង-ស៊ិរិន និងលោក ផាន់-វ៉ាន់ឌុង កិច្ចព្រមព្រៀងស្តីពីដែនទឹកប្រវត្តិសាស្ត្រថ្ងៃទី សន្ធិសញ្ញាថ្ងៃទី ៧ ខែកក្កដា ឆ្នាំ ១៩៨២ សន្ធិសញ្ញាស្តីពីគោលការណ៍ដំណោះស្រាយជំលោះព្រំដែននៅថ្ងៃទី ២0 ខែកក្កដា ឆ្នាំ ១៩៨៣ និងសន្ធិសញ្ញាស្តីអំពីការលុបបំបាត់ព្រំដែនរវាងសាធារណៈរដ្ឋប្រជាមានិតកម្ពុជា និងសាធារណៈរដ្ឋសង្គមនិយមវៀតណាមថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ១៩៨៥ (The Treaty of People's Republic of Kampuchea on 27th December 1985; please read Website ------> http://www.cfcambodge.org/Doc/Dec131005A.pdf ) ដើម្បីទទួលស្គាល់ជាចំហរ អនុវត្ត និង

ការពារនៅរាល់សន្ទិសញ្ញាខុសច្បាប់អស់ទាំងនេះ ហ៊ុន-សែន បានចាប់រាល់ពួកអ្នកដែលហ៊ានរិះគន់ ដាក់គុកព្រៃស រួមមានលោក តិម-សុខា លោក ប៉ា ងួនទាង លោក ម៉ម-សណង់ដូ និងលោក រុងឈុន ដោយចោទ ថាផ្សាយពត៌មានមិនពិត ដើម្បីអនុវត្តន៏យុទ្ធសាស្រ្តសំលាប់មួយគំរៀមមួយពាន់ និងល្បិចឆ្កែព្រុសរបស់ខ្លួន ដូចវាព្រុសថាយួនរំដោះលើរឿងពិតដែលយួនឈ្លានពានលុកលុយខ្មែរនាឆ្នាំ ១៩៧៩ សូមមើល http://peacecorpsonline.org/messages/messages/467/2042320.html និងសូមមើល http://editorials.cambodia.org/2006/02/seeing-through-hun-sen.html ។ ដូចគ្នាផងដែរ ប្រជាជនខ្មែរនៅខេត្តស្វាយរៀងទៅដកបង្គូលព្រំដែនយួនឈ្លានពាន ត្រូវបានគណៈបក្សប្រជាជនកម្ពុជាចាប់ដាក់គុក ហើយកាត់ទោសលោក សម-រង្សី អោយជាប់គុកជាច្រើនឆ្នាំដើម្បីធ្វើអោយលោក សម-រង្សី មិនមានឱកាសចូលរួមបោះឆ្នោត ហើយថ្មីៗនេះលោក សម-រង្សី ត្រូវបានតុលាការកាត់ទោសអោយជាប់គុកចំនួន ១០ ឆ្នាំ សូមមើល http://www.youtube.com/watch?v=lrjrajpKo_Y និងមើល




(http://www.upi.com/Top_News/Special/2010/09/24/Cambodian-politician-gets-prison-sentence/UPI-55031285325040/); (http://ki-media.blogspot.com/2010/09/key-dates-sam-rainsy-saga.html) និង (http://news.bbc.co.uk/2/hi/asia-pacific/4552054.stm) ទាំងនេះសបញ្ជាក់ថារាល់គ្រប់ល្បិចឆ្កែព្រុសរបស់អា ហ៊ុន-សែន គឺគ្មាននរណាតវ៉ាបានឡើយ បើអ្នកណាមិនជឿ មិនឯកភាព មិនស្របតាមការ

ព្រួសបំភ្លៃការពិតរបស់វា គឺត្រូវតែស្លាប់ ត្រូវបានសំលាប់ ត្រូវបានចាប់ដាក់គុក ត្រូវបានកៀបសង្កត់ដោយមធ្យោបាយផ្សេងៗ ហើយគ្រប់ប្រព័ន្ធឃោសនាគឺជាឧបករណ៏នយោបាយរបស់អា ហ៊ុន-សែន ទាំងអស់ ទាំងភាសាខ្មែរ ទាំងភាសាបរទេស ដូចជាទូរទស្សន៏បាយ័ន្ត អប្សរា ទទក,,,,,,វិទ្យុ,,,,,,,,កាសែត Cambodian Dail, Phnom Penh Post…….និងកាសែតម៉ាហ្វីយ៉ាឈ្មោះកាសែតរស្មីកម្ពុជា,,,,,,គឺសុទ្ធតែផ្សាយនៅអ្វីដែលគណៈបក្សប្រជាជនកម្ពុជាចង់បាន ,,,,,ពួកកាសែតអគតិអស់ទាំងនេះច្រើនតែជាពួកក្រុមអង្គរក្សជាអ្នកសរសេរតាមដែលអា ហ៊ុន-សែន ចង់បានដូចក្មេងបៀមដៃលេងបាយលុកបាយឡ ហើយសារពត៏មានណាដែលមិនស្របនឹងពួកវា ប្រពន្ធ័ឃោសនាដែលមិនស្របតាមអា ហ៊ុន-សែន គឺ មិនអាចឈរជើងនៅកម្ពុជាបានឡើយ,គឺត្រូវបានសំលាប់ និងត្រូវបានចាប់ដាក់គុកតាមតែក្បាលចិត្តរបស់អា ហ៊ុន-សែន ។ ក្រៅពីនេះក្រុមបងតូចបងធំ ក្រុមជនអន្ធពាល និងពួកសមាជិក អង្គការឧក្រិដ្ឋជនសំងាត់អេស-អូ-វ៉ាយ ត្រូវបានប្រើសំរាប់សំដែងល្ខោន ប្រឌិតរឿង ប្រឌិតហេតុការណ៏ទៅ តាមដែលគណៈបក្សប្រជាជនកម្ពុជាចង់បានតែប៉ុណ្ណោះ ដូចជាករណីធ្វើបាតុកម្មស៊ីវិលបង្រ្កាបបាតុកម្មពួក ប្រឆាំងនៅខែកញ្ញា ឆ្នាំ ១៩៩៨ និង ការធ្វើបាតុកម្មស៊ីវិលវាយដុតបំផ្លាញស្ថានទូតថៃប្រចាំក្រុងភ្នំពេញនៅខែ មករា ឆ្នាំ ២០០៣,,,,,សមដូចលោកកែន-ចំរើន ប្រធានអេស-អូ-វ៉ាយ បាននិយាយថា "រឿងហេតុគ្រប់យ៉ាងគឺសុទ្ធតែជាឆាកល្ខោន ដែលពួកមេដឹកនាំរបស់គណៈបក្សប្រជាជនជាអ្នកបង្កើតឡើងទាំងអស់ អ្នកបង្កើតឆាកល្ខោនគឺជាមេដឹកនាំរបស់គណៈបក្សប្រជាជនកម្ពុជា ចំណែកឯអ្នករងគ្រោះគឺប្រជាជន និងអ្នកប្រព្រឹត្ត" ។ ព្យុះកំណាចសព្វយ៉ាងគឺកើតចេញពីយួនកំមុយនិស្តទាំងអស់ ដូចជាយួនប្រើល្បិចបែកបាក់គ្នាបង្កើតចេញជាសង្រ្គាមវៀតណាមសំលាប់ប្រជាជាតិខ្មែរកម្ពុជាក្រោមអស់ជិត៤លាននាក់ បោកយកលុយជំនួយពីមហាអំណាចសូវៀត សហរដ្ឋអាមេរិកនិងចិន មកកសាងប្រទេសយួន ហើយថែមទាំងបង្កើតខ្មែរក្រហមសំលាប់ជាជនជាតិខ្មែរអស់ជិត៣លានហើយឈ្លានពានខ្មែរបន្តសង្រ្គាមសំលាប់ខ្មែររាប់សិបឆ្នាំ ទីបំផុតបោកបញ្ឆោតអង្គការសហប្រជាជាតិអោយបង្កើតតុលាលាការសាលាក្តីខ្មែរក្រហមកាត់ទោសលាងកំហុស លាងបទឧក្រិដ្ឋឈ្លានពានរបស់យួនជំនួសតុលាការយួនឆ្នាំ ១៩៧៩ ដែលធ្លាប់បានកាត់ទោសខ្មែរក្រហមរួចទៅហើយ តែសំដែងម្តងទៀតដើម្បីបិទបាំងអំពើឧក្រិដ្ឋកម្មដែលយួនបានសំលាប់ជនជាតិខ្មែរ បិទផ្លាកខ្មែរក្រហមជាឃាតករជំនួសយួនទៅវិញ ហើយអង្គការសហប្រជាជាតិប្រៀបបីដូចជាក្តាន់រមាំងដែលយួនបោកប្រាស់តែប៉ុណ្ណោះ។

## ការប្រៀបធៀបរវាងស្ថាប័នឆ្មាំក្រហមរបស់ ម៉ៅ-សេទុង និង អង្គការឧក្រិដ្ឋជនសំងាត់អេស-អូ-វ៉ាយ របស់ ហ៊ុន-សែន

| | |
|---|---|
| **ឆ្មាំក្រហមត្រូវបានបង្កើតឡើងដោយលោក ម៉ៅ-សេទុង នៅខែកក្កដា ឆ្នាំ១៩៦៦ ក្នុងសម័យមហាបដិវត្តន៍វប្បធម៌**   http://mike-servethepeople.blogspot.com/2008/08/battle-for-chinas-present-mao-and.html | **អង្គការឧក្រិដ្ឋជនសំងាត់ អេស-អូ-វ៉ាយ ត្រូវបាន បង្កើតឡើងដោយ ហ៊ុន-សែន ខែកក្កដា ឆ្នាំ ១៩៩៧**   មេស្ថាបនិកអង្គការឧក្រិដ្ឋជនសំងាត់ អេស-អូ-វ៉ាយ ដើម្បីពង្រឹងអំណាចគណៈបក្សប្រជាជនកម្ពុជា |
|  **បុព្វហេតុរបស់លោក ម៉ៅ-សេទុង** បដិវត្តន៍វប្បធម៌ បំបាត់ពិភពលោកចាស់ បង្កើតពិភពលោកថ្មី គឺបំបាត់រាល់គំនិតវប្បធម៌ ប្រពៃណី និងទំនៀមទំលាប់ចាស់ ។ |   **បុព្វហេតុរបស់ ហ៊ុន-សែន លក់ជាតិទឹកដី សំលាប់រាស្ត្រ សំរេចបេសកកម្មរំលាយជាតិខ្មែររបស់ក្រុងហាណូយ ។ ពិធីពាក់មេដៃឱ្យផ្កែដែលកាត់ដីឱ្យយួន ។** |














Thursday, January 30, 2003 S.O.Y burned Thai embassy http://www.corkscrew-cxballoon.com/03/01/2xxx/part2.html











http://news.bbc.co.uk/2/hi/asia-pacific/2709261.stm












http://www.gettyimages.com/detail/3430609/Hulton-Archive



https://www.msu.edu/course/iss/325/stein/revolt.htm

Cultural struggle meant smashing the "four olds" (old ideas, old culture, old habits, old customs). Secret Criminal Organization called S.O.Y meant smashing Anti-party, steal, rob, kidnap, illegal drug trafficking and human trading , kill Khmer people and Anti-party member activists for getting the Special Money Earning that CPP give them after achieved the mission of CPP. ចំពោះរឿងឃាតកម្មនយោបាយ និងរឿងប្លន់ជីវិតមនុស្ស អា ហ៊ុន-សែន តែងតែប្រើប្រាស់ ពួក ក្រុមកងអគ្គឃាតពិសេសនៃអង្គការឧក្រិដ្ឋជនសំងាត់អាវឈុតខ្មៅ ចំណែកឯរឿងឃោសនាបំផុសបំផ្លែងពត៌មានប្រើល្បិចឆ្កែព្រុសគឺអា ហ៊ុន-សែន ប្រើប្រាស់ពួកក្រុមបងតូចបងធំ ពួកក្រុមជនអន្ធពាល ពួកសមាជិកនៃអង្គការឧក្រិដ្ឋជនសំងាត់អេស-អូ-វ៉ាយ ដែលពួកអស់ទាំងនេះពូកែព្រុសលើសសត្វឆ្កែទៅទៀត ព្រុសហើយព្រុសទៀត ព្រុសទាំងយប់ទាំងថ្ងៃ ព្រុសស្រែកជេរឥតចេះហត់ ព្រុសដដែលៗ

រហូតដល់ប្រជាជនជឿពួកវា ហើយបើហ៊ានតវ៉ា គឺពួកវាសំលាប់បំបិទមាត់ ឬត្រូវបានចាប់ដាក់គុកដោយចោទពីបទផ្សាយពត៌មានមិនពិត ហើយការព្រុសស្រែកដដែលៗនេះគឺមានការផ្លាស់ប្តូរវេនម៉ោងគ្នា និង បែងចែកជាក្រុមពង្រាយសព្ទទីកន្លែងទៅលើរឿងសំខាន់ៗដែលអា ហ៊ុន-សែន យល់ថាជាការចាំបាច់។ ការប្រើល្បិចឆ្កែព្រុសនេះ អា ហ៊ុន-សែន ប្រើគ្រប់ប្រភេទមនុស្សចាប់តាំងពីក្មេងស្មាវមិនទាន់គ្រប់អាយុ រហូតដល់មនុស្សចាស់ជរា មានទាំងមនុស្សស្រីមនុស្សប្រុស ដែលក្លែងភេទគ្រប់មុខរបរដូចជាអ្នករត់ម៉ូតូឌុប អ្នកធាក់ស៊ីក្លូ អ្នករត់តាក់ស៊ីស អ្នកលក់ដូរ អ្នកកាសែត គឺគ្រប់ប្រភេទមនុស្សទៅតាមគោលដៅដែលពាក់ព័ន្ធ។ អា ហ៊ុន-សែន ប្រើល្បិចឆ្កែព្រុសគ្រប់មធ្យោបាយដែលវាមាននៅក្នុងដៃ ដើម្បីប្រឌិតរឿងដែលអា ហ៊ុន-សែន ចង់បាន គឺព្រុសរហូតដល់ព្រឹត្តិការណ៍ក្លែងក្លាយប្រែក្លាយជាការពិត រហូតដល់ប្រជាជនត្រូវតែជឿសិន បើមិនជឿគឺមានបញ្ហា គឺថាដើម្បីជោគជ័យ ត្រូវតែប្រើយុទ្ធសាស្ត្រឆ្កែព្រុស ដែលអា ហ៊ុន-សែន តែងតែព្រុសឥតឈប់ឈរទៅលើរឿងដដែលៗ ដូចជារឿងយួនឈ្លានពានប្រទេសខ្មែរ អា ហ៊ុន-សែន ព្រុសអោយទៅជាយួនរំដោះខ្មែរ ថែមទាំងព្រុសបោកប្រាស់អង្គការសហប្រជាជាតិអោយបង្កើតតុលាការសាលាក្តីខ្មែរក្រហម កាត់ទោសលាងកំហុសអោយយួន ប្រែក្លាយបទឧក្រិដ្ឋប្រល័យពូជសាសន៍ បទឧក្រិដ្ឋឈ្លានពានរបស់យួន អោយក្លាយជាយួនមានគុណលើខ្មែរគឺជាមហាជោគជ័យដ៏ធំបំផុតរបស់យួនក្នុងការសំរេចយុទ្ធសាស្ត្ររំលាយជាតិខ្មែរ គឺពួកគេប្រកាន់ ទ្រឹស្តីមួយដែលថា "**ព្រុសមួយពាន់ដង អោយតែគេជឿមួយដង គឺមានន័យថាជោគជ័យ**"។

## ***៣. អង្គការឧក្រិដ្ឋជនសំងាត់អាវខ្មៅឈុតខ្មៅ*** *(Secret Criminal Organizaton Of The Black Uniform):*

អង្គការឧក្រិដ្ឋជនសំងាត់អាវខ្មៅ ឬឈុតខ្មៅ គឺជាអង្គការឧក្រិដ្ឋជនសំងាត់ផ្លូវការមួយរបស់គណៈបក្សប្រជាជនកម្ពុជា ដែល ហ៊ុន-សែន ខ្លួនឯង ត្រូវបានហៅអង្គការនេះថា "ក្រុមកងអត្តឃាតពិសេស"។ អង្គការឧក្រិដ្ឋជនសំងាត់អាវឈុតខ្មៅនេះ ត្រូវបានបង្កើតឡើងដោយរដ្ឋាភិបាលក្រុងហាណូយ។ នៅក្នុងផែនការលេបត្របាក់ទឹកដីខ្មែរ និង រំលាយជាតិសាសន៍ខ្មែរនៅក្នុងល្បឿនលឿនជាអតិបរិមារតាមក្បួនយុទ្ធសាស្ត្ររបស់លោក ហូរ-ជីមិញ។ បើតាមលោក គិម-វ៉ាន់សាន អតីតជាមេបនយួន បានបញ្ជាក់ប្រាប់ខ្ញុំនៅបន្ទប់ ៣៤ អាគារអា នៃគុកព្រៃស នាខែតុលា និងវិច្ឆិការ ឆ្នាំ ២០០៦ ថា "ពួកអាអាវខ្មៅនេះគឺត្រូវបាន

រដ្ឋាភិបាលក្រុងហាណូយបង្កើតឡើងដោយប្រមូលពួកក្មេងកំព្រាដែលមានអាយុចាប់ពី ៥ឆ្នាំ ទៅ ១០ឆ្នាំ យកទៅបង្វឹកបង្ហាត់បង្រៀនសិល្បៈក្បាច់គុណនិនច្បា និងយុទ្ធសាស្រ្តដាកកុងរហូតដល់ពួកគេធំពេញវ៍យ។ មិនត្រឹមតែប៉ុណ្ណោះពួកគេថែមទាំងត្រូវបានបង្រៀនទៅជំនាញយុទ្ធសាស្រ្តយោធា និងជំនាញប៉ូលីសទៀតផង ហើយពួកគេស្ទាត់ជំនាញខ្លាំងណាស់ក្នុងការវាយប្រហារសំលាប់មនុស្ស ពួកគេបានប្រើប្រាស់ដៃជើងធ្វើជាអាវុធនៅក្នុងការវាយប្រហារសំលាប់មនុស្សដែលជាគោលដៅរបស់ពួកមេដឹកនាំ និងចេះប្រើប្រាស់នៅរាល់គ្រប់ប្រភេទអាវុធដែលនៅក្បែរជិតខ្លួន ពួកគេដូចជាចោលកាំបិត គាប់ដែកគោល គាប់ដែកកេះ គាប់ដុំថ្ម ប្រើប្រាស់ដំបង ដាវ កាំបិតគ្រប់យ៉ាង ចោលលំពែង គប់ខ្មោះដៃចោលពីចំងាយដែលសូម្បីតែស្រី១ដែលនៅក្នុងក្រុមពួកអាវឈុតខ្មៅក៏ចេះគាប់ខ្មោះពីចំងាយទៅកាំកង់ម៉ូតូរបស់មនុស្សដែលកំពុងជិះម៉ូតូធ្វើអោយដួលម៉ូតូចាប់បានយ៉ាងងាយបំផុត ក្រៅពីនេះ ពួកក្រុមសមាជិកនៃអង្គការឧក្រិដ្ឋជនសំងាត់អាវឈុតខ្មៅថែមទាំងចេះ ប្រើប្រាស់កាំភ្លើងខ្លី កាំភ្លើងវែង កាំភ្លើងស្វ័យប្រវត្តិ និងអាវុធទំនើប១គ្រប់ធុន ហើយពួកគេអាចលោតចុះពីលើផ្ទះជាន់ទី៣ ចុះមកក្រោមដោយគ្មានគ្រោះថ្នាក់ និងអាចឡើងជញ្ជាំងនៃអាគារខ្ពស់១ដើម្បីឈ្លបធ្វើឃាតមនុស្ស។ នៅក្នុងចំណោមពួកអាវខ្មៅចំនួន ១០០០ នាក់ ដែលត្រូវបានបញ្ចប់ការហ្វឹកហាត់ហើយនោះ រដ្ឋាភិបាលក្រុងហាណូយបានជ្រើសរើសចំនួន ២០០នាក់ ទៅ ៣០០នាក់ ដើម្បីបញ្ចូលទៅក្នុងក្រុម មួកមួកបា (ក្រុមអាវឈុតខ្មៅពិសេសរបស់អង្គការឧក្រិដ្ឋជនសំងាត់អាវឈុតខ្មៅរបស់យួន)។ លើសពីនេះទៅទៀត គឺរដ្ឋាភិបាលក្រុងហាណូយបានបង្ហាត់បង្រៀនដល់ពួកគេអោយចេះនិយាយភាសាខ្មែរ ចេះអក្សរសាស្រ្ត ព្រមទាំងប្រពៃណីទំនៀមទំលាប់ខ្មែរដល់ពួកក្រុមអាវឈុតខ្មៅរហូតដល់ពួកគេចេះចាំអាចប្រើការបានហើយ ទើបរដ្ឋាភិបាលក្រុងហាណូយយកពួកគេទៅចាក់ថ្នាំម្យ៉ាងធ្វើអោយប្រែពណ៌សំបុរស្បែកពីសអោយទៅជាខ្មៅដូចពណ៌សំបុរស្បែករបស់ជនជាតិខ្មែរនៅតាមជនបទ ហើយដល់ដំណាក់កាលចុងក្រោយបំផុត ទើបរដ្ឋាភិបាលក្រុងហាណូយដឹកបញ្ជូនពួកគេមកកាន់ប្រទេសកម្ពុជា។ ពួកអង្គការឧក្រិដ្ឋជនសំងាត់អាវខ្មៅ ឬឈុតខ្មៅ នេះដំបូងឡើយគឺមានតែលោក ហុក-ឡង់ឌី ទេ ហើយពួកគេធ្វើជាអង្គរក្សរបស់លោក ហុក-ឡង់ឌី និងបំរើការអោយលោកយ៉ាងមានប្រសិទ្ធិភាពបំផុត ទើបធ្វើអោយ ហ៊ុន-សែន មានការព្រួយបារម្ភ និងមានការច្រណែនរួមទាំងភ័យខ្លាចឥទ្ធិពលអំណាចរបស់លោក ហុក-ឡង់ឌី កើនឡើងនោះ ទើប ហ៊ុន-សែន សំរេចចិត្តទទូចសុំពួកក្រុមអង្គការឧក្រិដ្ឋជនសំងាត់អាវខ្មៅ ឬឈុតខ្មៅខ្លះមកធ្វើជាអង្គរក្សរបស់ខ្លួនដោយយកលេសព្រួយ






**ហ៊ីង-ប៊ុនហៀង** ជាមេឃាតករ ស្រេកឈាមស្រេកដុល្លា និងជាមនុស្សជំនិតរបស់ **ហ៊ុន-សែន** ស្បែកចាក់ថ្នាំមិនដូចស្បែកខ្មែរទេ

**អង្គការឧក្រិដ្ឋជនសំងាត់អាវខ្មៅ ឬឈុតខ្មៅ** (Secret Criminal Organizaton Of The Black Uniform)




[http://khmernz.blogspot.com/2008_01_16_archive.html](http://khmernz.blogspot.com/2008_01_16_archive.html)

នេះជាសកម្មភាពវាយប្លន់ប្រជាជននៅទីសាធារណៈកណ្តាលថ្ងៃរបស់ពួកក្រុមអង្គការឧក្រិដ្ឋជនសំងាត់អាវខ្មៅឬឈុតខ្មៅចុះទម្រមពេលយប់ និងនៅក្នុងទីអាថ៌កំបាំងនោះ តើទៅជាយ៉ាងណាទៅ?

បារម្ភពីបញ្ហាសន្តិសុខផ្ទាល់ខ្លួន ហើយទីបំផុតនៅក្នុងឆ្នាំ ១៩៩៧ រដ្ឋាភិបាលក្រុងហាណូយបានបញ្ជូនពួកក្រុមអង្គការឧក្រិដ្ឋជនសំងាត់អាវខ្មៅ ឬឈុតខ្មៅយ៉ាងច្រើនសន្ធឹកមកជួយជ្រោងជ្រែង និងជួយធ្វើកិច្ចការអោយគណៈបក្សប្រជាជនដើម្បីពង្រឹងអំណាច ពង្រីកឥទ្ធិពលក្តោបអំណាចអោយបានណែនក្នុងដៃ និងកំចាត់ពួកគណៈបក្សប្រឆាំង និងពួកអ្នកដែលមាននិន្នាការប្រឆាំង ពួកឥស្សរៈជនខ្មែរ វីរៈជនខ្មែរ ពួកអ្នកជាតិនិយមខ្មែរ និងពួកអ្នកដែលមិនដើរតាមគន្លងត្រីវិស័យរបស់ រដ្ឋាភិបាលក្រុងហាណូយ មិនថាក្នុងបក្ស ឬក្រៅបក្សឡើយដើម្បីសំរេចឱ្យបាននូវផែនការរំលាយជាតិសាសន៍ខ្មែរទៅអនាគត ព្រោះថាបើកំទេចពួកអស់ទាំងនេះបានគឺប្រៀបបីដូចជាបំផ្លាញសរសរទ្រូងរបស់ខ្មែរបានអញ្ចឹង។ ដើម្បីក្តោបអំណាច ពង្រីកអំណាច និងពង្រឹងអំណាចរបស់រដ្ឋាភិបាលអាយ៉ងរបស់ខ្លួននៅប្រទេសកម្ពុជា និងលេបត្របាក់ប្រទេសកម្ពុជា និងរំលាយជាតិសាសន៍ខ្មែរតាមយុទ្ធសាស្ត្រគឺង្គក់តាមបែបដូចប្រទេសឡាវ មានន័យថាមិនដូរឈ្មោះប្រទេសកម្ពុជាទេ ប៉ុន្តែដូរជនជាតិខ្មែរតាមវិធីនយោបាយសមានកម្ម ដោយសំលាប់ជនជាតិខ្មែរតិចៗ សំលាប់តក់ៗ តែសំលាប់ជាតិខ្មែររយៈពេលយូរគឺសំលាប់បានច្រើន ហើយសហគមន៍អន្តរជាតិមិនសង្ស័យ មិនចាប់អារម្មណ៍ ថែមទាំងឱ្យជំនួយ និងឱ្យលុយកម្ចីដល់រដ្ឋាភិបាលអាយ៉ងដើម្បីពង្រឹងប្រព័ន្ធចារកម្ម និងពង្រីកបណ្តាញឧក្រិដ្ឋជន បណ្តាញឃាតករភេរវករអោយធំធាត់ខ្លាំងក្លាថែមទៀត និងប្រើនយោបាយឆុងសាច់ឈាមជាតិសាសន៍ បង្កាត់ពូជសាសន៍ យួន-ខ្មែរ ហើយចាត់ទុកកម្ពុជាគ្រាន់តែជាខេត្តដ៏សំបូរស្តុកស្តម្ភមួយរបស់ប្រទេសវៀតណាម ទើបរដ្ឋាភិបាលក្រុងហាណូយបែងចែកក្រុមអាវឈុតខ្មៅជា ៣ផ្នែកគឺ ក្រុមអាវខ្មៅរបស់លោក ហុក-ឡង់ឌីក្រុមអាវខ្មៅរបស់ ហ៊ុន-សែន និងក្រុមអាវខ្មៅរបស់នាយកដ្ឋានអន្តរាគមន៍របស់ក្រសួងមហាផ្ទៃ។ ចំពោះហ៊ុន-សែន វិញ ទោះបីជារដ្ឋាភិបាលក្រុងហាណូយផ្តល់ដល់គាត់នៅពួកក្រុមអាវឈុតខ្មៅចំនួនច្រើនប៉ុណ្ណឹងក៏នៅតែ ហ៊ុន-សែន មិនស្កប់ស្កល់ឡើយ ហើយ ហ៊ុន-សែន បានប្រមូលពួកអង្គរក្សហ្វឹកហាត់បន្ថែមបញ្ចូលទៅក្នុងក្រុមអាវឈុតខ្មៅបន្ថែម។ នៅក្នុងប្រទេសកម្ពុជា សមាជិកក្រុមអាវឈុតខ្មៅសុទ្ធតែមានកាត និងប័ណ្ណពិសេស រួមទាំងសំបុត្របេសសកម្មពិសេស។ ចំពោះកាត និង ប័ណ្ណពិសេសនោះមានពណ៌ផ្ទៃមេឃ គឺជា

កាតដែលមានទំហំតូចប៉ុន ២ធ្នាប់ដៃ ម្ខាងមានរូបថត ហ៊ុន-សែន និងម្ខាងទៀតមានរូបភាពឃាតករអាវយុតខ្មៅ ដែលបញ្ជាក់នៅមុខតំណែងអង្គរក្ស អត្តលេខសំគាល់ខ្លួន ហើយនេះគឺត្រូវបានតំរូវងោយស៊កចូលទៅក្នុងចង្កេះខោ (Source$^{A4}$) នៅពេលជួបឧបសគ្គ ឬការរាំងស្ទះនៅក្នុងដំណើរបំពេញបេសសកម្ម ឬក៏ឧប្បត្តិហេតុផ្សេងៗ ជាមួយពួកអាជ្ញាធរដែនដី ទើបពួកអង្គរក្សអាវយុតខ្មៅបង្ហាញកាតពិសេសពណ៌ផ្ទៃមេឃទំហំ២ធ្នាប់ដៃនេះ ហើយនិយាយគំហ៊កទៅមេដឹកនាំអាជ្ញាធរដែនដីថា "សូមអស់លោកជួយសំរួលដំណើរបេសសកម្មរបស់យើងខ្ញុំផង" ពេលនោះអាជ្ញាធរដែនដី មិនត្រឹមតែមិនចាប់ចងពួកអាវយុតខ្មៅប៉ុណ្ណោះទេ ថែមទាំងជួយសំរួលសព្វបែបយ៉ាង ដូចជាជួយលុបបំបាត់ភស្តុតាង បំបាត់ស្លាកស្នាម គំរាមកំហែង ឬសំលាប់សាក្សី និងឧបត្ថម្ភដល់ពួកក្រុមអាវយុតខ្មៅនៅអ្វីដែលជា តំរូវការចាំបាច់នៅក្នុងដំណើរបេសសកម្មទៀតផង។ ពួកអង្គការឧក្រិដ្ឋជនសំងាត់អាវយុតខ្មៅនេះគឺមិនត្រឹម តែដើរតួនាទីត្រឹមតែជាអង្គរក្សរបស់ ហ៊ុន-សែន លោក ហុក-ឡង់ឌី និងថ្នាក់ដឹកនាំកំពូលៗរបស់គណៈបក្សប្រជាជនកម្ពុជាតែប៉ុណ្ណោះទេ គឺថែមទាំងជាប៉ូលីស ទាហ៊ាន ប៉េអ៊ឹមទៀតផង ដោយពួកគេមានជាប់មកជាមួយនៅ កាត ឬអត្តសញ្ញាប័ណ្ណជាប៉ូលីស ទាហ៊ាន និងកងរាជអាវុធហត្ថនៅជាប់នឹងខ្លួនដើម្បីផ្លាស់ប្តូររូបភាព ភេទ និងប្តូរឯកសណ្ឋានតាមកាលៈទេសៈចាំបាច់។ អង្គការឧក្រិដ្ឋជនសំងាត់អាវយុតខ្មៅនេះ ត្រូវបានបង្កើតឡើងដោយរដ្ឋាភិបាលក្រុងហាណូយ ហើយត្រូវបានប្រើប្រាស់នៅក្នុងគោលបំណងដូចខាងក្រោមនេះ

**(១)-តាមដាន ស៊ើបការណ៍ យកពត៌មាន ប្រមូលពត៌មានទិន្នន័យផ្សេងៗ:** ពួកសមាជិកអង្គការឧក្រិដ្ឋជនសំងាត់អាវយុតខ្មៅទាំងនេះត្រូវបានប្រើប្រាស់ដើម្បីធ្វើជាចារបុរស ស៊ើបអង្កេត តាមដាន ស៊ើបការណ៍ យកពត៌មានអំពីរាល់គ្រប់សកម្មភាពជីវិតផ្ទាល់ខ្លួនរបស់ពួកអ្នកជាតិនិយមខ្មែរ វរៈជនខ្មែរ ឥស្សរៈជនខ្មែរ ជនរួមជាតិខ្មែរ ពួកបក្សប្រឆាំង និងពួកអ្នកដែលមាននិន្នាការប្រឆាំង ឬមិនគាំទ្រគណៈបក្សប្រជាជនកម្ពុជា ព្រមទាំងថ្នាក់ដឹកនាំ និងសមាជិករបស់គណៈបក្សប្រជាជនកម្ពុជាដែលពួកគេសង្ស័យថាក្បត់ ឬមានបំណងចង់ក្បត់បក្ស រួមទាំងពួកឈ្មួញក្នុងស្រុក ពួកអ្នកវិនិយោគទុន និងជនបរទេស,,,,,,ហើយការតាមដាន ការស៊ើបការណ៍ ការស៊ើបសង្កេតនៃប្រព័ន្ធបណ្តាញចារកម្មរបស់ពួកសមាជិកអង្គការឧក្រិដ្ឋជនសំងាត់អាវយុតខ្មៅនេះគឺប្រើសុទ្ធតែឧបករណ៍ចារកម្មអាសន្សាឈ្លូទំនើប សូមមើល (Source$^{Special}$) រួមជាមួយបរិក្ខារជំនួយទំនើបបន្ថែមទៀតដូចជា កំព្យូទ័រទំនើបៗ ទូរស័ព្ទ និងវិទ្យុទាក់ទងទំនើបៗគ្រប់ធុន ប្រភេទ

អាវុធប្រល័យមនុស្សគ្រប់យ៉ាង យានជំនិះប្រណិតៗគ្រប់ធុន លិខិតបេសសកម្មរបស់ ហ៊ុន-សែន ឬក្រសួងដែលពាក់ព័ន្ធ រួមទាំងកាតឬអត្តសញ្ញាណបណ្ណ័ពិសេសតូចៗប៉ុន២ធ្នាប់ដៃសំរាប់លាក់ក្នុងចង្កេះខោដែលចេញឱ្យដោយ ហ៊ុន-សែន។ ពួកអស់នេះមិនត្រឹមតែតាមដានយកការណ៏ប៉ុណ្ណោះទេ ថែមទាំងប្លន់ជីវិត ឬសំលាប់ផងដែរ ប្រសិនបើពួកគេយល់ថាជាការចាំបាច់នោះ។ ក្រៅពីនេះ ពួកសមាជិកអង្គការឧក្រិដ្ឋជនសំងាត់អាវឈុតខ្មៅនេះមានតួនាទីប្រមូលពត៏មាន ទិន្នន័យ និងធ្វើរបាយការណ៏អំពីសមិទ្ធិផលដែលគណៈបក្សប្រជាជនកម្ពុជាសំរេចជូនក្រុងហាណូយបាន ដូចជា ថាតើពួកគេកំទេចសត្រូវ ឬឧបសគ្គរបស់ក្រុងហាណូយបានប៉ុន្មាន? បញ្ចូលជនជាតិវៀតណាមបានប៉ុន្មាន? ជួយអ្វីខ្លះជនជាតិវៀតណាម និងពួកអ្នកវិនិយោគទុនវៀតណាម និងអនុវត្តន៏ផែនការរំលាយជាតិសាសន៏ខ្មែរ បានដល់កំរិតណាហើយ? កិច្ចសហប្រតិបត្តិការរបស់គណៈបក្សប្រជាជនជាមួយជនជាតិវៀតណាម និងក្រុមពួកសមាជិកអង្គការឧក្រិដ្ឋជនសំងាត់អាវឈុតខ្មៅ ដើម្បីអនុវត្តផែនការលេបទឹកដីខ្មែរ និងរំលាយពូជសាសន៏ខ្មែរ ជាតិសាសន៏ខ្មែរ ប្រព្រឹត្តិទៅយ៉ាងដូចម្តេច? នរណាជាជនអសកម្មរារែកក្នុងការអនុវត្តន៏ផែនការរបស់ក្រុងហាណូយ? តើមូលហេតុអ្វីខ្លះនាំអោយរាំងស្ទះអាក់ខាននៅក្នុងការអនុវត្តន៏ផែនការរបស់រដ្ឋាភិបាលក្រុងហាណូយ? រាល់គ្រប់បណ្តាញចារកម្មទាំងអស់របស់គណៈបក្សប្រជាជនកម្ពុជា មានតែពត៏មានឧក្រិដ្ឋសំងាតរបស់អង្គការឧក្រិដ្ឋជនសំងាត់អាវឈុតខ្មៅដែលយកជាពត៏មានសំងាត់អាចយកជាការណ៏បាននោះ ព្រោះវាជាបណ្តាញចារកម្មសំងាត់ទំនើបរបស់អា ហ៊ុន-សែន ដែលជាអង្គការឃាតកម្មភេរវកម្មដែលបំពាក់ទៅដោយឧបករណ៏ចារកម្មអសន្យាណូទំនើបរបស់អា ហ៊ុន-សែន និងថ្នាក់ដឹកនាំជាន់ខ្ពស់របស់គណៈបក្សប្រជាជនកម្ពុជា ដែលត្រូវបានអា ហ៊ុន-សែន បានហៅអង្គការនេះ ជាផ្លូវការថា "ក្រុមកងអត្តឃាតពិសេស" (Death Squad) ដែលអា ហ៊ុន-សែន ទុកចិត្តអង្គការនេះជាទីបំផុតព្រោះថាពួកសមាជិកនៃអង្គការឧក្រិដ្ឋជនសំងាត់អាវឈុតខ្មៅសុទ្ធតែជាពួកឃាតករភេរវករដែលមានជំនាញត្រូវបានបង្វឹកដោយរដ្ឋាភិបាលក្រុងហាណូយ។ អា ហ៊ុន-សែន បានចំណាយលុយដ៏ច្រើនបំផុតទៅលើបណ្តាញចារកម្មសំងាត់ ជាពិសេសគឺអង្គការឧក្រិដ្ឋជនសំងាត់អាវឈុតខ្មៅតែម្តង ព្រោះពួកនេះត្រូវបានបែងចែកជាច្រើនក្រុម ច្រើនពួក អោយធ្វើការខុសៗគ្នាទៅតាមជំនាញ និងទេពកោសល្យរបស់ពួកគេ ដូចជា ពួកជំនាញខាងបង្កប់ឧបករណ៏ចារកម្ម លាក់កំបាំងវត្ថុចារកម្មសំងាត់ គ្រឿងបរិក្ខារអសន្យាណូទំនើប spy camera, spy electronics, Hidden Camera, Ip spy Camera, Network Ip Camera, Convert Serveillance Spy electronics, Spy Cam, Suveillance Camera, Bug, ……… ក្រុមតាម

ដានដែលមានជំនាញប្រើប្រាស់មូនីទឺតាមដានដូចជា Computer Monitor, Cell phone Monitor ,,,,,,ក្រុមចារឃាតករ,,,,,,ក្រុមចារជំនួយ,,,,,,ក្រុមចារក្លែងភេទ,,,,,,ក្រុមចារត្រួសត្រាយឧបសគ្គ,,,,,,,ក្រុមចារបេសកកម្ម,,,,,,,, ហើយការតាមដានគោលដៅប្រមាញ់នីមួយៗនោះ អា ហ៊ុន-សែន តែងតែប្រើក្រុមចារជនទាំង ៥ គឺចារបុរសមនុស្សក្នុង ចារបុរសរនុក្នុង ប្រតិចារបុរស ចារបុរសមនុស្សរស់ និងប្រតិចារបុរសដែលបែងភាគជា៣ក្រុមគឺ ក្រុមទី១ ទៅតាមដានដែលបំពាក់ទៅដោយឧបករណ៍ចារកម្មអសន្សាណូទំនើប និងមានលិខិតបេសកកម្មពិសេសរួមទាំងកាតសំងាត់ផង រីឯក្រុមទី២គឺតាមដានក្រុមទី១ និងតាមដានគោលដៅប្រមាញ់ ព្រមទាំងជួយក្រុមទីមួយជាសំងាត់ ឬសំលាប់កំទេចក្រុមទី១ តាមបញ្ជាថ្នាក់លើ ចំណែកក្រុមទី៣ គឺតាមដានក្រុមទី១ និងក្រុមទី២ បើខុសប្រក្រតី គឺសំលាប់កំទេចចោល ហើយនៅក្រុមនិមួយៗតែងតែមានមនុស្សជាច្រើនផ្លាស់ប្តូរវេនគ្នាតាមដាន និងប្តូរគោលដៅតាមដានផងដែរ។ សូមបញ្ជាក់ថាក្រុមចារបុរសទាំង៣ក្រុមនេះ គឺក្រុមទី១មិនស្គាល់ក្រុមទី២ទេ ក្រុមទី២មិនស្គាល់ក្រុមទី៣ទេ តែក្រុមទី៣ស្គាល់ក្រុមទី១ និងទី២ ហើយរងចាំសំលាប់ក្រុមទាំងពីរពេលមានបញ្ជាពីថ្នាក់លើ។ ចំណែកឯពួកក្រុមចារកិច្ច និងក្រុមខ្លា-ស របស់កងកំលាំងប្រដាប់អាវុធ និងក្រុមអេស-អូ-វ៉ាយ តាមដានគោលដៅនោះដែរ។ ដោយសារតែលុយច្រើនដ៏សន្ធឹកដែលបានមកពីជំនួយ កំចីបរទេស លុយចំណូលថវិការជាតិ លុយលក់ធនធានធម្មជាតិ លុយរបរម៉ាហ្វីយ៉ា ដែលអា ហ៊ុន-សែន ទទួលបាន គឺយកមកចំណាយលើប្រព័ន្ធបណ្តាញចារកម្មដើម្បីក្តាប់ពត៌មាននៅក្នុងដៃពង្រឹងអំណាច កំទេចពួកជាតិនិយមខ្មែរ ពួកអ្នកប្រឆាំង និងបង្កើនល្បឿនពន្លឿនសំរេចបេសកកម្មបេសកកម្មរំលាយជាតិខ្មែររបស់ក្រុងហាណូយ។

**(២)-កូរទឹកឱ្យល្អក់ដើម្បីចាប់ត្រី បង្កើតបញ្ហាក្នុងបញ្ហា ប្រឌិតល្បែនក្នុងល្បែនះ** ដោយបង្កើតចេញនៅភាពច្របូកច្របល់ វឹកវរចលាចល អសន្តិសុខ និងអស្ថេរភាពសង្គម បង្កើតចេញជាប្រតិមតិធ្វើអោយមានវិកលគំនិតក្នុងខួរក្បាលប្រជារាស្ត្រក្នុការវិភាគសភាពការណ៍ពិត និងមិនអាចថ្លឹងថ្លែងតថភាពនៃជំរៅនយោបាយ។ ការចេញប្រតិបត្តិការប្លន់ជីវិតសំលាប់យ៉ាងសាហាវ មិនត្រឹមតែរកលុយចំណូលអោយបក្សប៉ុណ្ណោះទេ ប៉ុន្តែវាមានប្រយោជន៏នៅក្នុងការបង្ករអសន្តិសុខសង្គម និងអស្ថេរភាពសង្គម បង្ករភាពភ័យខ្លាចដល់ប្រជាជនខ្មែរមិនហ៊ាននិយាយស្តីអារកាត់នៅរឿងហេតុពិតដែលកើតមានជាក់ស្តែង ហើយសុខចិត្តដាំដើមគរ ធ្វើទីងម៉ោង

ចាំចាប ដើម្បីរក្សាជីវិតអោយបានរស់ ហើយប្រជាជនម្នាក់ៗស្ទើរតែមិនហ៊ានចេញពីផ្ទះ (លើកលែងតែករណីចាំបាច់នោះ) ជាហេតុនាំអោយគណៈបក្សប្រជាជនធ្វើអ្វីៗស្រេចតែចិត្តនឹកឃើញ ឆ្លៀតឱកាសពង្រឹងអំណាច ពង្រីកឥទ្ធិពល កំចាត់ពួកអ្នកគាំទ្រឬសកម្មជនរបស់គណៈបក្សប្រឆាំង ដោយបាញ់សំលាប់ ឬក៏ចាប់ចងតាមចិត្តរបស់ពួកគេ ដោយគ្រាន់តែប្រើលេសចោទថាជាចោរ ជាឃាតករ ជាជនសង្ស័យតែប៉ុណ្ណោះ។ ម្យ៉ាងវិញទៀត ភារកិច្ចចម្បងបំផុតនៃបេសសកម្មរបស់ពួកសមាជិកអង្គការឧក្រិដ្ឋជនសំងាត់អាវឈុតខ្មៅគឺផ្សព្វផ្សាយពត៌មានក្លែងក្លែង សាបព្រុសពត៌មានមិនពិត បំផ្លើសពត៌មាន ប្រឌិតហេតុការណ៏ពត៌មាន បំផ្លៃងពត៌មាន បំផុសពត៌មាន បំភ្លៃពត៌មានគំរៀមកំហែងបំបាក់ស្មារតីប្រជារាស្ត្រខ្មែរអោយភ័យខ្លាចបាក់ស្បាត តក់ស្លត់តាមរយៈឃាតកម្មសំងាត់ដ៏សាហាវឃោរឃៅ ដោយគ្មានស្ថាប័នណាចាត់វិធានការជាមួយពួកឃាតករ ពួកភេរវករ ពួកចោរប្លន់ ពួកចោរចាប់ជំរិត,,,,,អ្វីឡើយ។ ផ្ទុយទៅវិញ ប្រជារាស្ត្រខ្មែរឃើញតែប្រព័ន្ធឃោសនារបស់រដ្ឋាភិបាលដូចជាទូរទស្សន៏ វិទ្យុ ទស្សនាវដ្ដី កាសែត ព្រឹត្តិប័ត្រ អង្គការឧក្រិដ្ឋជនសំងាត់ ជាពិសេសកាសែតម៉ាហ្វីយ៉ា របស់មេម៉ាហ្វីយ៉ារបស់លោក ថេង-ប៊ុនម៉ា ឈ្មោះថាការសែតរស្មីកម្ពុជា ([http://www.ask.com/wiki/Drugs_in_Cambodia](http://www.ask.com/wiki/Drugs_in_Cambodia)) ផ្សាយតែពីខ្មោចស្លាប់ មរណៈភាពគ្រោះថ្នាក់ផ្សេងៗ និងព្យាយាមបកស្រាយរឿងឃាតកម្មទាំងឡាយអោយឃ្លាតឆ្ងាយពីគណៈបក្សប្រជាជនកម្ពុជា និងភាពក្រៅក្របខណ្ឌ័នៃការទទួលខុសត្រូវរបស់រដ្ឋាភិបាលអាយ៉ងដោយបកស្រាយបញ្ហាឃាតកម្មភេរវកម្ម ការឆក់ប្លន់ជំរិត ការជួញដូរមនុស្ស ជួញដូរគ្រឿងញៀន,,,,,,,,នាំទំលាក់ទៅរករឿងឧប្បត្តិហេតុរឿងចៃដន្យ រឿងគ្រោះថ្នាក់ចរាចរ រឿងគំនុំផ្ទាល់ខ្លួន រឿងគំនុំគ្រួសារ រឿងញៀនថ្នាំ រឿងស្រវឹងបាត់ស្មារតី រឿងប្រកួតប្រជែង រឿងច្រណែនឈ្នានីស រឿងយល់ច្រលំ រឿងចោរកម្ម ឆក់ប្លន់ជំរិត រឿងល្បែងស៊ីសង រឿងវាយតប់ រឿងឈ្លោះគ្នា,,,,,,,,ហើយបែរជាផ្សាយលើកតំកើនពួកមេដឹកនាំឱ្យខ្ពស់ដូចព្រះអាទិទេព និងផ្សាយប្រឌិត រឿងហេតុបកស្រាយឱ្យប្រាសចាកក្រៅសាច់រឿងពិតដែលទាក់ទងនឹងបទឧក្រិដ្ឋឃាតកម្ម ភេរវកម្ម,,,,, ជួយលាងកំហុសអោយឃាតករ ភេរវករ និងពួកជនឧក្រិដ្ឋទៅវិញ។ ក្រៅពីបំផុសពត៌មានដើម្បីបំពុលស្មារតីប្រជារាស្ត្រខ្មែរ ពង្វក់ខួរក្បាលយុវជនខ្មែរអោយចេះប្រព្រឹត្តិបទល្មើសគ្រប់យ៉ាង ចេះសូកប៉ាន់រកខ្នងបង្អែក លើកទឹកចិត្តអោយហ៊ានធ្វើអំពើឃាតកម្ម លួចឆក់ប្លន់ជំរិត ជួញដូរគ្រឿងញៀន ជួញដូរមនុស្សខុសច្បាប់ និងប្រើប្រាស់គ្រឿងញៀននោះ ពួកសមាជិកអង្គការឧក្រិដ្ឋជនសំងាត់អាវ

ឈុតខៅ ពូកែនិងប្រសព្វប្រើល្បិចកលឃោសនាបំបែកបំបាក់ប្រជារាស្ត្រខ្មែរ ឥស្សរៈជនវរៈជនខ្មែរ ពួកអ្នកស្នេហាជាតិខ្មែរ និងពួកអ្នកនយោបាយប្រឆាំង អោយបែកបាក់គ្នា មិនទុកចិត្តគ្នា ស្អប់ខ្ពើមគ្នា និងមានគំនិតបំផ្លាញឈ្នានីស គំនិតមោទនភាពហួសហេតុដោយសារតែការបញ្ចោលើកដាក់បញ្ចេញបញ្ចូលបន្ថែមល្បោយរបស់ពួកអង្គការឧក្រិដ្ឋជនសំងាត់អាវឈុតខៅ ពួកអង្គការឧក្រិដ្ឋជនសំងាត់អេស-អូ-វ៉ាយ និងប្រពន្ធ័ឃោសនារបស់រដ្ឋាភិបាលអាយ៉ង សហការជាមួយប្រពន្ធ័ឃោសនារបស់ពួកម៉ាហ្វីយ៉ាដូចជាកាសែតរស្មីកម្ពុជា (http://www.ask.com/wiki/Drugs_in_Cambodia) ជាដើម,,,,,។

**(៣)-ឃាតកម្ម ភេរវកម្ម និងអនុវត្តយុទ្ធបាយសំលាប់មួយគំរៀម១០០០៖** ការឈ្លានពានលេបត្របាក់ទឹកដីខ្មែរត្រូវបានលោក ហូ-ជីមិញ អនុវត្តន៏តាមយុទ្ធសាស្ត្រយុទ្ធសាស្ត្រយូរអង្វែង ព្រោះថាដាំដើមឈើគឺចំណាយពេលតែ១០ ឬ២០ ឆ្នាំ នឹងទទួលផលផ្លែផ្កា តែដាំបណ្តុះធនធានមនុស្សគឺចំណាយពេលរាប់ជំនាន់ទើបអាចសំរេចមហិច្ឆិតាលេបទឹកដីខ្មែរបាន ហេតុនេះហើយទើបលោក ហូ-ជីមិញ បង្កើតបក្សកុំមុយនីស្ត៍ចិន ( http://www.britannica.com/EBchecked/topic/268300/Ho-Chi-Minh ) នៅទីក្រុងហុងកុង នាថ្ងៃទី ៣ ខែកុម្ភៈ ឆ្នាំ ១៩៣០ ( http://www.u-s-history.com/pages/h1863.html and http://news.bbc.co.uk/2/hi/asia-pacific/country_profiles/1243686.stm )ហើយនៅចុងឆ្នាំ ១៩៥០ លោក ហូ-ជីមិញ និងថ្នាក់ដឹកនាំវៀតមិញ បានពិភាក្សាគ្នាជាមួយលោក យូសែហ្វ ស្តាលីន (Joseph Stalin) មេដឹកនាំសហពន្ធ័សហភាពសូវៀត លោកស្តាលីន ពេញចិត្តនឹងការបង្កើតគណៈបក្សប្រជាជនកម្ពុជា ( http://www.foia.cia.gov/CPE/ESAU/esau-53.pdf ) ប៉ុន្តែគ្រាន់តែជាល្បិចប្រើខ្លាអោយអូស នង្គ័លតែប៉ុណ្ណោះ ព្រោះថាការសុំការយល់ព្រមពីលោក ស្តាលីនគឺគ្រាន់តែដើម្បីអូសយកជំនួយពីសហព័ន្ធសហភាពសូវៀត មិនខុសពីយួនប្រើអា ហ៊ុន-សែន ឱ្យ បោកអង្គការសហប្រជាជាតិបង្កើតតុលាការសាលាក្តី ខ្មែរក្រហម កាត់ទោសសំដែងល្ខោនលាងកំហុស លាងទោសបទឧក្រិដ្ឋកម្មរបស់រដ្ឋាភិបាលក្រុងហាណូយដែលបានឈ្លានពានខ្មែរនៅឆ្នាំ ១៩៧៩ នោះទេ។ ទីបំផុតបក្សកំមុយនីស្ត៍ខ្មែរបង្កើតបក្សកុំមុយនីស្ត៍ខ្មែរមានឈ្មោះថា "បក្សប្រជាជនបដិវត្តន៏កម្ពុជា" នៅឆ្នាំ១៩៥១ (http://opus.macmillan.yale.edu/workpaper/pdfs/GS20.pdf and

http://en.wikipedia.org/wiki/Communist_Party_of_Kampuchea ) ។

| | |
|---|---|
| <br>លោក ហូ-ជីមិញ បង្កើតបក្សកំមុយនីស្ដឥណ្ឌូចិននៅឆ្នាំ ១៩៣០ ដើម្បីក្តោបយកប្រទេសឡាវ និងកម្ពុជា។ | <br>http://padevat.info/2009/12/08/son-ngoc-minh-1952/ លោក ស៊ឺង-ង៉ុកមិញ ត្រូវបានចាត់តាំងដោយ លោក ហូ-ជីមិញ អោយធ្វើមេដឹកនាំបក្សប្រជាជនបដិវត្តន៏កម្ពុជា ដើម្បីលេបយកប្រទេសខ្មែរ។ |

ដែលយួនកំមុយនីស្ដ៏តែងតែផ្លាស់ប្ដូរយុទ្ធសាស្ត្រចុះឡើងដើម្បីពង្វក់បង្វែងដានសហគមន៏អន្តរជាតិមិនអោយយល់សាច់រឿង រហូតដល់ចេញជារបបខ្មែរក្រហមសំលាប់រង្គាលប្រជាជនខ្មែរអស់ជិត៣លាននាក់ ហើយទីបំផុតយួនកំមុយនីស្តបានប្ដូរយុទ្ធសាស្ត្រសំលាប់ខ្មែរទាំងដុលទ្រង់ទ្រាយធំ មកជាយុទ្ធសាស្ត្រសំលាប់ខ្មែរតក់ៗទៅវិញ គឺយួនកំមុយនីស្ដ៏បានលុបរបបខ្មែរក្រហមប្រែមកជារបបរដ្ឋាភិបាលអាយ៉ងវិញ ហើយនៅចុងខែធ្នូ ឆ្នាំ ១៩៧៨ កងទ័ពវៀតណាមចំនួនជាង ១៥ ម៉ឺន នាក់ មកវាយលុកលុយយកប្រទេសខ្មែរជាចំហរ ដោយ (http://en.wikipedia.org/wiki/Cambodian%E2%80%93Vietnamese_War ) វាយលុកឈ្លានពានខ្មែរនៅឆ្នាំ ១៩៧៨ ដល់ ឆ្នាំ ១៩៧៩ ស្របពេលដែលកងទ័ពរដ្ឋាភិបាលក្រុងហាណូយបានដែលត្រូវបានរក្សាទុកនៅក្នុងប្រទេសឡាវចំនួនពី ៤0000 (៤ ម៉ឺនន)ទៅ ៦0000 (៦ ម៉ឺន) នាក់ ដើម្បីគ្រប់គ្រងប្រទេសឡាវ និងកើបប្រមូលភោគទ្រព្យធនធានធម្មជាតិ ទ្រព្យសម្បត្តិរបស់ប្រទេសឡាវ (http://countrystudies.us/vietnam/59.htm ) ។ ដើម្បីពង្រីកឥទ្ធិពល ពង្រឹងអំណាច និងធ្វើអោយមានភាពស្របច្បាប់នៃការឈ្លានពានលេបត្របាក់ទឹកដីខ្មែររបស់វៀតណាម រដ្ឋាភិបាលក្រុងហាណូយបានប្រើ

គ្រប់យុទ្ធោបាយសឹកប្រទាក់ក្រឡាគ្នាចាក់ច្រែះគួបត្របាញ់ចូលគ្នាផ្តួងមួយនៅក្នុង **ការបន្តគោលនយោបាយរំលាយពូជសាសន៍ និងជាតិសាសន៍ខ្មែរ ការប្រើលិទ្ធិផ្តាច់ការតាមបែបកុំមុយនីស្តដោយយកឃាតកម្ម និងភេរវកម្ម ធ្វើជាឧបករណ៍តែមួយគត់សំរាប់គ្រប់គ្រងប្រទេសតាមយុទ្ធសាស្រ្តសំលាប់មួយគំរៀម១000** ធ្វើការសំលាប់ផ្តាច់ផ្តៅច ក្កិចត្រួយ ជីករឹស រំលើងគល់ ដុតដើម បំផ្លាញមែកសាខា ប្រហារពួកអ្នកជាតិនិយមឱ្យក្ស័យ ប្រល័យវរៈជនខ្មែរអោយសូន្យ ពូនផ្តុំពួកល្ងង់ស្មើរខ្លៅអោយគ្រងអំណាចគ្រប់គ្រងប្រទេស ពាក់ផ្លាកបណ្ឌិតក្លែងធ្វើអ្នកចេះ បើពួកអាយ៉ងណាមួយអនុវត្តបេសសកម្មក្រុងហាណូយមិនបានល្អ ត្រូវតែកំទេចចោល ហើយបន្តុបអាយ៉ងថ្មីអោយគ្រប់គ្រងប្រទេសកម្ពុជាជំនួសអាយ៉ង សមដូចសម្តីរបស់លោកហូ-ជីមិញ ពោលថា **"ទំពាំងត្រូវតែធំជាងឬស្សី បើទំពាំងតូចជាងឬស្សី គឺជាទំពាំងស្អុយ បើទំពាំងស្អុយគឺត្រូវតែជីករំលើងចោល"** ជាក់ស្តែងណាស់ លោកប៉ែន-សុវណ្ណ ត្រូវបានយួនកុំមុយនីស្តជីករំលើងចេញពីមុខ



តំណែងដោយសារតែយួនកំមុយនីស្ត៍បានចាត់ទុកថាលោក ប៉ែន-សុវណ្ណ ជាទំពាំងស្អុយ ដែលត្រូវតែជីករំលើងចោលជាដាច់ខាត ដែលត្រូវបានយួនចាប់ខ្លួននៅខែធ្នូ ឆ្នាំ ១៩៨១ ដាក់គុកនៅក្រុងហាណូយ ៧ ឆ្នាំ និងដាក់ឃុំក្នុងផ្ទះ ៣ឆ្នាំ http://angkor1431.tripod.com/index/id24.html ហើយបានលើកបន្តុបអា ហ៊ុន-សែន (ឈ្មោះ ដើមគឺ ហ៊ុន-ណាល់ ដែលជាចោរលួចខ្វាក់ភ្នែក) មកជំនួសតំណែងលោក ប៉ែន-សុវណ្ណ ព្រោះថាបើយួន លើកបន្តុបអ្នកចេះដឹង គឺពិបាកប្រើ ពិបាកពង្វក់ណាស់ តែបើលើកចោរខ្វាក់គឺ ងាយស្រួលញាក់ពង្វក់ គ្រាន់រំលឹងវាថា **"ហ្អែងចង់ធ្វើចោរវិញឬ?"** គឺអា ហ៊ុន-សែន ប្រឹងប្រែងបំពេញបេសសកម្មជូនក្រុងក្រុងហាណូយ ១ ទ្វេជា១០។ ហេតុនេះហើយ ដើម្បីសងគុណយួន គឺអា ហ៊ុន-សែន ខំប្រឹងសំរេចបេសកកម្មរំលាយជាតិខ្មែររបស់ក្រុងហាណូយ ដែលអាហ៊ុន-សែន សំលាប់ជនជាតិខ្មែរជាបន្តបន្ទាប់តាមរយៈអង្គការឧក្រិដ្ឋជនសំងាត់បាក់គី អេស-អូ-វ៉ាយ និងអង្គការឧក្រិដ្ឋជនសំងាត់អាវឈុតខ្មៅ ដែលយួនកំមុយនីស្ត៍ចែកពួកសមាជិកអង្គការឧក្រិដ្ឋជនសំងាត់អាវឈុតខ្មៅជា ៣ ភាគ គឺ មួយភាគអោយលោក ហុក-ឡង់ឌី មួយភាគទៀតអោយអា ហ៊ុន-សែន។ អា ហ៊ុន-សែន ខំជ្រើសរើសខ្មែរមកបញ្ចូលជាពួកសមាជិកអង្គការឧក្រិដ្ឋជនសំងាត់អាវឈុតខ្មៅកើនទ្វេ១ជា១០ គឺពិតជាឆ្អែតស្គាល់ចិត្តម្ចាស់មែន! ទោះបីជា **ហ៊ុន-សែន ល្ងង់ខ្លៅអាប់ប្រាជ្ញា លោភលន់ដុល្លា និងអំណាច តែអាភ្នែកខ្វាក់ភ្នែកមានចិត្តស្មោះ**

**ប្រល័យរាស្ត្រខ្មែរល្អឥតខោះ លើសផែនការយួនកំណត់ រាស្ត្រខ្មែរហៅ ហ៊ុន-សែន ថាជនក្បត់ យួនស្មាត់កលយុទ្ធហៅវីរៈបុរស**។ ទោះបីអា ហ៊ុន-សែន ជាចោរលួចខ្វាក់ភ្នែក រៀនបានត្រឹមតែថ្នាក់ទី៤ នៅវិទ្យាល័យព្រះសីហានុខេត្តកំពង់ចាមក៏ដោយ ប៉ុន្តែយួនបានបង្វឹកក្បួនប្រហារ និងកលយុទ្ធប្រល័យមនុស្សស្មាត់ជំនាញណាស់ ហើយនៅពេលដែលយួនដឹងថា ខ្មែរជាប់ទ្រុងរបស់យួនរកច្រកចេញមិនរួច ចាប់ពីរដ្ឋប្រហារថ្ងៃ ៥-៦ ខែកក្កដា ឆ្នាំ១៩៩៧ មក យួនបានពិសោធន៍ខ្មែរប្រៀបដូចពិសោធន៍សង្គមសត្វព្រៃនាសម័យមនុស្សបុព្វកាលដោយព្យាយាមយកប្រជាជនខ្មែរអោយរស់ក្នុងពិភពគុណសម័យបុរាណចិនប្រៀបទៅនឹងរឿងភាគបុរាណចិន ដោយអោយអា ហ៊ុន-សែន មើលរឿងភាគនិទានខ្សែភាពយន្តចិនជារៀងរាល់ថ្ងៃ ហើយដកស្រង់ល្បិចពីរឿងភាគចិនមកប្រល័យជនជាតិខ្មែរ និងល្បិចបំផ្លាញខ្មែរតាមការដែលអា ហ៊ុន-សែន អាចធ្វើទៅរួច ដោយយួនគ្រាន់តែជួយតំរង់ផ្លូវ ផ្តល់យោបល់ បង្ហាញច្រកដល់ ហ៊ុន-សែន តែប៉ុណ្ណោះ រហូតដល់ ហ៊ុន-សែន ងប់ងល់នឹងរឿងភាគបុរាណភាគសម័យចិន ភ្លេចគិតថា ខ្លួនជានាយករដ្ឋ ក៏ស្រែកព្រុសតាមរឿងភាគចិន ដូចជាមើលរឿងទេវបុត្រណាចា ពេលឃើញឈុតអ្នកគុណនិយម ហាត់វិជ្ជាគុណយុទ្ធសិល្ប៍កណ្តាប់ដៃដែក ហ៊ុន-សែន ក៏ប្រកាសអនុវត្ត **យុទ្ធការកណ្តាប់ដៃដែក** ហើយ នៅពេលឃើញឈុតបិសាចកញ្ច្រោងអុកឡុករាជវាំង ហ៊ុន-សែន ក៏ប្រកាសថា **មេបិសាចកញ្ច្រោង**។ នៅពេលមើលរឿងភាគសម័យនិយាយអំពីជួញដូរគ្រឿងញៀនរបស់ក្រុមអន្ធពាល ក៏ តាំងខ្លួនជាមេលោកបងធំ នាំលោក ថេង-ប៊ុនម៉ា មករកស៊ីគ្រឿងញៀនចូលហ៊ុនជាមួយ និងបង្កើតក្រុមបងតូចបងធំទូទាំងប្រទេសនៅឆ្នាំ ១៩៩៧ ដែលមានឈ្មោះថាអង្គការឧក្រិដ្ឋជនសំងាត់អេស-អូ-វ៉ាយ សំលាប់រាស្ត្រខ្មែរយ៉ាងរង្គាល តែមើលទៅស្រដៀង ពួកឆ្មាំក្រហមរបស់លោក ម៉ៅ-សេទុង នាសម័យបដិវត្តន៍វប្បធម៌ តែបើសិក្សាល្អិតល្អន់ គឺ ហ៊ុន-សែន យកស្នាយតាមគំរូភាគសម័យចិនទេ។ ពេលបំពេញបេសសកម្មក្រុងហាណូយដោយគិតពិចារណាដើម្បីគាប់ចិត្តចៅហ្វាយក្នុងនាមជាឆ្កែស្គាល់ចិត្ត បានប្រើក្រុមបងតូចបងធំនៃអង្គការឧក្រិដ្ឋជនសំងាត់ អេស-អូ-វ៉ាយ វាយស្ថានទូតថៃប្រចាំក្រុងភ្នំពេញ នាខែមករា ឆ្នាំ ២០០៣ ហើយគៀងលេសទៅរកបញ្ហាព្រំដែនរហូតដល់ថៃគំរាមបកវិញ ទើបយួនដឹង វិសនឹងខាតដើម ក៏កែកុនបញ្ហា ដោយអោយ ហ៊ុន-សែន ព្យាយាមសំដែងអោយដូចជាកូនអុករបស់ចិន ទោះមិនទំនងក៏ដោយ ដើម្បីយកឥទ្ធិពលចិនគំរាមថៃ មិនអោយច្រឡោតតបតដោយហឹង្សា ហើយធ្វើអោយថៃខ្លាចប្រទេសចិនលូកដៃ ជួយយួនដើម្បីឈ្លានពានប្រទេសថៃ។ ទោះបីជាយួនប្រើអា ហ៊ុន-សែន

អោយនៅស្មៀម មិនព្រុសមិនខាំថៃ ក៏ដោយ ក៏យួនរងចាំឱកាសដែលថៃភ្លេចខ្លួន នឹងវាយលុកឈ្លានពានថៃ និងលេបប្រទេសថៃដូចលេបប្រទេសខ្មែរ ហើយទីបំផុតចាប់ឥស្សរៈជនថៃកាត់ទោសដូចកាត់ទោសខ្មែរក្រហម ព្រោះថាប្រទេសថៃសន្តិភាពយូរឆ្នាំ ខ្វះការប្រុងប្រយត្ន័ ភ្លេចគិតថា យួនគឺយួន ទោះបីពួកវាពាក់ផ្លាកសេរី ឬកំមុយនីស្ត គ្រាន់តែជាលេសប៉ុណ្ណោះ ហើយបច្ចុប្បន្ននេះជនជាតិយួននៅប្រទេសថៃ មានទាំងស៊ីវិល និងព្រះសង្ឃក្លែងភេទ យកវត្តអារាមថៃធ្វើជាទីកន្លែងប្រជុំសំរេចយុទ្ធសាស្រ្តផែនការឈ្លានពានថៃ។



http://oneclick.indiatimes.com/photo/0ckTggn6jqbPG

**អាសាន:** យុិ! លោក វិន-ជាប៉ាវ ទើបតែបានឆ្កែមកពីណាណ៎! ឆ្កែនេះឆ្លាតដល់ហើយ!សូម្បីតែដំណើរបោះជំហ៊ានរបស់លោក វិន-ជាប៉ាវ ក៏វាធ្វើដូចដែរ! មើលណ៎! វាសំលឹងមើលដំណើរជើងរបស់ម្ចាស់វាឥតដាក់ភ្នែកសោះ!

**អាចូច:** អូ! ឆ្កែនេះជាឆ្កែរបស់យួនទេតើ! មិនដឹងថាលោក វិន-ជាប៉ាវ ទិញពីយួន ឬក៏លួចពីយួន ឬក៏ខ្ចីយួនយកមកប្រើ!

**អាសាន:** ទំលាប់ចិនកាប់ឆ្កែស៊ីរឿយ! បើសិនលោក វិន-ជាប៉ាវ ខ្ចីឆ្កែនេះពីយួនមកប្រើ គឺមិនអ៊ីទេ! ប៉ុន្តែបើគាត់លួចពីយួនវិញ ច្បាស់ជាឆ្កែនេះចូលឆ្នាំងហើយរឿយ!

**(៤)-រកលុយចំណូលអោយគណៈបក្សប្រជាជនកម្ពុជាតាមរយៈរបរម៉ាហ្វីយ៉ាបែបកុំមុយនីស្ត:** ពួកសមាជិកអង្គការឧក្រិដ្ឋជនសំងាត់អាវឈុតខ្មៅនេះ ក្រៅសំលាប់ឃាតកម្ម ភេរវកម្ម និងប្រព្រឹត្តិបទឧក្រិដ្ឋសព្វយ៉ាង ពួកគេហ៊ានពលីជីវិតធ្វើអ្វីៗគ្រប់យ៉ាងដើម្បីសំរេចបេសសកម្មរបស់បក្ស ហើយពួកគេមានជំនាញខាងរកលុយចំណូលអោយបក្សខ្លាំងណាស់ ហើយគណៈបក្សប្រជាជនកម្ពុជា ជាពិសេសអា ហ៊ុន-សែន តែម្តង តែងតែ

ហៅពួកអង្គការឧក្រិដ្ឋជនសំងាត់អាវឈុតខ្មៅនេះថាជា "**ក្រុមកងអត្តឃាតពិសេស**" ។ ពួកសមាជិកអង្គការឧក្រិដ្ឋជនសំងាត់អាវឈុតខ្មៅមានការស្ទាត់ជំនាញក្នុងការរកស៊ីជួញដូរគ្រឿងញៀនខ្លាំងណាស់ ព្រោះពួកគេមានតំណែងធំៗនៅក្នុងជួរកងកំលាំងប្រដាប់អាវុធប៉ូលីស ទាហ៊ាន កងរាជអាវុធហត្ថ និងមានឥទ្ធិពលលើពួកឈ្មួញ និងពួកក្រុមក្មេងស្ទាវ ក្រុមបងតូចបងធំនៃអង្គការឧក្រិដ្ឋជនសំងាត់ អេស-អូ-វ៉ាយ ។ ប្រភពចំណូលធំជាងគេបំផុតរបស់គណៈបក្សប្រជាជនកម្ពុជា គឺពាណិជ្ជកម្មគ្រឿងញៀន (ធំជាងចំណូលដែលបានមកពីអំពើពុករលួយលួចលុយចំណូលជាតិ លុយលក់ធនធានធម្មជាតិ លុយជំនួយបរទេស និងលុយកម្ចីបរទេស) ហើយបើតាមប្រភពឯកសារដែលមានចំណងជើងថា U.S. accuses Hun Sen on drugs;terrorism ប្រទេសកម្ពុជាជាប្រទេសនាំចេញគ្រឿងញៀនប្រភេទហេរ៉ូអ៊ីន និងកញ្ឆាធំបំផុតនៅអាស៊ីអាគ្នេយ៍ទៅកាន់ទ្វីបអ៊ឺរ៉ុប ជាក់ស្តែងនៅឆ្នាំ ១៩៩៦ គ្រឿងញៀនកញ្ឆាទំនង់ ១២០ តោន របស់កម្ពុជា ត្រូវបានចាប់រឹបអូសបាននៅក្នុងទ្វីបអ៊ឺរ៉ុប សូមអាន http://www.garella.com/rich/grenpost.htm ។ គ្រឿងញៀនកញ្ឆាទំងន់ ៧តោន របស់ក្រុមហ៊ុនម៉ុង-រិទ្ធី ត្រូវបានក្រុមប៉ូលីសចាប់នៅកំពង់ផែក្រុងព្រះសីហនុនៅឆ្នាំ ១៩៩៧ តែត្រូវបាន ហ៊ុន-សែន កាងមិនអោយនរណាប៉ះពាល់លោក ម៉ុង-រិទ្ធី ជាដាច់ខាត និងថ្នាំញៀនហេរ៉ូអ៊ីន ទំងន់ ៣៦ គីឡូក្រាម ដែលពាក់ព័ន្ធនឹងលោក ដុំ-ហាក់ និងលោក សៅ-សុខា សូមអាន http://ki-media.blogspot.com/2006/08/transcript-and-original-statement-of.html

ក្រៅពីនេះ ពួកសមាជិកអង្គការឧក្រិដ្ឋជនសំងាត់អាវឈុតខ្មៅនេះរកស៊ីប្លន់ជីវិត ឃាតកម្ម ជួញដូរមនុស្ស រកស៊ីរបរខុសច្បាប់ និងរកស៊ីកាងបាញ់បោះជាដើម ។ ដូចជាករណីអារ៉ាស្មាច់ ជាអង្គរក្សរបស់ ហ៊ុន-សែន និងជាសកម្មជនក្នុងអង្គការឧក្រិដ្ឋជនសំងាត់អាវឈុតខ្មៅ ជាមួយលោក មុំ-ម៉េត តាមប្រភព (Source[45]) បើយោងតាមលោក ហង្ស-វុធថា ជាបងប្រុសរបស់លោក ហង្ស-វុទ្ធី ហៅយមរាជ បាននិយាយប្រាប់ខ្ញុំនៅអាគារសេនៃគុកព្រៃស នៅថ្ងៃទី ២១ ខែមិថុនា ឆ្នាំ ២០០៧ ថាលោក អារ៉ាស្មាច់គឺជាចោរចាប់ជីវិតដ៏ល្បីល្បាយនៅកម្ពុជាដែលរកលុយបានច្រើនរាប់មិនអស់ជូន ហ៊ុន-សែន និងគណៈបក្សប្រជាជនកម្ពុជា ហើយ

ទីបំផុតត្រូវបានលោកជា-សុផារ៉ា ទូរស័ព្ទប្រាប់អារ៉ាស្នាច់ អោយចុះពីបូឱញទៅទំលាប់ប្រទេសវៀតណាម ហើយបានត្រៀមរៀបចំកងកំលាំងបាញ់សំលាប់អារ៉ាស្នាច់បំបិទមាត់ ដោយសារតែលោកអារ៉ាស្នាច់ បានកឹបកេងលុយរបស់បក្ស មិនស្មោះត្រង់នឹង ហ៊ុន-សែន គឺជាជនក្បត់បក្ស ព្រោះលោក អារ៉ាស្នាច់ បានកឹបកេងយកលុយ ចំនួនប្រាំម៉ឺនដុល្លាគឺ ៥០០០០ដុល្លាអាមេរិក ($U.S 50,000)ដែលបានមកពីការជំរិត (រៀចចំដោយ ហ៊ុន-សែន និងគណៈបក្សប្រជាជនកម្ពុជា) យកទៅអោយបកប្រុសនៅម៉ុំដេអ៊ិន និងបានអោយម្តាយខ្លះ ប៉ុន្តែបន្ទាប់ពីលោក ជា-សុផារ៉ា បាញ់សំលាប់អារ៉ាស្នាច់យ៉ាងសាហាវ គណៈបក្សប្រជាជនកម្ពុជាបានចាប់បងប្រុស និងម្តាយរបស់អារ៉ាស្នាច់ដាក់គុក តែម្តាយជាប់គុកតែមួយឆ្នាំ ត្រូវបានដោះលែងវិញ។

ការចេញប្រតិបត្តិការប្លន់ជំរិតសំលាប់យ៉ាងសាហាវ មិនត្រឹមតែរកលុយចំណូលអោយបក្សប៉ុណ្ណោះទេ ប៉ុន្តែវាមានប្រយោជន៍នៅក្នុងការបង្ករអសន្តិសុខសង្គម និងអស្ថេរភាពសង្គម បង្ករភាពភ័យខ្លាចដល់ប្រជាជនខ្មែរ មិនហ៊ានិយាយស្តីអារកាត់នៅរឿងហេតុពិតដែលកើតមានជាក់ស្តែង ហើយសុខចិត្តដាំដើមគរ ធ្វើទីងមោងចាំចាប់ ដើម្បីរក្សាជីវិតអោយបានរស់ ហើយឆ្លៀតពេលដែលប្រជាជនភ័យខ្លាចបាក់ស្បាត ស្ទើរតែមិនហ៊ានចេញពីផ្ទះ (លើកលែងតែករណីចាំបាច់នោះ) គណៈបក្សប្រជាជនកម្ពុជាឆ្លៀតឱកាសពង្រឹងអំណាចពង្រីកឥទ្ធិពលកំចាត់ពួកអ្នកគាំទ្រឬសកម្មជនរបស់គណៈបក្សប្រឆាំង ដោយបាញ់សំលាប់ ឬក៏ចាប់ចងតាមចិត្តរបស់ពួកគេ ដោយគ្រាន់តែចោទថាជាចោរ ជាឃាតករ ជាជនសង្ស័យតែប៉ុណ្ណោះ លើសពីនេះទៅទៀតគណៈបក្សប្រជាជនកម្ពុជាអាចកើបលុយចំណូលជាតិតាមរយៈអំពើរពុករលួយនិងរបរម៉ាហ្វីយ៉ារបស់ខ្លួន លួចឆក់ប្លន់ជំរិត សំលាប់ ជួញដូរគ្រឿងញៀន ជួញដូរមនុស្ស ប្លន់ទ្រព្យសម្បត្តិគ្រប់យ៉ាងរបស់ប្រជាជន ព្រមទាំង**ប្លន់ដីធ្លីប្រជាជនតាមតែអំពើចិត្ត** ក្នុងនាមជា**ត្រីងៀតឆ្លៀតពងគឺរកចំណូលពីភាពភ័យខ្លាចបាក់ស្បាតរបស់ប្រជាជនខ្មែរ**និង**ភាពទន់ខ្សោយនៃច្បាប់អន្តរជាតិ** ចាប់តាំងពីអង្គការសហប្រជាជាតិឃុបឃិតជាមួយ**ហ៊ុន-សែន** បង្កើតតុលាការសាលាក្តីខ្មែរក្រហម លាងកំហុសអោយយួន លុបលាងអំពើឧក្រិដ្ឋកម្មរបស់យួនកុំមុយនីស្តដែលបង្កើតលទ្ធិកុំមុយនីស្តខ្មែរក្រហមដើម្បីសំលាប់រង្គាលប្រជាជនខ្មែរ និងលាងសំអាតអំពើឈ្លានពានរបស់យួនកុំមុយនីស្តអោយក្លាយជាភាពស្របច្បាប់អន្តរជាតិ ព្រោះថាតុលាការសាលាក្តីខ្មែរក្រហមនេះ មិនបានលើកយកធាតុប្រវត្តិសាស្ត្រ និងធាតុនយោបាយមកកាត់ទោសទេ ថាតើនរណាជាអ្នក

បញ្ចពីក្រោយ រៀបចំផែនការនៅពីក្រោយឆាកសំលាប់រង្គាលនេះ? មានប្រទេសណាខ្លះដែលពាក់ព័ន្ធក្នុង បទឧក្រិដ្ឋ ផ្ទុយទៅវិញ តុលាការសាលាក្តីខ្មែរក្រហមនេះ បែរជាលេងល្បែងបែឡុកបែឡបែបក្មេងបៀមដៃ



យកគំរូដូច **ហ៊ុន-សែន** ចាប់ហេង-ពៅ កាត់ទោសលាងកំហុស លាងបទឧក្រិដ្ឋអោយគណៈបក្សប្រជាជន កម្ពុជា។ ដោយសារតែភាពអសកម្មខាងខួរក្បាល និងភាពឆ្កួតលីលាល្ងង់ខ្លៅរបស់សហគមន៏អន្តជាតិដែល ងប់ងល់នឹងផលប្រយោជន៏ដែល ហ៊ុន-សែន និងគណៈបក្សប្រជាជនផ្តល់អោយសហគមន៏អន្តរជាតិវិញនៅ ធនធានធម្មជាតិខ្មែរ សិទ្ធិវិនិយោគរកស៊ីស្រុកខ្មែរ និងផលកំរៃប្រាក់ជើងសារដែល ហ៊ុន-សែន ផ្តល់ដល់ពួក គេ ដែលពិបាកនឹងមើលឃើញ ឧទាហរណ៏ដូចជាករណីអា ហ៊ុន-សែន ចំណាយភាគរយដល់ពួកអ្នករត់ការ ជំនួយ ឧបមារថា បើបាន ១០០ លានដុល្លា ហ៊ុន-សែន អោយអ្នករត់ការពី ៣០ លាន ឬ ៤០ លានដុល្លានោះ រឿងអ៊ីដែលមិនប្រឹងធ្វើអោយបាន ព្រោះជាលុយរដ្ឋ លុយអង្គការទេតើ ចំណែកបុគ្គលមនុស្សគឺគ្រាន់ធ្វើការ ស៊ីប្រាក់ខែ ចំណែកលុយដែល ហ៊ុន-សែន ផ្តល់អោយគឺច្រើនណាស់ ឧទាហរណ៏មួយទៀត ដូចជាលោក អគ្គលេខាធិការនៃអង្គការសហប្រជាជាតិ មកលេងស្រុកខ្មែរ (គ្រាន់តែឧបមាលេងៗទេណា) យកពត៏មាន ពីការរំលោភសិទ្ធិមនុស្សនិងអំពើឧក្រិដ្ឋកម្មរបស់រដ្ឋាភិបាលខ្មែរ តើគាត់ធ្វើការអោយអង្គការសហប្រជាជាតិ ទទួលបានប្រាក់ខែប៉ុន្មានក្នុងមួយខែ ចុះបើ ហ៊ុន-សែន អោយ ២រយ ឬ ៣រយលានដុល្លានោះហើយគ្រាន់តែ បំភ្លេចសំណុំរឿងខ្មែរ ដោយយកលេសថាមានសំណុំរឿងលើពិភពលោកច្រើនពេក រវល់ដោះស្រាយមិនទាន់

ចប់ តើសោកនាកកម្មបោកគ្រាប់បែក បង្រ្កាបបាតុកម្ម រដ្ឋប្រហារ,,,,,,,,,ដែល ហ៊ុន-សែន និងគណៈបក្សប្រជាជនកម្ពុជាប្រព្រឹត្តិនោះ ទៅជាយ៉ាងណា? ហើយរួចខ្លួនរហូតដល់ស្លាប់ឬអ៊ី? ដោយសារតែសហគមន៍អន្តរជាតិ និងប្រទេសមហាអំណាចលើលោកដែលមានសហរដ្ឋអាមេរិកជាមេខ្លោងធ្វើពុតជាមើលមិនឃើញ មិនរវល់នៅរាល់បទឧក្រិដ្ឋឃាតកម្ម ភេរវកម្ម និងរបរម៉ាហ្វីយ៉ារបស់ ហ៊ុន-សែន និងគណៈបក្សប្រជាជនកម្ពុជានោះ ហើយបែរជាធ្វើពុតមិនស្គាល់ពីល្បិចយួនកុំមុយនីស្ត៍ មិនដឹងថាឃាតករពិតប្រាកដនៅពីខាងក្រោយខ្មែរជានរណានោះ ថែមទាំងផ្តល់លុយជំនួយ និងប្រាក់កំចីថែមទៀតនោះ ធ្វើអោយមេដឹកនាំយួនកំមុយនីស្តមានមោទនភាពយ៉ាងខ្លាំង សប្បាយឥតឧបមា រហូតដល់ភ្លេចខ្លួន សំដែងឬកពារជាស្តេចចក្រភពជាមេដឹកនាំប្រទេសមហាអំណាច មកចាប់ដៃជាមួយលោកនាយករដ្ឋជប៉ុន និងចិន សូមមើលរូបភាព



ស៊ីហ្អ! អាឆ្កែនេះ! ទើបតែលេបយកប្រទេសឡាវ និងខ្មែរបានថ្មីៗ ចង់តាំងខ្លួនជាមហាអំណាចមកចាប់ដៃរៃស្មើរជាមួយយើងហ្អង៎ហ្អ៎!

ស្អែកចាប់ដៃជាមួយអាហ្អែងហើយហ្អ!! ភើយ!

http://www.thehindu.com/news/international/article857382.ece



នេះជារូបភាពរបស់លោក **(Churchill, Truman, and Stalin during the Potsdam Conference, Germany, 28 July to 1 August 1945)** នៅសន្និសិទ្ធិទីក្រុង ប៉ូស្តាំម ប្រទេសអាឡឺម៉ង់នាថ្ងៃ ទី ២៨ ខែកក្កដា ដល់ថ្ងៃទី ១ ខែសីហា ឆ្នាំ ១៩៤៥ ត្រូវបាននាយករដ្ឋមន្ត្រីយួនឈ្មោះ ង្វៀង-តាន ដុង (Nguyen Tan Dung) តាំងខ្លួនជាមហាអំណាច ដូចលោក ទ្រូ-ម៉ាន់ **Truman** យកស្ទាយចាប់ ដៃឱ្យដូចលោកទ្រូ-ម៉ាន់ តែត្រូវបានលោកនាយក រដ្ឋមន្ត្រីចិនឈ្មោះ វិន-ជាប៉ាវ Wen Jiabao និង នាយករដ្ឋមន្ត្រីជប៉ុនឈ្មោះ ណាវតូ-ខាន់ (Naoto Kan) បដិសេធមិនចាប់ដៃជាមួយ ។

**(៥) -ការពារសន្តិសុខ និងផលប្រយោជន៍ជនជាតិយួននៅស្រុកខ្មែរៈ** ជនជាតិវៀតណាមបាន និងកំពុងតែហូរចូលមកកម្ពុជា ប្រៀបដូចទឹកបាក់ទំនប់ចាប់ពីឆ្នាំ ១៩៧៩ រហូតមកដល់បច្ចុប្បន្ន ដើម្បីសំរេចបេសសកម្មរំលាយជាតិសាសន៍ខ្មែរតាមយុទ្ធោបាយសមានកម្ម និងនយោបាយឆុងសាច់ឈាម ហើយបញ្ហាចោទរបស់ពួកគេ គឺត្រូវតែមានការប្រកួតប្រជែងជាមួយជនជាតិដើម ជនជាតិម្ចាស់ស្រុក ហើយ បើគ្មានអ្នកត្រួសត្រាយផ្លូវអោយពួកគេ ហើយសិនបើគ្មានអ្នកជួយជ្រោងជ្រែងការពារទេគឺពួកគេក៏មិនអាចរស់នៅប្រទេសខ្មែរបានដែរ ។ មុនជនជាតិយួនសំរេចចូលមករស់នៅប្រទេសខ្មែរគឺត្រូវតែមានយុទ្ធសាស្ត្រត្រៀមបំរុងទុកជាមុនរួចជាស្រេចដើម្បីចៀសវាងប្រការចៃដន្យដែលកើតមានគឺៈ

-បណ្ណ័ ឬអត្តសញ្ញាណប័ណ្ណជនជាតិខ្មែរ ឬលិខិតសំអាងដែលអាចប្រើប្រាស់បាន

-ទីលំនៅបណ្តោះអាសន្ន ឬពិតប្រាកដទៅតាមការចាត់តាំង និងបែងចែករបស់អង្គការឧក្រិដ្ឋជនសំងាត់អាវឈុតខ្មៅនេះ ហើយរដ្ឋាភិបាលអាយ៉ងមានការគោលនយោបាយជួយឧបត្ថម្ភដល់ពួកគេតាមការជាក់ស្តែង ។

-មុខរបរ ការងារ និងការប្រកបអាជីវកម្មផ្សេងៗត្រូវតែមានជាស្រេច ។

-ការការពារសន្តិសុខ ការពារសិទ្ធិរកស៊ី និងការផ្តល់ភាពកក់ក្តៅក្នុងការប្រកបអាជីវកម្មផ្សេងៗ ជាភារកិច្ច ជាកាតព្វកិច្ចរបស់រដ្ឋាភិបាលអាយ៉ង និងអង្គការឧក្រិដ្ឋជនសំងាត់អាវឈុតខ្មៅនេះ រួមទាំងការកំចាត់គូរប្រជែង និងការជំរះឧបកសគ្គរាំងស្ទះក្នុងការរកស៊ីរបស់ជនជាតិយួននៅក្នុងស្រុកខ្មែរទៀតផង ។

-អាវុធយុទ្ធភ័ណ្ឌគ្រាប់រំសេវ ស្បៀងអាហារ ដែលអង្គការចាត់តាំងរបស់ថ្នាក់លើបានកប់ទុក និងលាក់ទុកទៅ តាមក្បួនយុទ្ធសាស្ត្រ ហើយគាស់យកមកប្រើប្រាស់នៅគ្រាមានអាសន្ន ឬហេតុការណ៏ចាំបាច់ដែលថ្នាក់លើ និងអង្គការតាំងតំរូវអោយធ្វើ ។ ជនជាតិយួនគ្រប់រូបត្រូវតែត្រៀមលក្ខណៈការពារអធិបតេយ្យកម្ពុជា ដែលជាដែនដីដែលទើបតែទន្រ្ទានបាន ហើយត្រូវតែខំប្រឹងសំរេចបេសសកម្មរំលាយជាតិខ្មែរអោយបានឆាប់បំផុត តាមក្បួនយុទ្ធសាស្ត្រសមានកម្ម និងនយោបាយឆុងសាច់ឈាម ដែលនៅក្នុងអារម្មណ៏ជនជាតិយួនបានចាត់ទុកប្រទេសកម្ពុជាជារដ្ឋាភិបាលទី២របស់វៀតណាម ។

-ទីជំរកយុទ្ធសាស្ត្រសេដ្ឋកិច្ច នយោបាយ និងទីជំរកយុទ្ធសាស្ត្រសង្គ្រាម និងតំបន់ជ័យភូមិរបស់កម្ពុជាគឺជាចំណុចក្តៅ និងជាចំណុចជីពចរស្លាប់រស់ដែលជនជាតិយួនទាំងអស់ត្រូវតែដណ្តើមយកអោយបានសំរាប់ផ្ទេរមរតកបន្តអោយកូនចៅជំនាន់ក្រោយរបស់ពួកគេ សំរេចបេសសកម្មរំលាយជាតិសាសន៏ខ្មែរបន្ត ។ ទីតាំងទាំងនេះ មានដូចជាទីទាំងជាប់មាត់សមុទ្រ ទីតាំងជាប់មាត់ទន្លេ ទីប្រជុំជនធំៗ តំបន់ដីមានជីវជាតិ តំបន់សំបូរទៅដោយភោគទ្រព្យធម្មជាតិ,,,,,,,,ហើយបើកន្លែងណាពិបាកដណ្តើមយក គ្រាន់តែបញ្ជូទៅកាន់រដ្ឋាភិបាលអាយ៉ងពាក់ផ្លាកជីវិនិយោគ ដីសម្បទា ប្លន់ដណ្តើមយកពីជនជាតិខ្មែរ សំរាប់ប្រគល់អោយយួននៅពេលក្រោយៗបន្តទៀត ។

### *៤. អង្គការឧក្រិដ្ឋជនស្របច្បាប់របស់រដ្ឋាភិបាលអាយ៉ងគឺកងកំលាំងប្រដាប់អាវុធៈ*

The Legal Criminal Organization of the Puppet Government is the Armed Forces:

កងកំលាំងប្រដាប់អាវុធរបស់រាជរដ្ឋាភិបាលកម្ពុជាបច្ចុប្បន្ននេះគឺជាអង្គការឧក្រិដ្ឋជនស្របច្បាប់របស់ ហ៊ុន-សែន និងគណៈបក្សប្រជាជនកម្ពុជាមានដូចជា ប៉ូលិស ទាហ៊ាន កងរាជអាវុធហត្ថ កងអង្គរក្សរបស់ថ្នាក់ដឹកនាំជាន់ខ្ពស់របស់គណៈបក្សប្រជាជនកម្ពុជា ក្រុមបណ្តញ្ញចារកម្ម និងពួកខ្លា-ស,,,,,,,,,,,,។ កងកំលាំងប្រដាប់អាវុធរបស់រាជរដ្ឋាភិបាលកម្ពុជា ត្រូវបានបញ្ជូអោយស៊ើបការណ៏ តាមដាន ស៊ើបអង្កេតប្រមូលពត៍មាន ផ្សព្វផ្សាយពត៍មាន បំផុសពត៍មាន បំផ្លើសនិងបំផ្លែពត៍មាន និងប្រឌិតភស្តុតាងបង្កើតសាក្សី

សំដែងឈុតល្ខោនលាបពណ៏បទឧក្រិដ្ឋសំរាប់លាងសំអាតអំពើឧក្រិដ្ឋកម្មរបស់គណៈបក្សប្រជាជនកម្ពុជា និង ពាក់ផ្លាកក្បត់ និងលផាត់ពណ៏តុបតែងបទឧក្រិដ្ឋអោយគណៈបក្សប្រឆាំង រួមទាំងបក្ស ឬមនុស្សដែលជា គោលដៅប្រមាញ់របស់គណៈបក្សប្រជាជន ដូចជាករណីសំលាប់លោក ជា-វិជ្ជា ប្រធានសហជីពកម្មករ,,,, នៅថ្ងៃទី ២២ ខែមករា ឆ្នាំ ២០០៣ ត្រូវបានលោក ហុក-ឡង់ឌី បញ្ជាទៅកាន់លោក ហេង-ពៅ អោយចាប់ ឃាតករសិប្បនិម្មិតឈ្មោះលោក បន-សំណាង និងលោក សុខ-សំអឿន យកមកដាក់គុកសំដែងល្ខោនលាង សំអាតបទឧក្រិដ្ឋកម្មរបស់គណៈបក្សប្រជាជន ហើយទំលាក់កំហុសលើបក្សប្រឆាំង ដោយរួមនឹងការផ្តល់ ភស្តុតាងប្រឌិតរបស់លោក ឆាយ-ស៊ីណារិទ្ធ ។ សូមមើល
http://ki-media.blogspot.com/2006/08/hun-sens-dirty-jobs-heng-pov-reveals.html
http://ki-media.blogspot.com/2006/08/transcript-and-original-statement-of.html ។

ដូចគ្នាដែរ ការបាញ់សំលាប់លោក ឱម-រដ្ឋសាឌី ជាតំណាងរាស្ត្ររបស់គណៈបក្សហ៊ុនស៊ីនប៉ិច និងជាទីប្រឹក្សា ផ្ទាល់របស់សម្តេចក្រុមព្រះនរោត្តម រណឫទ្ធិ នៅឆ្នាំ ២០០៣ ហើយត្រូវបានបង្ខំអោយឃាតករឈ្មោះលោក មុំ-សុផាន់ ( អង្គរក្សផ្ទាល់របស់ ប៊ុន-រ៉ានី ហ៊ុន-សែន) បង្ខំអោយឆ្លើយថាសំលាប់ដោយសាររឿងប្លន់ទូរស័ព្ទ ដើម្បីលាងសំអាតបទឧក្រិដ្ឋឃាតកម្មនយោបាយរបស់ ហ៊ុន-សែន រួមទាំងឃាតម្មនយោបាយលើរូបលោក ហូ-សុខ ដែលធ្វើឡើងដោយលោក ហុក-ឡង់ឌី ផងដែរ ។ លើពីនេះទៅទៀត កងកំលាំងប្រដាប់អាវុធរបស់ រាជរដ្ឋាភិបាលដើរតួជា ឃាតករ និង ភេរវករ ដែលជាឧបករណ៏តែមួយគត់របស់គណៈបក្សប្រជាជនកម្ពុជា

| | |
|---|---|
|  | ឯកសារ ៩ ទំព័ររបស់លោក ហេង-ពៅ http://ki-media.blogspot.com/2006/08/hun-sens-dirty-jobs-heng-pov-reveals.html http://ki-media.blogspot.com/2006/08/transcript-and-original-statement-of.html |

<table>
<tr>
<td>


លោក **ជា-វិជ្ជា** ត្រូវបានពួកក្រុមអង្គការឧក្រិដ្ឋសំងាត់អាវខ្មៅសំលាប់
http://ki-media.blogspot.com/2010/09/assassination-of-union-leader.html
</td>
<td>លោក ជា-វិជ្ជា ត្រូវបានពួកក្រុមអង្គការឧក្រិដ្ឋជនសំងាត់អាវយឺតខ្មៅ បាញ់សំលាប់ ហើយបានយកកាសែតម៉ាហ្វីយ៉ាដាក់កល់ក្រោមក្បាលលោកមុនចាកចេញ ។ នេះបញ្ជាក់ថាឃាតករមានភាពស្ទាត់ជំនាញខាងពិឃាតខ្លាំងណាស់ធ្វើឱ្យជនរងគ្រោះមិនអាចរត់ដល់ថ្នល់ផង ថែមទាំងមានពេលវេលាយកកាសែតទ្រាប់ក្បាលអោយទៀត ។ ប៉ុន្តែរដ្ឋាភិបាលបែរជាចាប់លោក បនសំណាង និង សុខ-សំអឿន មកពាក់ផ្លាកឃាតករបង្វែងដានបទឧក្រិដ្ឋអោយឃាតឆ្ងាយពីគណៈបក្សប្រជាជនកម្ពុជាទៅវិញ ។</td>
</tr>
</table>

និង របស់យួនកំមុយនីស្តក្រុងហាណូយសំរាប់គ្រប់គ្រងប្រជាជនខ្មែរ និងក្តាប់អំណាចយ៉ាងណែននៅក្នុងដៃ ដូច ជាករណីលោក **ហ៊ុន-សែន** បានបញ្ជាអោយក្រុមអង្គរបស់ខ្លួនឈ្មោះលោក **ហុយ-ពិសិដ្ឋ** ជាអ្នកដឹកនាំក្រុមធ្វើការវាយប្រហារដោយគ្រាប់បែកលើហ្វូងបាតុកម្មស៊ីវិលរបស់ប្រជាជនដែលទាមទារសុំអោយកែរទំរង់ប្រពន្ធ័តុលាការខ្មែរនៅមុខរដ្ឋសភាជាតិនាទីក្រុងភ្នំពេញនៅថ្ងៃទី ៣០ ខែមិនា ឆ្នាំ ១៩៩៧ ហើយបទឧក្រិដ្ឋកម្មនេះត្រូវបានផ្តល់គំនិតមិតិយោបល់ដោយលោក ហុក-ឡង់ឌី និង ផ្តល់លុយដោយលោក ហេង-ពៅ (http://ki-media.blogspot.com/2006/08/hun-sens-dirty-jobs-heng-pov-reveals.html)

សូមមើលឯកសារ **FBI Points Finger in Cambodian Attack** របស់វ៉ាស៊ីនតោនប៉ុស្តិ៍នៃវិបសាយ http://www.garella.com/rich/grenpost.htm និងឯកសារនៃវិបសាយ http://editorials.cambodia.org/2008/03/cambodia-infamous-grenade-attack-still.html និងឯកសារវិដេអូនៃវិបសាយ ។ http://ki-media.blogspot.com/2010/10/30-march-1997-grenade-attack.html ។ ។

| | |
|---|---|
|  |  |
| | |
| http://www.garella.com/rich/grenpost.htm<br>http://editorials.cambodia.org/2008/03/cambodia-infamous-grenade-attack-still.html<br>http://ki-media.blogspot.com/2010/10/30-march-1997-grenade-attack.html | |

បន្ទាប់ពីគ្រាប់បែកផ្ទុះរួចហើយ សំលេងសំរែកប្រជាជនរងគ្រោះស្រែកធ្ងូរទ្រហោរយំយ៉ាងឈឺចាប់បំផុត តែបែរជារថក្រោះរបស់រដ្ឋាភិបាលបញ្ចេះម៉ាស៊ីនទ្រហឹងអ៊ឹងកងអមសំរែកជនរងគ្រោះទេ ចំណែកជនដៃដល់បែរជារត់រួចយ៉ាងសុវត្ថិភាព ក្រោយមកលោក ជា-សុផារ៉ា បែរជាយកម៉ាស៊ីនមកស្រូបយកកំទេចគ្រាប់បែក និងយកទ្បានទឹកមកលាងសំអាតភស្តុតាងដានស្នាមឧក្រិដ្ឋទៅវិញ ហើយក្រសួងមហាផ្ទៃបានចាត់អ្នកជំនាញឈ្មោះលោក ប្រាជ្ញ-បញ្ញា អោយមកស្រាវជ្រាវរឿងនេះ តែត្រូវបានបាត់ខ្លួនរហូតមកដល់បច្ចុប្បន្ន នេះបើតាមសំដីរបស់លោក លី-រ៉ាស៊ី អតីតជាប្រធានព្រហ្មទណ្ឌក៏រិតស្រាល,,,,,,បានប្រាប់ខ្ញុំនៅអាគារអា នៃគុកព្រៃស នៅខែតុលា ឆ្នាំ ២០០៦ ហើយលោក លី-រ៉ាស៊ី បានផ្តាំខ្ញុំថា"**បើចង់ច្បាស់រឿងនេះ អោយរកលោក ប្រាជ្ញ-បញ្ញា អោយឃើញ ហើយ ពេលខ្ញុំរៀបចេញពីគុក គាត់នឹងផ្តល់ឯកសារភស្តុតាងឧក្រិដ្ឋរបស់គណៈបក្សប្រជាជនកម្ពុជាមកឱ្យខ្ញុំ**" តែគួរ ឱ្យស្តាយ ពេលខ្ញុំសល់រយៈ ៤ខែខាងមុខទៀតរៀបចេញពីគុក ខ្ញុំត្រូវបានចាងហ្វាងគុកព្រៃ-ស ឈ្មោះ ម៉ុង-គីមហេង ដាក់អោយនៅបន្ទប់លេខ ១ អាគាសេ ដែលមានសុទ្ធតែពួកអង្គរក្ស ហ៊ុន-សែន នៅជាមួយខ្ញុំចំនួន៦នាក់ដែលខ្ញុំស្គាល់ ហើយខាងមុខបន្ទប់ខ្ញុំក៏មានអង្គចំនួន ៤ នាក់

ដែលខ្ញុំស្គាល់ ហើយខ្ញុំត្រូវបានដាក់កំហិតមិនអោយចេញពីបន្ទប់ ឬក៏ឆ្លងកាត់អាគារគុកឡើយ ហើយនៅពេលជួបអង្គការគឺសុទ្ធតែប៉ូលីសអមដំណើរខ្ញុំ ធ្វើឱ្យខ្ញុំគ្មានឱកាសធ្វើការទាក់ទងជាមួយពួកអ្នកទោសឡើយ។ មិនត្រឹមតែប៉ុណ្ណោះ កងកំលាំងប្រដាប់អាវុធរបស់រាជរដ្ឋាភិបាលត្រូវបានបញ្ជាឱ្យសំលាប់ប្រជាជនខ្មែរ និងបំផ្លាញជាតិខ្មែរ ព្រមទាំងឆក់ប្លន់យ៉ាងបើកចំហរដោយមិនខ្លាចញញើតនឹងច្បាប់អន្តរជាតិ អង្គការ សហគមន៏អន្តរជាតិឬប្រទេសមហាអំណាចណាឡើយ ទោះបីឪសហរដ្ឋអាមេរិកក៏មិនអាចធ្វើអ៊ី ហ៊ុន-សែន បានឡើយ សមដូចលោក ម៉ុង-គីមហេង ចាងហ្វាងគុកព្រៃសបានគំរៀមសំលាប់ខ្ញុំក្នុងគុកដោយព្រមាននៅថ្ងៃទី ១០ ខែតុលាឆ្នាំ២០០៧ថា **"អង្គការវាគ្មានបានប្រយោជន៍អ្វីទេ អាអង្គការវាំស្រែកដើម្បីឱ្យបានលុយតែប៉ុណ្ណោះ"** ។ ជាការជាក់ស្តែង គណៈបក្សប្រជាជនកម្ពុជាមិនគោរពច្បាប់អន្តរជាតិ ឬកិច្ចព្រមព្រៀងក្រុងប៉ារីសអ្វីឡើយ ដូចជាការធ្វើរដ្ឋ ប្រហារបង្ហូរឈាមនៅកណ្តាលក្រុងភ្នំពេញនៅថ្ងៃទី ៥-៦ កក្កដា ឆ្នាំ ១៩៩៧ ដណ្តើមយកអំណាចផ្តាច់មុខដើម្បីប្រើអំណាចផ្តាច់ការបំរើគោលនយោបាយលេបទឹកដីខ្មែរ និងរំលាយជាតិសាសន៏ខ្មែររបស់យួនកំមុយនីស្តក្រុង ហាណូយ ដោយទាត់ចោលកិច្ចព្រមព្រៀងក្រុងបារីសថ្ងៃ ២៣ តុលា ឆ្នាំ ១៩៩១ ហើយចុះសន្ធិសញ្ញាបំពេញ បន្ថែមជាមួយរដ្ឋាភិបាលក្រុងហាណូយដើម្បីអនុវត្តសន្ធិសញ្ញាព្រំដែនខ្មែរ-យួន នៅ ឆ្នាំ ១៩៨២-១៩៨៣ និង ១៩៨៥ ជំនួសកិច្ចព្រមព្រៀងក្រុងប៉ារីស។ ជាសំលាប់រង្គាលប្រជាជនខ្មែរនៅខែកញ្ញា ឆ្នាំ ១៩៩៨ កងកំលាំងប្រដាប់អាវុធត្រូវបានបញ្ជារអោយស៊ើបការណ៏ ស៊ើបអង្កេតតាមដានរាល់សកម្មភាពជីវិតផ្ទាល់ខ្លួន របស់ប្រជាជនខ្មែរ អ្នកនយោបាយខ្មែរទាំងក្នុងបក្សនិងក្រៅបក្ស ពួកឥស្សរះជនខ្មែរ ពួកវរះជនខ្មែរ ពួកអ្នក ស្នេហាជាតិខ្មែរ ពួកអ្នកជាតិនិយមខ្មែរ ពួកបក្សប្រឆាំង និងពួកអ្នកមាននិន្នាការប្រឆាំង ពួកដែលមិនចុះចូលពួកយួនកំមុយនីស្ត៏ ពួកដែលមិនចុះចូលនឹងអា ហ៊ុន-សែន និង



ប្រជាជនខ្មែរគេចវាសពីការសំលាប់របស់ CPP



សកម្មភាពបំផ្លាញទីក្រុងភ្នំពេញរបស់ CPP



សកម្មភាពប្លន់ប្រមូលទ្រព្យសម្បត្តិប្រជារាស្ត្រខ្មែរ របស់ពួកកងកំលាំងប្រដាប់អាវុធរបស់គណៈបក្ស ប្រជាជនកម្ពុជា។



សកម្មភាពប្លន់ប្រមូលទ្រព្យសម្បត្តិប្រជារាស្ត្រខ្មែរ របស់ពួកកងកំលាំងប្រដាប់អាវុធរបស់គណៈបក្ស ប្រជាជនកម្ពុជា។

http://www.seasite.niu.edu/khmer/ledgerwood/july_56_1997_events.htm

គណៈបក្សប្រជាជនកម្ពុជា និងពួកអ្នកក្បត់បក្ស ឬជនដែលគេសង្ស័យថាក្បត់.,.,.,.,ប្រសិនបើឱកាសហុចឱ្យ ពួកចារកម្មរបស់កងកំលាំងប្រដាប់អាវុធនឹងធ្វើការលួចឆក់ប្លន់ ចាប់ជំរិត ចាប់ដាក់គុក ចាប់ធ្វើទារុណកម្ម ឬសំលាប់ទៅតាមការដាក់ទិសរបស់បក្ស ឬទៅតាមការបញ្ជារបស់ ហ៊ុន-សែន និងថ្នាក់លើរបស់គណៈបក្ស ប្រជាជនកម្ពុជា។ ហ៊ុន-សែន ហុក-ឡង់ឌី និងពួកមេដឹកនាំជាន់ខ្ពស់ដទៃៗទៀត បានប្រើប្រាស់ពួកក្រុមកង កំលាំងប្រដាប់អាវុធ និងកងកំលាំងអង្គរក្សអោយធ្វើជាកំលាំងជំនួយ ជាអ្នកជំនាញការ និងជាសមាជិករបស់

អង្គការឧក្រិដ្ឋជនសំងាត់បាក់គី អង្គការឧក្រិដ្ឋជនសំងាត់អេស-អូ-វ៉ាយ និងអង្គការឧក្រិដ្ឋជនសំងាត់អាវខ្មៅ ឬឈុតខ្មៅ ព្រមទាំងធ្វើជាមេក្រុមបងតូចបងធំផងដែរ។ លើសពីនេះទៅ កងកំលាំងប្រដាប់អាវុធរបស់រាជរដ្ឋាភិបាលបានបំពេញតួនាទីបំបិទភស្តុតាង លុបស្នាមដានឧក្រិដ្ឋ សំលាប់សាក្សី ប្រឌិតសាក្សី និងភស្តុតាង តាក់តែងឆាកល្ខោននយោបាយ បន្ថែមលើភស្តុតាង និងឧក្រិដ្ឋជនសិប្បនិម្មិត្ត ដើម្បីដូរនឹងលកខ័ណ្ឌដែលជាគោលដៅរបស់យួនកុំមុយនីស និងគណៈបក្សប្រជាជនកម្ពុជាចង់បាន,,,,,,,,,,,,,,

ពួកឧក្រដ្ឋករ ឃាតករ និងភេរវករ ដែលក្រុងហាណូយយល់ថាអស់តំលៃនៅក្នុងការប្រើបាស់ ឬបារម្ភខ្លាចបែករឿងអាថ៏កំបាំង និងពេលវេលាប្រធានសក្តិមកដល់ហើយនោះ គឺត្រូវតែកំទេចចោលជាចាំបាច់ និងជាបន្ទាន់ គណៈបក្សប្រជាជនកម្ពុជាត្រូវតែសំរេចភ្លាមដោយគ្មានការយោគយល់ ឬរារែកអ្វីឡើយ គឺជីវិតពួកឧក្រិដ្ឋករ ឃាតករ និងភេរវករ ប្រៀបដូចជាអាចម៍អណ្តែតលើទឹក មិនថាបុណ្យឋានៈធំតូចអ្វីឡើយ គឺវាសនាដូចគ្នា គ្រាន់តែមុនហើយនិងក្រោយតែប៉ុណ្ណោះ គឺខ្លះត្រូវបានសំលាប់ ខ្លះត្រូវបានជាប់គុកពីជាច្រើនឆ្នាំរហូតដល់មួយជីវិតក៏មាន ដោយគ្រាន់តែពាក់ផ្លាកថាជាឃាតករ ភេរវករ ចោរប្លន់ ចោរចាប់ជំរិតជាជនក្បត់ ទាក់ទងរណសិរ្ស ឬចលនារំដោះផ្សេងៗ ខ្លះទៀតត្រូវបានភៀសលាក់ខ្លួនក្លែងភេទដូរត្រគោល។ ដូចជាករណីលោក ហេង-ពៅ លី-វ៉ាស៊ី យមរាជ,,,,,,,ដែលបេសកកម្មគ្រប់យ៉ាងរបស់ពួកគាត់គឺសុទ្ធតែធ្វើតាមការបញ្ជារបស់លោក ហុក-ឡង់ឌី ហ៊ុន-សែន និងថ្នាក់ដឹកនាំកំពូលៗរបស់គណៈបក្សប្រជាជនកម្ពុជាហើយទីបំផុតត្រូវបានជាប់គុកអស់ជាច្រើនឆ្នាំ ចំណែកលោក ហុក-ឡងឌី ដែលជាមេឃាតករ ភេរវករមេចោរប្លន់ជំរិត និងជាមេបនស្រីបនល្បែង រកលុយអោយឃ្លាំរដ្ឋយួនរាប់មិនអស់ បញ្ចូលជនជាតិយួនឱ្យហូរចូលស្រុកខ្មែររាប់ភ្លេច និងបានសំរេចបេសសកម្មរំលាយជាតិខ្មែររបស់ក្រុងហាណូយរាប់មិនអស់មិនហើយ ទីបំផុតត្រូវបានសំលាប់បំបិទមាត់យ៉ាងអាណោចអធម សូម្បីតែសាកសព្វទាំងមូល ក៏មិនអាចរក្សាបានផង នៅអា ហ៊ុន-សែន មួយទៀត មិនដឹងថាក្រុងហាណូយសំលាប់បំបិទដោយរបៀបណា? របៀបផ្ទុះយន្តហោះក្រឡាប់ឡាន ផ្ទុះគ្រាប់បែក ឬមួយក៏ត្រូវសំលាប់ដោយរបៀបឃាតកម្មនយោបាយ?,,,,,,,,,បើរឿងចាប់កាត់ទោស ហ៊ុន-សែន គឺមិនអាចធ្វើបានឡើយ ព្រោះថា ឧក្រិដ្ឋកម្មរបស់ ហ៊ុន-សែន ស្តែងចេញអោយឃើញនៅការបញ្ជារបស់រដ្ឋាភិបាលយួនកំមុយនីស្ត៍ ជាក់ច្បាស់ជាង អំពើឧក្រិដ្ឋកម្មខ្មែរក្រហមដែលពាក់ព័ន្ធនឹងយួនកំមុយនីស្ត៍ ចុះបើបែកការ មិនវីវរធំដល់យួនកំមុយនីស្ត៍ទៅហើយ តែមិនអ៊ីទេ យួនឆ្លាតណាស់

បើសហគមន៍អន្តរជាតិ នឹងរកឃើញថា អំពើឧក្រិដ្ឋកម្មលើប្រជាជនខ្មែរដែលធ្វើឡើយដោយខ្មែរក្រហម និង ហ៊ុន-សែន គឺសុទ្ធតែជាបញ្ជារបស់រដ្ឋាភិបាលយួនកំមុយនីស្ត៍ គឺយួននឹងដូររដ្ឋាភិបាលមកជារបបសេរីនិយម ក្លាម ហើយចាប់ខ្មោចលោក ហូ-ជីមិញ មកកាត់ទោសដូចប៉ុល-ពត នោះ នឹងបោកយកលុយជំនួយរបស់ សហគមន៍អន្តរជាតិបានរាប់មិនអស់ ដូចអា ហ៊ុន-សែន សំដែងល្ខោនបង្កើតសាលាក្តីតុលាការខ្មែរក្រហម អញ្ចឹង។ តើសហគមន៍អន្តរជាតិល្ងង់ ឬក៏ពួកគេទទួលផលប្រយោជន៍នៅពីខាងក្រោយភាពល្ងង់ខ្លៅរបស់ ពួកគេ បែរជាមើលមិនឃើញអា ហ៊ុន-សែន ជាមេឧក្រិដ្ឋករ ជាមេឃាតករ ជាមេភេរវករ និងមើលមិន ឃើញយួនកំមុយនីស្តនៅពីខាងក្រោយរបបក្រហម?

## *៥.រចនាសម្ព័ន្ធឃាតកម្មរបស់គណៈបក្សប្រជាជនកម្ពុជា:*

បើគណៈបក្សប្រជាជនកម្ពុជាដាក់ **បញ្ចូលនរណាម្នាក់ចូលក្នុងបញ្ជីស្បែកខ្លែងរបស់ពួកគេហើយ អ្នកនោះកំរស់គេចខ្លួនរួចណាស់ ព្រោះថា គណៈបក្សប្រជាជនកម្ពុជា ជាពិសេសអា ហ៊ុន-សែន តែម្តង តែងតែប្រើគ្រប់មធ្យោបាយដើម្បីប្រមាញ់គោលដៅរបស់ខ្លួនអោយបាន ហើយក្នុងការសំលាប់គោលដៅ នោះ** ពួកវាតែងតែបែងចែកជាជំហ៊ានៗទៅ តាមរចនាសម្ព័ន្ធឃាតកម្មដូចតទៅ:

**ដ្យាក្រាមនៃរចនាសម្ព័ន្ធឃាតកម្មរបស់គណៈបក្សប្រជាជនកម្ពុជា**




**-ជំហ៊ានទី១ គឺដំណាក់កាលបញ្ជាពីថ្នាក់លើ ពីហ៊ុន-សែន ប៊ុន-រ៉ានី ហុក-ឡង់ឌី:** ពាក្យស្លោកកុំមុយនីស្ត៍ បានពោលថា រាល់គ្រប់បញ្ជា គ្រប់ទង្វើរ និងរាល់គ្រប់ការសំរេចរបស់ថ្នាក់លើគឺសុទ្ធតែជាការត្រឹមត្រូវទាំង អស់ ថ្នាក់ក្រោមមិន ចាំបាច់ចង់ដឹងពីមូលហេតុអ្វីឡើយ ហើយក៏មិនត្រូវរារែកស្ទាក់ស្ទើរក្នុងការអនុវត្តបញ្ជា ឡើយ អ្នកដែលមិនធ្វើតាម មិនអនុវត្តតាមបញ្ជាថ្នាក់លើគឺមានន័យថាជាខ្មាំង បើជាខ្មាំងគឺត្រូវតែកំទេច ចោល។ នៅថ្ងៃទី ១៧ ខែកញ្ញា ឆ្នាំ ២០០៦ អា ហ៊ុន-សែន បាននិយាយក្នុងពិធីថ្លែងសន្ទរកថា នៅខេត្ត

កំពង់ធំថា "ផោមក្នុងទឹក ក៏វាដឹងដែរ គ្មានអ្វីលាក់វាជិតទេ" ដូច្នេះគ្មានអ្វីគួរឱ្យឆ្ងល់ទេ នៅរាល់គ្រប់អំពើឃាតកម្មនយោបាយ ភេរវកម្មបោកគ្រាប់បែកលើហ្វូងបាតុករនៅមុខរដ្ឋសភាថ្ងៃទី ៣០ ខែមិនា ឆ្នាំ ១៩៩៧ អំពើមនុស្សឃាតផ្សេងៗ ការឆក់ប្លន់ជីវិត ការស្លាប់ដោយសារពេទ្យពិឃាត ការស្លាប់ដោយគ្រោះថ្នាក់ចរាចរ ការស្លាប់ដោយឧប្បត្តិហេតុផ្សេងៗរបស់ពួកអ្នកនយោបាយប្រឆាំង និងពួកអ្នកគាំទ្រនយោបាយប្រឆាំង គឺសុទ្ធតែជាការរៀបចំ បង្កើតឡើងដោយគណៈបក្សប្រជាជនទាំងអស់ រួមទាំងការរកស៊ីជួញដូរមនុស្ស ជួញដូរគ្រឿង ញៀន ឃាតករស៊ីឈ្នួល អំពើពុករលួយ,,,,,,,,ជាដើមគឺសុទ្ធជាទង្វើររបស់គណៈបក្សប្រជាជនកម្ពុជា ជាអ្នកធ្វើទាំងអស់ បើពួកវាជាអ្នកធ្វើ តើពួកវាអាចបញ្ជូអោយតុលាការរបស់ពួកវាចាប់ផ្តន្ទាទោសដែរឬ? សូម្បីតែកុំមុយនីស្តិ៍គ្នាវាក៏ដោយ អោយតែមិនស្តាប់បញ្ជារបស់ថ្នាក់លើ ត្រូវបានថ្នាក់លើចាត់ទុកជាខ្មាំង ហើយត្រូវតែកំទេចចោលជាដាច់ខាត ដូចជាករណីលោក ហេង-ពៅ គ្រាន់តែមិនបានអនុវត្តន៏តាមបញ្ជារបស់លោក ហុក-ឡង់ឌី ត្រូវបានដកហូតចេញពីតំណែងខ្លាញ់ ហើយទីបំផុតដកបុណ្យសក្តិ ចាប់ដាក់គុក កាត់ទោសអោយនៅក្នុងគុកជិត ១០០ ឆ្នាំ ចុះល្មមតែពួកប្រឆាំងដែលមិនមែនជាគ្នារបស់ពួកវា តើទៅយ៉ាងណា? សូមមើលអាស័យដ្ឋានអ៊ីនធឺនិតខាងក្រោមនេះ
http://ki-media.blogspot.com/2006/08/transcript-and-original-statement-of.html

**-ជំហ៊ានទី២ គឺជំណាក់កាលតាមដានស៊ើបការយកពត៏មាន:** នៅពេលដែលថ្នាក់លើ (ហ៊ុន-សែន ប៊ុន-រ៉ានី ហុក-ឡង់ឌី,,,,,,,,,)របស់គណៈបក្សប្រជាជនកម្ពុជា ដាក់បញ្ជាហើយ ក្រសួងស្ថាប័នពាក់ព័ន្ធនឹងកងកំលាំងប្រដាប់អាវុធតែងតែប្រើពួកចារកម្មដែលមាន៥ គឺ ចារបុរស្សមនុស្សរស់ ប្រតិចារបុរស ចារបុរសមនុស្សក្នុង ចារបុរសរនុកក្នុង មរណៈចារបុរស នៅក្នុងជួរកងកំលាំងប្រដាប់អាវុធរបស់ពួកគេដែលបំពាក់ទៅដោយឧបករណ៏អាសន្សាណូទំនើប (Spy Bugs) ដែលជាឧបករណ៏តាមដានទំហំតូចៗអាចមានដល់តូចជាងឡេវអាវ ឬប៊ិទចុងជើងធូប ឬជាសរសៃលោហៈដូចខ្សែសយ សំរាប់បង្កប់តាមបន្ទាប់ផ្ទះ ឡាន គ្រឿងឧបករណ៏ប្រើប្រាស់ ក្នុងកញ្ចប់បារី មួក ប៊ិច ឬក៏បង្កប់ក្នុងទីអាថ៏កំបាំងដែលស្មានមិនដល់ ហើយពួកអ្នកតាមដានគឺគ្រាន់តែមើលតាមអេក្រង់កំព្យូទ័រពីចំងាយ គឺអាចឃើញរូបភាព និងស្តាប់សំលេងបានយ៉ាងច្បាស់ សូមមើល ($\text{Source}^{Special}$) ដើម្បីតាមដានរាល់ទង្វើរសកម្មភាពទាំងក្នុងផ្ទះ ទាំងក្រៅផ្ទះ របស់ មនុស្សដែលជាគោលដៅប្រមាញ់ពិសេសរបស់របស់គណៈបក្សប្រជាជនកម្ពុជា ដោយមានឧបករណ៏ទំនើប ធម្មតាជាជំនួយ




បន្ថែមដូចជាទូរស័ព្ទ វិទ្យុទាក់ទង (Walkie-Talkie) យានជំនិះ កាំភ្លើងខ្លី គ្រាប់បែកដៃ លុយកាក់




ស្បៀងអាហារ ឧបករណ៍ប្រើប្រាស់ផ្សេងៗ បើចាំបាច់ត្រូវតែសំលាប់គោលដៅមុនការបញ្ជាឱ្យ ឃាតករមកសំលាប់។ ពួកចារកម្មអស់ទាំងនេះចែកចេញជា ៣ ក្រុមទៀតគឺ សំរាប់ផ្លាស់ប្តូរគ្នា សង្កេតឃ្លាំមើលតាមដាន ហើយបើសិនជាទាក់ទងនឹងអ្នកនយោបាយប្រឆាំងសំខាន់ៗ ពួកចារកម្មទាំង ៣ ក្រុមនេះ ដើរតួជាឃាតករសំលាប់គ្នាទៅវិញទៅមកគឺ ក្រុមទី២សំលាប់ក្រុមទី១ ក្រុមទី៣សំលាប់ក្រុមទី២ ហើយ អង្គរក្សអាវខ្មៅ ឬក្រុមដ៏ទៃទៀតសំលាប់ក្រុមទី៣។ លើសពីនេះទៅទៀតនោះ គឺ ហ៊ុន-សែន តែងតែចូលចិត្តប្រើប្រាស់ពួកក្រុមក្មេងស្ទាវ និង ពួកក្រុមបងតូចបងធំនៃអង្គការ ឧក្រិដ្ឋជនសំងាត់ អេស-អូ-វ៉ាយ អោយតាមដានមនុស្សដែលជាគោលដៅប្រមាញ់បន្ថែមលើពួកចារកម្មរបស់កងកំលាំងប្រដាប់អាវុធ ព្រោះ ហ៊ុន-សែន មិន

ចេះទុកចិត្តនរណាឡើយ ដោយសារតែវាជាមនុស្សជំនិតរបស់លោកប៉ែន-សុវណ្ណ ហើយក្បត់លោកដើម្បីប្តូរនឹងអំណាចដែលយួនផ្តល់អោយ ហើយវាតែងតែធ្លាប់បានថ្លែងសន្ទរកថាជាសាធារណៈថា "ប្រយ័ត្ន! អាអោនណាស់ គឺគ្រោះថ្នាក់ណាស់! មានតែបន្លាដែលនៅជិតជើងទេ ដែលធ្វើអោយមុតជើង! អាជិតកៀកណាស់ គឺគ្រោះថ្នាក់ណាស់! "។ មូលហេតុដែល ហ៊ុន-សែន ចូលចិត្តប្រើប្រាស់ ពួកសមាជិកអង្គការឧក្រិដ្ឋជនសំងាត់ អេស-អូ-វ៉ាយ ព្រោះពួកនេះលាក់ការណ៍បានល្អ ដោយសារតែបណ្តាញប្រព័ន្ធពួកគេស្មុគស្មាញស្មានមិនដល់ គឺហ៊ុន-សែន គ្រាន់តែបញ្ជូទៅលោក ជា-សុផារ៉ា និងលោក កែន-ចំរើន ពេលនោះលោក កែន-ចំរើន បានបញ្ជូទៅ**ពួកមេក្រុមបងតូចបងធំ "លោកបងធំៗ"** ដែល**មានឋានៈ**គ្រាន់តែជា**សមាជិកនៃអង្គការឧក្រិដ្ឋជនសំងាត់ អេស-អូ-វ៉ាយ** តែប៉ុណ្ណោះ ហើយពួកមេក្រុមបងតូចបងធំ "លោកបងធំៗ" បានបញ្ជូទៅកាន់កូនចៅរបស់ខ្លួន ពួកមនុស្សដែលស្ថិតនៅក្នុងក្រុមបងតូចបងធំរបស់ខ្លួន (ដែលពួកគេមិនដែលដឹងសោះថា តើអង្គការឧក្រិដ្ឋជនសំងាត់ អេស-អូ-វ៉ាយ ជាអ្វីឡើយ) អោយតាមដាន សង្កេតឃ្លាំមើល មនុស្សដែលបងធំស្អប់ ដែលមានបញ្ហាជាមួយលោកបងធំរបស់ពួកគេ បើអ្នកណាធ្វើបានជោគជ័យ អ្នកនោះនឹងទទួលការកោតសរសើរលើកទឹកចិត្តមានមុខមានមាត់ជាងគេនៅក្នុងក្រុមបងតូចបងធំរបស់ពួកគេ ថែមទាំងមាន**ឱកាសរកលុយពិសេស**ច្រើនជាងគេនៅក្នុងក្រុមបងតូចបងធំរបស់ពួកគេ ហើយបើមានបញ្ហាវិញនោះលោកធំរបស់ពួកគេនឹងចេញមុខជួយ ឬចេញមុខកាងជំនួស ដូច្នេះហើយបានជាពួកក្រុមក្មេងស្ទាវ ពួកក្រុមក្មេងអាណាថា និងពួកក្រុមបងតូចបងធំនៃអង្គការឧក្រិដ្ឋជនសំងាត់ អេស-អូ-វ៉ាយ ប្រឹងប្រែងតាមដានរាល់សកម្មភាពមនុស្សដែលជាគោលដៅប្រមាញ់ ម្យ៉ាងវិញទៀតគឺ ហ៊ុន-សែន មិនចាំបាច់ធ្វើការចំណាយលុយកាក់អ្វីទេ គឺ ហ៊ុន-សែន គ្រាន់តែផ្តល់ **ឱកាសរកលុយពិសេស** ដល់ពួកក្រុមក្មេងស្ទាវ ក្រុមពួកក្មេងអាណាថា និងពួកក្រុមបងតូចបងធំនៃអង្គការ ឧក្រិដ្ឋជនសំងាត់ អេស-អូ-វ៉ាយ ជាការស្រេច។

**-ជំហ៊ានទី៣ គឺដំណាក់កាលសំលាប់ពិឃាត :** គណៈបក្សប្រជាជនកម្ពុជា មានប្រភពដើមកំណើតចេញមកពីយួនកុំមុយនីស្តដែលជាអ្នកបង្កើត និងបន្តុបពួកគេឱ្យស្ថិតនៅលើបល្ល័ង្កអំណាចដែលសោយអំណាចរហូតដល់បច្ចុប្បន្ននេះ ហើយយកព្រះមហាក្សត្រធ្វើជាទ្រនាប់ជើងរបស់ពួកគេដើម្បីឈរលើអំណាចទាត់ធាក់វាយប្រហារសំលាប់ប្រជារាស្ត្រខ្មែរស្រេចតែក្បាលចិត្តដោយគ្រាន់តែយកលេសថាអនុវត្តតាមព្រះហត្ថលេខារបស់ព្រះមហាក្សត្រ ឬធ្វើតាមព្រះរាជតំរិះព្រះមហាក្សត្រតែប៉ុណ្ណោះ។ ទោះបីជាពួកថ្នាក់ដឹកនាំរបស់គណៈបក្ស

ប្រជាជនកម្ពុជាចេញប្រភពមកពីពួកចោរលួចចោរប្លន់ក្មេងពាលក្មេងអាណាថា មិនបានរៀនសូត្រជ្រៅជ្រះក៏ដោយ ប៉ុន្តែពួកគេបានទទួលការហ្វឹកហាត់សិល្បៈសង្គ្រាមបែបកុំមុយនីស្តិ៍ពីចៅហ្វាយយួនរបស់ពួកគេ ហើយពួកគេមានជំនាញប៉ិនប្រសព្វណាស់ចំពោះខាងរឿងសំលាប់ឃាតកម្ម ការធ្វើភេរវកម្ម ការគំរាមកំហែង ការបំបាក់ ស្មារតីប្រជារាស្ត្រខ្មែរអោយភ័យរន្ធត់ខ្លាចបាក់ស្បាត ការប្រើឃាតករក្នុងបណ្តាញខ្សែសង្វាក់ចុចអន្ទាក់គឺជាជំនាញរបស់ពួកគេនៅក្នុងការក្តោបអំណាច ហើយ **ចំណុចខ្លាំងរបស់ពួកកុំមុយនីស្តិ៍គឺ ប្រើប្រាស់ឃាតកម្ម ទារុណកម្ម និងភេរវកម្មដែលប្រើជាឧបករណ៍តែមួយគត់សំរាប់គ្រប់គ្រងប្រទេស និងត្រួតត្រាក្តោបក្តាប់ប្រជាជនខ្មែរយ៉ាងណែននៅក្នុងដៃ** ហើយ **ចំណុចខ្សោយរបស់ពួកកុំមុយនីស្តគឺសេដ្ឋកិច្ច តែបើពួកវាមានសេដ្ឋកិច្ចហើយគឺប្រៀបបីដូចជាសត្វខាដុះស្លាប ធ្វើអ្វីក៏បាន**។ ទោះបីជាពួកថ្នាក់ដឹកនាំកុំមុយនីស្តិ៍កំពូលៗរបស់គណៈបក្ស ប្រជាជនកម្ពុជាសំលាប់ប្រជារាស្ត្រខ្មែររាប់មិនអស់ក៏ដោយ ក៏ពួកគេប៉ិនប្រសព្វធ្វើអោយពិភពខាងក្រៅដូចជាសហគមន៍អន្តរជាតិ មហាអំណាចពិភពសេរីមានសហរដ្ឋជាមេខ្លោងជាដើមនៅតែមិនដឹងខ្យល់អ្វី ហើយថែមទាំងចូលរួមប្រល័យប្រជារាស្ត្រខ្មែរតាមរយៈលុយជំនួយ និងលុយកម្ចីបរទេសបរទេសរបស់ពួកគេផ្តល់អោយដល់រដ្ឋាភិបាលភេរវករខ្មែរ **ព្រោះថាលុយជំនួយ លុយកម្ចីបរទេសដែលរដ្ឋាភិបាលភេរវករខ្មែរ ទទួលបានពីសហគមន៍អន្តរជាតិ អង្គការអន្តរជាតិ ប្រទេសមហាអំណាចនានា រដ្ឋាភិបាលភេរវករខ្មែរ បានយកលុយទាំងនោះទៅបង្កើតអង្គការឧក្រិដ្ឋជនសំងាត់មួយហើយមួយទៀត ហើយយកលុយទាំងនេះទៅលើកទឹកចិត្តឃាតករ ទិញទឹកចិត្តឃាតករសំលាប់ឃាតករបំបិទភស្តុតាង ទិញទឹកចិត្តប្រជាជនអោយជួយសំរួលដល់ដំណើរការឧក្រិដ្ឋកម្មតាមរយៈទិញពត៌មាន និងជួលទីតាំងឱ្យពួកក្រុមឃាតករប្រព្រឹត្តិបទឧក្រិដ្ឋបានឆាប់រហ័ស ទិញទឹកចិត្តមនុស្សធម្មតាឱ្យជួយតាមដានស៊ើបអង្កេតអោយពួកវា ទិញអាវុធទំនើបៗ ទិញឧបករណ៍ប្រើប្រាស់ទំនើបៗក្នុងការសំរួលដល់ការប្រព្រឹត្តិបទឧក្រិដ្ឋផេង្សៗ និងអំពើឃាតកម្មរបស់ខ្លួនដូចជា ទូរស័ព្ទ វិទ្យុទាក់ទង កំព្យូទ័រ យានជំនិះគ្រប់ប្រភេទ ជួលផ្ទះសំណាក់ទីអាស្រ័យ និងទិញឧបករណ៍ចារកម្មអាសន្យាណូ ទំនើប** (modern spy bugs' tools) ដើម្បីសំរួលដល់ការតាមដានស៊ើបការណ៍ ការប្លន់ជីវិត ការចាប់ចង ការសំលាប់ ការធ្វើឃាតកម្មនយោបាយ ការធ្វើភេរវម្មជាដើម ការជួញដូរគ្រឿងញៀន ការជួញដូរមនុស្ស, ,,,,,,,,។ល។ និង ។ល។ ចំពោះជំហ៊ានទីពនេះ គឺដំណាក់កាលនៃការសំលាប់ ពួកមេដឹកនាំគណៈបក្សប្រជាជនប៉ិនប្រសព្វ និងពូកែខ្លាំងណាស់ក្នុងរឿងនេះ ជាពិសេស គឺ

